**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា**

# ការអភិវឌ្ឍវិស័យកសិកម្មរបស់សហគមន៍ កសិកម្មភ្នំដិនសែនសុខ

កម្មសិក្សាចាប់ពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០២០ ដល់ ថ្ងៃទី១៥ ខែ ឧសភា ឆ្នាំ២០២០

ឈ្មោះស្ថាប័ន៖ សហគមន៍កសិកម្មភ្នំដិនសែនសុខ ភូមិទទឹង ឃុំភ្នំដិន ស្រុកគីរីវង់ ខេត្តតាកែវ


តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **សឿន ម៉ុនថាត់**

**ផន សុភាន់**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត ឈុន ពហុ**


ថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ៤

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេររបាយការណ៍ ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **សឿន ប៊ុនថាត់** និង **ផន សុភាន់** លជានិស្សិតបរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ឆ្នាំទី៤ ជំនាន់ទី៤ នៃសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។ តាមរយៈការនាំណែ និងផ្តល់យោបល់ជាច្រើនដែលជួយឱ្យរបាយការណ៍បញ្ចប់ការសិក្សារបស់ពួកយើងខ្ញុំទទួលបានជោគជ័យជាស្ថាពរ។

**សូមសម្តែងការគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

លោកឪពុក អ្នកម្តាយរបស់យើងខ្ញុំដែលបានផ្តល់កំណើត និងខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតដល់ធំដឹងក្តីប្រកបដោយព្រហ្មវិហារធម៌ចំពោះកូន។ លោកទាំងទ្វេរជួយផ្គត់ផ្គង់គ្រប់បែបយ៉ាង តាំងពីកម្លាំងកាយចិត្ត ផ្នែកស្មារតី និងផ្នែកសម្ភារៈ។ លោកជាព្រះព្រហ្មរបស់កូន ជាគ្រូរបស់កូន ជាពេទ្យរបស់កូន ជាអ្នកចាំជួយលើកទឹកចិត្តដល់កូនគ្រប់ពេលវេលា។ ដើម្បីឱ្យកូនបានចេះដឹងបានបញ្ជូនកូនឱ្យទៅរៀននៅសាលារៀនតាំងពីថ្នាក់កុមារដ្ឋាន បន្តរហូតមកដល់ថ្នាក់ឧត្តមសិក្សា។ គុណានុបការៈលោកដ៏ធំធេងនេះ ពិតជាមិនអាចយកអ្វីមកប្រៀបផ្ទឹមបានឡើយ។

ឯកឧត្តមសាកលវិទ្យាការ លោក លោកស្រី សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានការិយាល័យសិក្សា និងបណ្ឌិតសាស្ត្រាចារ្យគ្រប់មុខវិជ្ជាទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយកម្លាំងចិត្តក្នុងការអប់រំបង្ហាត់បង្រៀន និងបានផ្តល់ចំណេះដឹងដល់យើងខ្ញុំ ព្រមទាំងនិស្សិតដទៃទៀតតាំងពីថ្នាក់មូលដ្ឋាន រហូតដល់ថ្នាក់បញ្ចប់បរិញ្ញាបត្រ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ លោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ពណ្ណ** ជាសាស្ត្រចារ្យដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃ បង្ហាត់បង្រៀន និង ដឹកនាំ ត្រួតពិនិត្យ កែតម្រូវ ដល់យើងខ្ញុំព្រមទាំងបញ្ចេញគំនិតសម្រាប់ការច្នៃប្រឌិតបន្ថែមទៀតក្នុងកិច្ចការស្រាវជ្រាវនេះតាំងពីដំណើរការចាប់ផ្តើមរហូតដល់របាយការណ៍មួយចងក្រងប្រកបដោយជោគជ័យ។

ឯកឧត្តម លោក លោកស្រី ជាមន្ត្រីរដ្ឋបាលអគ្គនាយដ្ឋានកសិកម្ម នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ខេត្តតាកែវ ដែលបានជួយសម្របសម្រួល ផ្តល់ជាឯកសារមួយចំនួន និងអនុសាសន៍ដ៏មានតម្លៃដល់យើងខ្ញុំក្នុងអំឡុងពេលចុះកម្មសិក្សាស្រាវជ្រាវ ។

សូមថ្លែងអំណរគុណដល់លោក **មេន មីន** ជាប្រធានក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្ម ភ្នំដិន សែនសុខ សមាជិកសហគមន៍កសិកម្ម ប្រជាពលរដ្ឋក្នុងសហគមន៍ និងលោកមេឃុំ មេភូមិ ដែលបានចំណាយពេលវេលាដ៏មានតម្លៃដល់ពួកយើងខ្ញុំក្នុងការធ្វើបទសម្ភាសន៍ និងបានផ្តល់ជាព័ត៌មានលម្អិត ឯកសារពាក់ព័ន្ធទៅនឹងការអភិវឌ្ឍសហគមន៍កសិកម្ម ភ្នំដិនសែនសុខ។

ជាចុងក្រោយយើងខ្ញុំសូមគោរពជូនពរដល់អ្នកមានគុណទាំងទ្វេ ឯកឧត្តមសាកលវិទ្យាការ សាកលវិទ្យាការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកសាស្ត្រាចារ្យគ្រប់មុខវិជ្ជាទាំងអស់ ព្រមទាំងមិត្តនិស្សិតគ្រប់រូប សូមទទួលបាននូវសេចក្តីសុខ សុខភាពបរិបូរណ៍ ទទួលជោគជ័យគ្រប់ភារកិច្ច និងជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងនាមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានសិក្សាលើថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ យើងខ្ញុំបានសិក្សាស្វែងយល់អំពីមេរៀន ទ្រឹស្តី និងការស្រាវជ្រាវជាច្រើនដែលបានឆ្លុះបញ្ចាំងពីការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ជាពិសេសដោយមើលឃើញពីការអភិវឌ្ឍនៅតាមសហគមន៍ជាផ្នែកមួយក្នុងសង្គម ហើយក៏ជាបញ្ហាសំខាន់សម្រាប់ការអភិវឌ្ឍប្រទេសផងដែរនោះ ទើបយើងខ្ញុំបានធ្វើការចុះសិក្សាស្រាវជ្រាវ និងរៀបចំចងក្រងជារបាយការណ៍កម្មសិក្សាមួយស្តីពី "**ការអភិវឌ្ឍវិស័យកសិកម្មរបស់សហគមន៍កសិកម្ម ត្នំដិនសែនសុខ**" ។

ចំពោះកម្រងឯកសារស្រាវជ្រាវដែលអ្នកកំពុងកាន់នឹងដៃនេះ ជាសមិទ្ធផលមួយដែលឆ្លងកាត់ការស្រាវជ្រាវពីសំណាក់ឯកសារស្រាវជ្រាវ ពីសំណាក់កម្រងឯកសារជាច្រើន រួមនឹងការតម្រែតម្រង់ទិសពីសំណាក់លោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ពហុ** ដែលបានផ្តល់នូវគំនិតសំខាន់ៗដែលជាគន្លឹះនៃការស្រាវជ្រាវប្រធានបទនេះផងដែរ។ ចំពោះការសិក្សាស្រាវជ្រាវពីប្រធានបទខាងលើ បានផ្តល់នូវចំណេះដឹងបន្ថែមដល់យើងខ្ញុំ និងយល់កាន់តែច្បាស់អំពីដំណើរការនៃការអភិវឌ្ឍរបស់សហគមន៍ យល់ដឹងអំពីបញ្ហាប្រឈម និងដំណោះស្រាយល្អៗដែលមាននៅក្នុងការអភិវឌ្ឍសហគមន៍។យើងខ្ញុំសង្ឃឹមថាការស្រាវជ្រាវមួយនេះ និងអាចចូលរួមចំណែកក្នុងការជួយសម្រួលដល់ស្ថាប័នដែលពាក់ព័ន្ធនឹងការអភិវឌ្ឍនៅតាមសហគមន៍ ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវទាំងឡាយផងដែរ។ យ៉ាងណាមិញ ទោះបីជាក្រុមយើងខ្ញុំ បានព្យាយាមអស់ពីសមត្ថភាពទាំងកម្លាំងកាយកម្លាំងចិត្ត និងពេលវេលា ដើម្បីទទួលបានសមិទ្ធផលមួយនេះឡើងឱ្យបានល្អយ៉ាងណាក៏ដោយ ក៏គង់តែមិនអាចចៀសផុតពីកំហុសឆ្គងទាំងអក្ខរាវិរុទ្ធ ខ្លឹមសារ និងកំហុសឆ្គងផ្សេងៗដោយអចេតនា ដូច្នេះយើងខ្ញុំទាំងអស់គ្នា សូមធ្វើការអភ័យទោសទុកជាមុនដោយអនុគ្រោះនិង រង់ចាំទទួលការនូវផ្តល់មតិយោបល់ក្នុងន័យរិះគន់ដើម្បីស្ថាបនាពីសំណាក់គណៈកម្មការវាយតម្លៃ សាស្ត្រាចារ្យ និស្សិត និង មិត្តអ្នកអានទាំងឡាយ ដោយក្តីសោមនស្សរីករាយបំផុត ដើម្បីឱ្យសៀវភៅមួយនេះកាន់តែល្អប្រសើរឡើងជាងនេះមួយកម្រិតទៀត។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការចំណាយពេលវេលាដ៏មានតម្លៃក្នុងការអានឯកសារនេះ ។ យើងខ្ញុំសូមជូនពរដល់គណៈកម្មការវាយតម្លៃ សាស្ត្រាចារ្យ និងក្រុមគ្រួសារ ជួបប្រទះតែសំណាងល្អ ព្រមទាំងពុទ្ធពរទាំងឡាយ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# មាតិកា

ទំព័រ


បញ្ជីអក្សរកាត់ ........ v

បញ្ជីតារាង ........ vi

បញ្ជីរូបភាព ........ vii

បញ្ជីក្រាហ្វិក ........ viii

បញ្ជីឧបសម្ព័ន្ធ ........ ix


## សេចក្តីផ្តើម


១.លំនាំបញ្ហា ........ ១

២. ចំណោទបញ្ហា ........ ២

៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ ........ ៣

៥. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ........ ៣

៦. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ៤

៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ ........ ៥


## ជំពូកទី១
## ទ្រឹស្តីពាក់ព័ន្ធនឹងការអភិវឌ្ឍសហគមន៍


១.១. និយមន័យ និងទ្រឹស្តីនៃពាក្យគន្លឹះ ........ ៧

១.១.១. និយមន័យការអភិវឌ្ឍ ........ ៧

១.១.២. ទ្រឹស្តីសំខាន់នៃការអភិវឌ្ឍ ........ ៨

១.១.២.១. ទ្រឹស្តីរបស់លោក Walt Whitman Rostow ........ ៩

១.១.២.២. ទ្រឹស្តីគំរូកំណើនរបស់លោក Harrod-Domar ........ ១១

១.១.២.៣. ទ្រឹស្តីរបស់លោក Michael P.Todaro ........ ១២

១.១.២.៤. ទ្រឹស្តីរបស់លោក Francois Peroux ........ ១២

១.១.២.៥. ទ្រឹស្តីរបស់លោក W. Arthur Lewis ........ ១៣

១.១.៣. គោលបំណងនៃការអភិវឌ្ឍ ........ ១៤
១.១.៤. កត្តាដែលជម្រុញឱ្យមានការអភិវឌ្ឍ ........ ១៥
១.១.៥. កត្តាដែលរាំងស្ទះដល់ការអភិវឌ្ឍ ........ ១៧
១.១.៦. ទ្រឹស្ដីជាមូលដ្ឋានជម្រុញការអភិវឌ្ឍវិស័យកសិកម្ម ........ ១៩
១.១.៦.១. និយមន័យកសិកម្ម ........ ១៩
១.១.៦.២. មុខងារកសិកម្មក្នុងការអភិវឌ្ឍ ........ ១៩
១.១.៧. និយមន័យសហគមន៍ ........ ១៩
១.១.៨. និយមន័យការអភិវឌ្ឍសហគមន៍ ........ ២០
១.១.៩. និយមន័យសហគមន៍កសិកម្ម ........ ២១
១.១.១០. ការអភិវឌ្ឍសហគមន៍កសិកម្ម ........ ២៣
១.២. គោលគំនិតនៃការអភិវឌ្ឍសហគមន៍ ........ ២៣
១.២.១. ទស្សនៈវិស័យនៃការអភិវឌ្ឍសហគមន៍ ........ ២៣
១.២.២.គោលការណ៍នៃការអភិវឌ្ឍសហគមន៍ ........ ២៤
១.២.៣.គោលបំណងនៃការអភិវឌ្ឍសហគមន៍ ........ ២៥
១.២.៤. មូលហេតុនៃការអភិវឌ្ឍសហគមន៍ ........ ២៦
១.៣. គោលនយោបាយរបស់រដ្ឋាភិបាលដើម្បីអភិវឌ្ឍន៍សហគមន៍ ........ ២៦
១.៣.១. គោលនយោបាយអភិវឌ្ឍន៍សហគមន៍ ........ ២៧
១.៣.២. ទិសដៅអភិវឌ្ឍន៍ ........ ២៨
១.៣.៣. យុទ្ធសាស្ត្រការអភិវឌ្ឍ ........ ២៩
១.៣.៤. បេសកកម្មរបស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ........ ២៩

## ជំពូកទី២

## ស្ថានភាពទូទៅជុំវិញការអភិវឌ្ឍរបស់សហគមន៍កសិកម្មភ្នំជីនសែនសុខ

២.១. ប្រវត្តិនិងទីតាំងភូមិសាស្ត្ររបស់សហគមន៍ ........ ៣២
២.២. ប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម ........ ៣៣
២.២.១. ប្រជាពលរដ្ឋ ........ ៣៣

២.២.២. មុខរបរ ....................................................................................................................៣៤
២.៣. ទស្សនៈវិស័យ និង គោលបំណងរបស់សហគមន៍កសិកម្ម .................................................៣៤
២.៣.១. ទស្សនៈវិស័យ.....................................................................................................៣៤
២.៣.២. គោលបំណងរបស់សហគមន៍កសិកម្ម ........................................................................ ៣៤
២.៣.៣. សកម្មភាពរបស់សហគមន៍ ....................................................................................៣៦
២.៣.៤. ឈ្មោះ និងស្លាកសញ្ញារបស់សហគមន៍ ....................................................................៣៧
២.៤. រចនាសម្ព័ន្ធ ការបែងចែក សិទ្ធិ និង តួនាទីភារកិច្ច ...........................................................៣៨
២.៤.១. រចនាសម្ព័ន្ធសហគមន៍កសិកម្ម ..............................................................................៣៨
២.៤.២. ការបែកចែកសិទ្ធិ តួនាទីភារកិច្ច.............................................................................៣៩
២.៥. លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍កសិកម្មភ្នំដិន សែនសុខ.............................. ៤៨
២.៥.១. លក្ខន្តិកៈក្នុងការចូលជាសមាជិកសហគមន៍កសិកម្ម .................................................. ៤៨
២.៥.២. បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍កសិកម្មភ្នំដិន សែនសុខ............................................. ៥០
២.៦. ទីតាំងសហគមន៍កសិកម្មភ្នំដិន សែនសុខ និង ធនធានដែលមាននៅក្នុងឃុំភ្នំដិន.......................៥២
២.៦.១. ទីតាំង...............................................................................................................៥២
២.៦.២. ការកំណត់ព្រំប្រទល់ និងប្រព័ន្ធគមនាគមន៍..............................................................៥៣
២.៦.៣. ដែនស្រោចស្រព ................................................................................................៥៣
២.៧.ការធ្វើផែនការអភិវឌ្ឍន៍របស់សហគមន៍កសិកម្ម ...............................................................៥៣
២.៧.១.ការធ្វើផែនការគ្រប់គ្រងសហគមន៍ ...........................................................................៥៣
២.៧.១.១.ការកំណត់បញ្ហា ..........................................................................................៥៣
២.៧.១.២. ការកសាងផែនការ...................................................................................... ៥៤
២.៧.១.៣. យុទ្ធសាស្ត្រអនុវត្តផែនការ .......................................................................... ៥៤
២.៧.១.៤. ការគ្រប់គ្រងហិរញ្ញវត្ថុសហគមន៍ និង បញ្ជីឯកសារ.............................................. ៥៥
២.៧.២. ផែនការគ្រប់គ្រង និងសកម្មភាពសំខាន់ៗរបស់សហគមន៍កសិកម្ម....................................៥៧
២.៧.២.១. សកម្មភាពសំខាន់ៗរបស់សហគមន៍កសិកម្មឆ្នាំ២០១៤-២០១៩ ..............................៥៧
២.៧.២.២. ផែនការអភិវឌ្ឍន៍សហគមន៍កសិកម្ម.................................................................. ៥៩

២.៧.២.៣. ផែនការអភិវឌ្ឍន៍មុខជំនួញ.............................................................................................................៦២
២.៧.៣. ផែនការយុទ្ធសាស្រ្តសំខាន់ៗសម្រាប់បន្តភាពជោគជ័យ...................................................................................៦៣

# ជំពូកទី៣

# ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

៣.១. ការវិភាគលើស្ថានភាពរបស់សហគមន៍កសិកម្មភ្នំដិន សែនសុខ................................................................. ៦៥
៣.១.១. ស្ថានភាពរស់នៅមុនពេលបង្កើតសហគមន៍កសិកម្មភ្នំដិន សែនសុខ.................................................. ៦៥
៣.១.២. ស្ថានភាពរស់នៅក្រោយពេលបង្កើតសហគមន៍កសិកម្ម .................................................................... ៦៦
៣.២. សមិទ្ធផលរបស់សហគមន៍កសិកម្មភ្នំដិនសែនសុខ ............................................................................... ៦៨
៣.៣. បញ្ហាប្រឈមចំពោះការអភិវឌ្ឍសហគមន៍កសិកម្ម.................................................................................. ៦៨
៣.៤. ដំណោះស្រាយចំពោះបញ្ហាប្រឈមនៃការអភិវឌ្ឍសហគមន៍កសិកម្ម ......................................... ៦៩
៣.៥.កាលវិភាគ SWOT .......................................................................................................................៧០
៣.៥.១. ការវិភាគលើចំណុចខ្លាំង...........................................................................................................៧០
៣.៥.២. ការវិភាគលើចំណុចខ្សោយ ......................................................................................................៧១
៣.៥.៣. ឱកាស.................................................................................................................................៧១
៣.៥.៤. ការគំរាមកំហែង......................................................................................................................៧១

# សេចក្តីសន្និដ្ឋាននិងការផ្តល់អនុសាសន៍

១.សេចក្តីសន្និដ្ឋាន ................................................................................................................................ ៧២
២. ការផ្តល់អនុសាសន៍ .......................................................................................................................... ៧៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- ❖ K ៖ Capital
- ❖ ម ៖ ខ្នាតប្រវែងគិតជាម៉ែត្រ
- ❖ % ៖ ភាគរយ
- ❖ GDP ៖ Gross Domestic Product
- ❖ CWDCC ៖ Children and Woman Development Center in Cambodia
- ❖ FACT ៖ Fishery Action Coalition Team
- ❖ NGOs ៖ Non-government Organizations
- ❖ JICA ៖ Japan International Cooperation Agency

# បញ្ជីតារាង

តារាង ២.១ សមិទ្ធផលពីមុខរបរឥណទាន ....................................................................................៥៧
តារាង ២.២ សមិទ្ធផលបានពីមុខរបរផ្គត់ផ្គង់....................................................................................៥៨
តារាង ២.៣  ផែនការការងាររដ្ឋបាល....................................................................................៥៩
តារាង ២.៤ ផែនការរចនាសម្ព័ន្ធ....................................................................................៦០
តារាង ២.៥ ផែនការសកម្មភាពអប់រំ....................................................................................៦១
តារាង ២.៦ ផែនការទ្រព្យសកម្មអចល័ត....................................................................................៦១
តារាង ២.៧ ផែនការមុខរបរឥណទាន ....................................................................................៦២

# បញ្ជីរូបភាព


រូបភាពទី ១ ៖ ឈ្មោះ និងស្លាកសញ្ញារបស់សហគមន៍កសិកម្មភ្នំដិនសែនសុខ ................................... ៣៧

រូបភាពទី ២ ៖ រចនាសម្ព័ន្ធគណៈកម្មាធិការសហគមន៍កសិកម្មភ្នំដិន សែនសុខ ....................................៣៨

រូបភាពទី ៣ ៖ ផែនទីរបស់សហគមន៍កសិកម្មភ្នំដិន សែនសុខ..........................................................៥២

រូបភាពទី ៤៖ ការសម្ភាសន៍ជាមួយប្រធានក្រុមប្រឹក្សាភិបាលសហគន៍កសិកម្មភ្នំដិន សែនសុខ ............... ៥៤

# បញ្ជីក្រាហ្វិក

ក្រាហ្វិក ៣.១ បង្ហាញពីស្ថានភាពរស់នៅក្រោយពេលបង្កើតសហគមន៍កសិកម្មភ្នំដិន សែនសុខ ............. ៦៦

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ បញ្ជីសំណួរពាក់ព័ន្ធនឹងការស្រាវជ្រាវ

ឧបសម្ព័ន្ធទី២ ៖ តារាងស្ថិតិចំនួនប្រជាពលរដ្ឋប្រែប្រួលប្រចាំឆ្នាំ

ឧបសម្ព័ន្ធទី៣ ៖ ពាក្យសុំចូលជាសមាជិកសហគមន៍កសិកម្ម

ឧបសម្ព័ន្ធទី៤ ៖ សកម្មភាពសម្ភាសន៍ជាមួយប្រធានក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្ម

ឧបសម្ព័ន្ធទី៥ ៖ សកម្មភាពចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាល

ឧបសម្ព័ន្ធទី៦ ៖ វិញ្ញាបនបត្ររបស់សហគមន៍

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

ព្រះរាជាណាចក្រកម្ពុជា ត្រូវបានគេចាត់ទុកថាអន់ថយផ្នែកសេដ្ឋកិច្ចដែលជាប្រទេសកំពុងអភិវឌ្ឍន៍មានខឿនសេដ្ឋកិច្ចពឹងផ្អែកទៅលើវិស័យកសិកម្មជាចម្បង។ ភាពក្រីក្រនៅក្នុងប្រទេសនេះ គឺកើតឡើងនៅតាមជនបទ ដែលប្រជាជនក្រីក្រភាគច្រើនប្រកបរបរចិញ្ចឹមជីវិតដោយពឹងផ្អែកទៅលើវិស័យកសិកម្ម ហើយអាំងតង់ស៊ីតេនៃភាពក្រីក្រក៏មានខ្ពស់ក្នុងចំណោមកសិករជាងក្នុងចំណោមក្រុមប្រកបរបរផ្សេងទៀត។ ប្រហែលជាង ៨៤% នៃចំនួនប្រជាជន និង ៩០% នៃអ្ន កក្រ រស់នៅតាមតំបន់ដាច់ស្រយាល ហើយការប្រកបរបរកសិកម្មគឺជាប្រភពសំខាន់នៃប្រាក់ចំណូលរបស់ពួកគាត់។ ក្នុងលក្ខខណ្ឌនៃដំណើរវិវឌ្ឍន៍សេដ្ឋកិច្ច សង្គមបែបនេះរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាបាននឹងកំពុងពង្រឹងផ្តោតលើវិស័យកសិកម្ម និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដែលជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការលើកស្ទួយកម្រិតជីវភាពប្រជាពលរដ្ឋ ក៏ដូចជា ការចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឱ្យបានរីកចម្រើនផងដែរ ។

បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានសូចនាករសំខាន់ៗនៃក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច ដោយបានសម្រេចកំណើនសេដ្ឋកិច្ចក្នុងរង្វង់ជាង ៧% ក្នុងមួយឆ្នាំ រក្សាបាននូវអតិផរណាក្នុងរង្វង់៣% ដែលសុទ្ធតែជាចំណុចគន្លឹះសម្រាប់កម្ពុជាបោះជំហានឆ្ពោះទៅមុខក្នុងការលើកកម្ពស់កម្រិតជីវភាព ដើម្បីសម្រេចបាននូវកិច្ចអភិវឌ្ឍន៍មួយប្រកបដោយចីរភាព។ ទន្ទឹមគ្នានេះដែរ ក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានធ្វើកំណែទម្រង់លើវិស័យកសិកម្មដែលផ្តោតលើការលើកកម្ពស់ផលិតភាពកសិកម្ម ជម្រុញ និងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ធ្វើពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដើម្បីបង្កើនការងារ បង្កើនប្រាក់ចំណូលនៅជនបទ ព្រមទាំងធានានូវសន្តិសុខស្បៀងសម្រាប់ប្រជាជនទូទៅ បង្កើនការនាំចេញផលិតផលកសិកម្ម សំដៅលើកកម្ពស់កម្រិតជីវភាពប្រជាកសិកររស់នៅតំបន់ជនបទនិងកាត់បន្ថយភាពក្រីក្រជាចម្បង។ ម្យ៉ាងទៀត យើងក៏ឃើញមាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ត្រូវបានបង្កើតឡើងនៅក្នុងគោលបំណង ដើម្បីលើកកម្ពស់ដល់ការពង្រឹងសមត្ថភាព និងសម្របសម្រួលដល់ដំណើរការសហគមន៍កសិកម្មនៅកម្ពុជាផងដែរ ។

ផ្អែកលើកត្តានេះហើយ ទើបជម្រុញឱ្យរាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ អង្គការក្នុង និងក្រៅប្រទេសបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអភិវឌ្ឍវិស័យកសិកម្ម តាមបែបសហគមន៍នៅក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍ និងធ្វើអោយប្រជាកសិករនៅតាមជនបទបានសិក្សាស្វែងយល់ដឹងពីការធ្វើកសិកម្មតាមបែបទំនើប និងទទួលបានទិន្នផលខ្ពស់។ ជាងនេះទៅទៀតការលើកកម្ពស់ក្នុងការអភិវឌ្ឍសហគមន៏កសិកម្មនេះបាន

ជួយសម្រួលដល់ការរស់នៅរបស់ប្រជាកសិករបានមួយកម្រិតផងដែរ ដោយបានផ្ដល់នូវការកម្ចីប្រាក់សម្រាប់ដំណើរការធ្វើកសិកម្ម ជាពិសេសបានចែករម្លែកនូវបទពិសោធន៍ ព្រមទាំងបច្ចេកទេសប្រតិបត្តិនៅគ្រប់ដំណាក់កាលនៃខ្សែច្រវាក់ផលិតកម្មកសិកម្ម ដែលឆ្លើយតបចំពោះឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុត្រូវបាន នឹងកំពុងជម្រុញឱ្យអនុវត្តយ៉ាងល្អប្រសើរ ប្រកបដោយប្រសិទ្ធភាព និង និរន្តរភាព។

## ២. ចំណោទបញ្ហា

យ៉ាងណាមិញ បើទោះជាមានការយកចិត្តទុកដាក់ទៅលើសហគមន៍កសិកម្មនានា ពីសំណាក់រាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ អង្គការក្នុង និងក្រៅប្រទេសមួយចំនួនយ៉ាងណា ក៏គេឃើញថាការរស់នៅរបស់ប្រជាជននៅតាមតំបន់សហគមន៍កសិកម្មនៅតែមានបញ្ហាមួយចំនួនដោយសារ តែប្រជាកសិករភាគច្រើនជាកសិករក្រីក្រដែលពុំមានថវិកានិងឧបករណ៍គ្រប់គ្រាន់ ក្នុងការប្រកបរបរកសិកម្មដោយខ្លួនឯងផ្ទាល់ កត្តាខ្វះចំណេះជំនាញនិងបច្ចេកទេសនៅក្នុងដំណើរការកសិកម្មបែបទំនើប ជាពិសេសបញ្ហានៃការប្រែប្រួលអាកាសធាតុ។ តាមរយៈបញ្ហាទាំងនេះហើយថា តើមានបញ្ហាប្រឈមអ្វីខ្លះកើតមានឡើងនៅក្នុងកំឡុងដំណើរការអភិវឌ្ឍសហគមន៍កសិកម្មនេះ? តើសហគមន៍កសិកម្មភ្នំជិនសែនសុខមានការដោះស្រាយ និងអភិវឌ្ឍន៍សហគមន៍យ៉ាងដូចម្ដេចខ្លះ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងដូចជាៈ

- ❖ សិក្សាពីទ្រឹស្ដីពាក់ព័ន្ធនឹងការអភិវឌ្ឍសហគមន៍
- ❖ សិក្សា និងស្វែងយល់អំពីស្ថានភាពទូទៅ និងដំណើរការនៃការអភិវឌ្ឍសហគមន៍
- ❖ សិក្សា និងស្វែងយល់អំពីការធ្វើផែនការ និងយុទ្ធសាស្ត្រដែលសហគមន៍កសិកម្មរៀបចំឡើងនៅក្នុងការអភិវឌ្ឍសហគមន៍
- ❖ ស្វែងយល់អំពីបញ្ហាប្រឈមដែលសហគមន៍ជួបប្រទះ និងវិធីសាស្ត្រក្នុងការដោះស្រាយតាមការយុទ្ធសាស្ត្រការអភិវឌ្ឍសហគមន៍កសិកម្ម ភ្នំជិនសែនសុខ
- ❖ សិក្សាឡើងវិញ និងធ្វើការវិភាគតាមវិធីសាស្ត្រ SWOT
- ❖ សេចក្ដីសន្និដ្ឋាន និងផ្ដល់ជាអនុសាសន៍បន្ថែមសម្រាប់ដំណើរការនៃការអភិវឌ្ឍរបស់សហគមន៍កសិកម្មប្រកបដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តភាព។

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ត្រូវបានធ្វើឡើងស្ថិតនៅក្នុងសហគមន៍កសិកម្ម ភ្នំដិនសែនសុខ ដែលមានទីតាំងនៅ ភូមិ ទទឹង ឃុំ ភ្នំដិន ស្រុក គិរីវង់ ខេត្ត តាកែវ ហើយរបាយការណ៍ដែលបានចងក្រងនេះនឹងសិក្សាអំពី ផែនការ យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍរបស់សហគមន៍កសិកម្ម ភ្នំដិនសែនសុខទាំងមូល។ ចំពោះការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើង ចាប់ពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២០ ដល់ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០២០។ ចំពោះខ្លឹមសាររបាយការណ៍ស្រាវជ្រាវនេះ មានការចងក្រងដោយធ្វើការប្រមូលឯកសារ និងមានការជួបសម្ភាសន៍ផ្ទាល់ជាមួយ ប្រជាពលរដ្ឋ សមាជិកសហគមន៍ ប្រធានប្រឹក្សាភិបាលសហគមន៍កសិកម្ម ភ្នំដិនសែនសុខ និងស្ថាប័នដែលពាក់ព័ន្ធផ្សេងទៀតអំពីស្ថានភាពទូទៅទាក់ទងនឹងការអភិវឌ្ឍនៅក្នុងសហគមន៍មួយនេះផងដែរ។ លើសពីនេះទៅទៀត ការសិក្សាស្រាវជ្រាវនេះក៏អាចជាស្ពានចម្លងក្នុងការជួយដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗទៀត និងជាមូលដ្ឋានជំនួយស្មារតីអោយយល់ដឹងពីការអភិវឌ្ឍរបស់សហគមន៍កសិកម្ម ភ្នំដិនសែនសុខដល់ប្អូនៗជំនាន់ក្រោយផងដែរ។

## ៥. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវនេះ យើងបានប្រើប្រាស់ទិន្នន័យចំនួនពីរប្រភេទដើម្បីកំណត់វិធីសាស្ត្រស្រាវជ្រាវគឺ ទិន្នន័យបឋម (Primary Data) និងទិន្នន័យបន្ទាប់បន្សំ (Second Data)ដែលធ្វើឡើងតាមរបៀបពិពណ៌នាពន្យល់ ប្រើស្ថិតិពិពណ៌នាសម្រាប់ជាជំនួយក្នុងការបកស្រាយ និងបញ្ជាក់ឱ្យកាន់តែច្បាស់។

❖ **ទិន្នន័យបឋម (Primary Data)**

- យើងបានបង្កើតជាកម្រងសំណួរដើម្បីឱ្យការប្រមូលទិន្នន័យមានភាពងាយស្រួលនិងចំណាយពេលវេលាតិច។
- ក្រុមយើងបានធ្វើការចុះជួបសម្ភាសន៍ និងប្រជុំដោយផ្ទាល់ជាមួយលោក **មេន ម៉ន** ជាប្រធានក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្ម ភ្នំដិនសែនសុខ។
- ធ្វើការចុះជួបដោយផ្ទាល់ជាមួយសមាជិកសហគមន៍ និងប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ដើម្បីសួរព័ត៌មានផ្សេងៗទាក់ទងនឹងកម្រិតជីវភាព និងការជួបផលលំបាកកំឡុងពេលធ្វើកសិកម្ម។
- ការណែនាំពីសាស្ត្រាចារ្យបណ្ឌិត **ឈុន ពហុ** ជាសាស្ត្រាចារ្យបានដឹកនាំ កែតម្រូវ ព្រមទាំងបញ្ចេញគំនិតសម្រាប់ការកែច្នៃប្រឌិតបន្ថែម។

❖ **ទិន្នន័យបន្ទាប់បន្សំ (Secondary Data)**

ទិន្នន័យបន្ទាប់បន្សំគឺសំដៅលើប្រភេទទិន្នន័យស្រាវជ្រាវ ដែលបានប្រមូលតាមរយៈសៀវភៅឯកសារផ្សេងៗជាច្រើនដូចជា៖

- ➢ សៀវភៅសារណា របាយការណ៍បញ្ចប់ការសិក្សា នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច
- ➢ ឯកសារបណ្ណាល័យ និង ឯកសារដែលទាញយកពីអ៊ីនធើណេត
- ➢ ឯកសាររបាយការណ៍បូកសរុបប្រចាំឆ្នាំ របស់ក្រសួងកសិកម្មនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម
- ➢ ឯកសារផែនការយុទ្ធសាស្រ្ត និងទិន្នន័យដែលបានមកពីការិយាល័យសហគមន៍កសិកម្មភ្នំដិនសែនសុខ។

## ៦. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

តាមរយៈការសិក្សាស្រាវជ្រាវនេះ បានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដូចជា៖

- ❖ ផ្តល់នូវបទពិសោធន៍ និងចំណេះដឹងនៅក្នុងការស្វែងយល់អំពីការអភិវឌ្ឍរបស់សហគមន៍កសិកម្ម
- ❖ ពង្រីកនូវចំណេះដឹងបន្ថែមដែលបានសិក្សាកន្លងមក និងទ្រឹស្តីដែលទាក់ទងនឹងការអភិវឌ្ឍ
- ❖ ទទួលបាននូវចំណេះដឹងថ្មីៗ ការពន្យល់ណែនាំពីលោកសាស្រ្តាចារ្យពីរបៀបប្រមូលទិន្នន័យ ចងក្រង និងចេះធ្វើការវិភាគអំពីព័ត៌មានដែលត្រូវសិក្សា
- ❖ ផ្តល់ជាគន្លឹះនិងអត្ថប្រយោជន៍ដល់សង្គមជាតិ តាមរយៈការជម្រុញដល់ការអភិវឌ្ឍសហគមន៍នៅតាមទីជនបទ
- ❖ លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ នឹងត្រូវបានរក្សាទុកសម្រាប់ធ្វើជាឯកសារ ជាស្ពានជំនួយស្មារតីដល់ស្វែងយល់ពីការអភិវឌ្ឍសហគមន៍កសិកម្មសម្រាប់ជូនដល់និស្សិតនានា និងអ្នកសិក្សាជំនាន់ក្រោយៗទៀត
- ❖ ជាពិសេសផងដែរ របាយការណ៍ដែលបានសិក្សាស្រាវជ្រាវនេះ ក៏អាចជួយផ្សព្វផ្សាយពីកេរ្តិ៍ឈ្មោះរបស់សហគមន៍កសិកម្មភ្នំដិនសែនសុខ ហើយអាចជួយទាក់ទាញដល់មូលនិធិសម្រាប់ធ្វើការអភិវឌ្ឍន៍ពីអង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវ ចងក្រងឯកសារនៃប្រធានបទ "ការអភិវឌ្ឍវិស័យកសិកម្មរបស់សហគមន៍កសិកម្ម ភ្នំជិនសែនសុខ" យើងខ្ញុំបានធ្វើការបែងចែកប្រធាននេះជាប្រាំផ្នែកសំខាន់ៗ ដែលរួមមាន៖

- **សេចក្តីផ្តើម** គឺជាចំណុចចាប់ផ្តើមនៃប្រធានបទ ដែលនឹងធ្វើការសិក្សាលើផ្នែកមួយចំនួន ដូចជា ស្ថានភាពទូទៅ មូលហេតុនៃការសិក្សា គោលបំណងនៃការសិក្សា ទំហំ និង ដែនកំណត់ វិធីសាស្ត្រស្រាវជ្រាវ ដែលផ្តោតសំខាន់លើការអភិវឌ្ឍវិស័យកសិកម្ម និងសិក្សាពីបញ្ហាប្រឈមដើម្បីឈានទៅរកដំណោះស្រាយសមស្របមួយ។
- **ជំពូកទី១** ទ្រឹស្តីពាក់ព័ន្ធនឹងការអភិវឌ្ឍសហគមន៍ គឺជាការសិក្សាទៅលើទ្រឹស្តី ទស្សនៈផ្សេងៗ ដែលស្តីពីការអភិវឌ្ឍទាក់ទងសហគមន៍កសិកម្ម ដោយយកនូវទស្សនៈការអភិវឌ្ឍរបស់សេដ្ឋវិទូមួយចំនួនមកបកស្រាយពន្យល់។ លើសពីនេះទៅទៀត យើងនឹងធ្វើការបង្ហាញ បកស្រាយពន្យល់អំពីប្រវត្តិ គោលការណ៍មួយចំនួនរបស់សហគមន៍ ព្រមទាំងបង្ហាញអំពីលទ្ធផលទទួលបានពីការអភិវឌ្ឍសហគមន៍តាមរយៈទ្រឹស្តី។
- **ជំពូកទី២** ស្ថានភាពទូទៅជុំវិញការអភិវឌ្ឍវិស័យកសិកម្មរបស់សហគមន៍កសិកម្ម គឺយើងបានធ្វើការសិក្សាស្រាវជ្រាវទាក់ទងនឹងស្ថានភាពទូទៅ ការអភិវឌ្ឍរបស់សហគមន៍កសិកម្ម ភ្នំជិនសែនសុខ ដែលរៀបរាប់អំពីទីតាំងភូមិសាស្ត្រ ស្ថានភាពប្រជាសាស្ត្រ មុខរបររបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍។ បន្ថែមពីនេះទៀត យើងនឹងបង្ហាញអំពីការអភិវឌ្ឍទៅលើវិស័យការងារកម្រិតចំណេះដឹង ការចូលរួមចំណែកពីប្រជាកសិករនៅក្នុងសហគមន៍ ទស្សនៈវិស័យ គោលបំណងក្នុងការរៀបចំផែនការគ្រប់គ្រងសម្រាប់ការអភិវឌ្ឍរបស់សហគមន៍កសិកម្ម។
- **ជំពូកទី៣** ការវិភាគ និងបកស្រាយពីលទ្ធផលនៃការសិក្សាស្រាវជ្រាវដែលមាននៅក្នុងសហគមន៍កសិកម្ម ភ្នំជិនសែនសុខ។ នៅក្នុងជំពូកនេះ យើងនឹងធ្វើការបកស្រាយ រៀបរាប់អំពីបញ្ហាដែលប្រជាពលរដ្ឋនៅក្នុងសហគមន៍កំពុងជួបប្រទះ នៅមុនពេលបង្កើតសហគមន៍កសិកម្ម និងក្រោយពេលបង្កើតសហគមន៍នេះ។ ជាងនេះទៅទៀត យើងនឹងធ្វើការរៀបរាប់បន្ថែមពីសមិទ្ធផលដែលទទួលបានរបស់សហគមន៍កសិកម្ម បទពិសោធន៍ក្នុងការគ្រប់គ្រង បញ្ហាប្រឈមនានាដែលកើតមានឡើងនៅក្នុងដំណើរការរបស់សហគមន៍ ព្រមទាំងបង្ហាញពីវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហារបស់សហគមន៍កសិកម្ម ភ្នំជិនសែនសុខ។ ជាពិសេស នៅក្នុងចំណុច

សំខាន់ចុងក្រោយនេះ គឺជាការវិភាគអំពីចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងកត្តាគំរាមកំហែងនៅក្នុងសហគមន៍កសិកម្ម ភ្នំដិនសែនសុខ។

- **សេចក្ដីសន្និដ្ឋាន និង ការផ្ដល់អនុសាសន៍** ជាចំណុចចុងក្រោយបង្អស់ ដែលធ្វើការសង្ខេបប្រធានបទ ឡើងវិញ និងមិនត្រឹមតែប៉ុណ្ណោះថែមទាំងបានផ្ដល់អនុសាសន៍ដល់ប្រធានបទថែមទៀតផង។

# ជំពូកទី១

# ទ្រឹស្តីពាក់ព័ន្ធនឹង ការអភិវឌ្ឍសហគមន៍

## ១.១. និយមន័យ និងទ្រឹស្តីនៃពាក្យគន្លឹះ

### ១.១.១ និយមន័យការអភិវឌ្ឍ

**ការអភិវឌ្ឍ** គឺជាដំណើរការនៃការធ្វើអោយប្រសើរឡើងនូវគុណភាពជីវិតក្នុងការរស់នៅ និងសមត្ថភាពរបស់មនុស្សទាំងអស់ ដោយតាមរយៈការបង្កើននូវកម្រិតជីវភាពរស់នៅរបស់ប្រជាជន ការគោរព ការឱ្យតម្លៃ ការជឿទុកចិត្តលើខ្លួនឯង និងសេរីភាពរបស់មនុស្ស។[1]

**អភិវឌ្ឍន៍** គឺសំដៅលើចលនាវិវត្តពីស្ថានភាពមួយទៅស្ថានភាពមួយទៀតដែលល្អប្រសើរជាងមុន។[2]

**ការអភិវឌ្ឍ** គឺជាដំណើរការមួយគំរូសមាជិកទាំងអស់នៃសង្គមបង្កើនសមត្ថភាពផ្ទាល់ខ្លួនរបស់គេ និងសមត្ថភាពនៃការចាត់តាំង ឬ ការអនុវត្ត ដើម្បីបង្រួបបង្រួម និងការប្រើប្រាស់ធនធានធម្មជាតិសម្រាប់ធ្វើឱ្យផលិតផលមាន លំនឹង ឬស្ថេរភាព ព្រមទាំងធ្វើឱ្យការរស់នៅរបស់គេមានលក្ខណៈល្អប្រសើរហើយសមស្របទៅនឹងសេចក្តីប្រាថ្នារបស់គេ ។ ការកំណត់នេះគេមិនប្រៀបធៀប ការអភិវឌ្ឍទៅនឹងឧស្សាហាតូបនីយកម្ម ឬក៏ការបង្កើនទិន្នផលសេដ្ឋកិច្ចនោះទេ ការកំណត់នេះបញ្ជាក់ពីដំណើរអភិវឌ្ឍន៍ និងការចាំបាច់របស់វា គឺផ្តោតទៅលើសមត្ថភាពផ្ទាល់ខ្លួន និងសមត្ថភាពក្រុមរបស់ពួកគាត់ ហើយគេបានទទួលស្គាល់ថាមានតែប្រជាជនខ្លួនឯងផ្ទាល់ទេ ដែលអាចកំណត់ឱ្យបានច្បាស់លាស់នូវអ្វី ដែលគេយល់ឃើញថាចាំបាច់ហើយអាចធ្វើឱ្យបានប្រសើរឡើងក្នុងជីវភាពរស់នៅរបស់គេ។[3]

**ការអភិវឌ្ឍ** ជាដំណើរការនៃការប្រែក្លាយរចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងស្ថាប័នដែលបង្កលក្ខណៈងាយស្រួល ឬអំណោយផលដល់ការធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើននិងធ្វើឱ្យកំណើនសេដ្ឋកិច្ចអាចបន្តបានយូរ ឬអាចនិយាយបានម្យ៉ាងទៀត ការអភិវឌ្ឍជាការបង្កលក្ខខណ្ឌឱ្យកំណើនសេដ្ឋកិច្ចមានចីរភាព។[4]

ដូច្នេះយោងតាមអត្ថន័យយើងអាចឆ្លុះបញ្ចាំងពីដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ចគឺជាចលនាវិវត្ត ឬការកែប្រែសេដ្ឋកិច្ចសង្គមឱ្យមានភាពជឿនលឿន ពីស្ថានភាពមួយទៅស្ថានភាពមួយទៀតដែលល្អប្រសើរនិងរីកចម្រើនជាងមុន។

---

[1] Economic Development 12th Edition , Michael P. Todaro and Stephen C. Smith 2009

[2] *សៀវភៅ សេដ្ឋកិច្ចអភិវឌ្ឍន៍* ភាគទី២, រៀបរៀងដោយ សាស្ត្រាចារ្យ យែម សំបូ (បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤)

[3] *សៀវភៅ សេចក្តីផ្តើមនៃការអភិវឌ្ឍជនបទ*, ចងក្រងដោយ អង្គការ ស៊ីដសេ CIDSE, ទំព័រទី២

[4] និស្សិតៈ ឡៃ ប៉ូរ៉ាពីន, សៀវភៅសារណាបញ្ចប់ការសិក្សា *"ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា"*,ទំព័រទី៦

ក្នុងន័យសេដ្ឋកិច្ចវិញ ការអភិវឌ្ឍគឺ ទាក់ទងទៅនឹងការកែលម្អក្នុងស្ថានភាពសេដ្ឋកិច្ចរបស់មនុស្ស គុណភាពរស់នៅល្អប្រសើរជាងមុន អត្រាកំណើននៃចំណូលក្នុងម្នាក់ៗ ឬផលិតផលជាតិក្នុងពលរដ្ឋម្នាក់ៗ ក៏ដូចជានៅក្នុងប្រទេសទាំងមូល។ ការអភិវឌ្ឍត្រូវបានលើកឡើងក្នុងទម្រង់កាត់បន្ថយ និងលុបបំបាត់នូវភាពក្រីក្រ វិសមភាព និងនិកម្មភាពជាដើម។

ការអភិវឌ្ឍអាចស្តែងចេញតាមមាត្រដ្ឋានចំនួន ៥គឺៈ

**១. មាត្រដ្ឋានសេដ្ឋកិច្ចៈ** ការអភិវឌ្ឍ គឺជាកំណើនសេដ្ឋកិច្ចដែលត្រូវផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច ដោយកែលម្អនិងពង្រីកប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធថាមពល ប្រព័ន្ធផ្គត់ផ្គង់ទឹក ការពង្រីកវិស័យកសិកម្ម ឧស្សាហកម្ម ទេសចរណ៍និងសេវាកម្មផ្សេងៗទៀត។

**២. មាត្រដ្ឋានសង្គមៈ** ការអភិវឌ្ឍ ជាការផ្លាស់ប្តូរផ្នែកសង្គមកិច្ចដូចជា សមធម៌ និងយុត្តិធម៌តាមរយៈការកាត់បន្ថយភាពក្រីក្រដោយធ្វើយ៉ាងណាអោយគម្លាតរវាងអ្នកមាន និងអ្នកក្រសមល្មមអាចទទួលយកបាន លើកតម្កើននារីភេទ ជាពិសេសនោះបានធានានូវសមភាពយេនឌ័រ រវាងបុរសនិងស្ត្រីក្នុងសង្គម។

**៣. មាត្រដ្ឋាននយោបាយៈ** ការអភិវឌ្ឍត្រូវស្ថិតនៅក្នុង បរិស្ថាននយោបាយសមស្របសម្រាប់ជម្រុញវឌ្ឍនភាពសង្គមតាមច្បាប់ និងធានានូវការគោរពសិទ្ធិមនុស្ស។

**៤. មាត្រដ្ឋានបរិស្ថានៈ** ការអភិវឌ្ឍត្រូវស្ថិតនៅក្នុងក្របខណ្ឌនៃការយកចិត្តទុកដាក់ ថែរក្សាតុល្យភាពបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឱ្យបានឋិតថេរ។

**៥. មាត្រដ្ឋានធនធានមនុស្សៈ** ការអភិវឌ្ឍ ផ្សារភ្ជាប់ទៅនឹងការកើនឡើងនៃផលិតភាពពលកម្ម និងកម្រិតចំណេះដឹងរបស់ប្រជាជន ការផ្លាស់ប្តូរបទពិសោធន៍ និងបច្ចេកទេសការផ្តល់សេវាសុខភាពសាធារណៈនិងការអប់រំសម្រាប់ប្រជាជនទូទៅ។[5]

## ១.១.២. ទ្រឹស្តីសំខាន់នៃការអភិវឌ្ឍ

ពាក្យថា **អភិវឌ្ឍន៍** គឺជាពាក្យមួយដែលមានខ្លឹមសារ អត្ថន័យយ៉ាងទូលំទូលាយ ហើយមានទ្រឹស្តីនិងទស្សនៈជាច្រើនដែលត្រូវបានបង្កើតឡើងដោយអ្នកប្រាជ្ញសេដ្ឋកិច្ចដើម្បីពន្យល់បកស្រាយអំពី ការផ្លាស់ប្តូរដែលកើតមានឡើងនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍក្នុងគោលបំណង ដើម្បីសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ចនិងកំណើនទាំងមូល ហើយអត្ថន័យនៃពាក្យអភិវឌ្ឍន៍ត្រូវបានផ្លាស់ប្តូរទៅតាមសម័យកាលនីមួយៗ តាមទស្សនៈយល់ឃើញ របស់អ្នកប្រាជ្ញនីមួយៗ ។ ដើម្បីយល់ឱ្យកាន់តែច្បាស់លាស់ និងស៊ីជម្រៅ

[5] សារណាបញ្ចប់ការសិក្សា, *កម្មវិធីអភិវឌ្ឍន៍របស់ឃុំឆ្លូង ខេត្តក្រចេះ*, ឆ្នាំ២០០២ - ២០០៦

អំពីអត្ថន័យរបស់ពាក្យ **អភិវឌ្ឍន៍** យើងខ្ញុំសូមលើកយកទ្រឹស្តីសំខាន់ៗមួយចំនួនរបស់អ្នកប្រាជ្ញនីមួយៗមកពន្យល់ និងបកស្រាយដូចខាងក្រោម ៖

**១.១.២.១. ទ្រឹស្តីរបស់លោក Walt Whitman Rostow**

បើយើងតាមទស្សនៈរបស់លោក Walt W.Rostow បានបង្ហាញថា អភិវឌ្ឍន៍ គឺសំដៅទៅលើទំនាក់ទំនងនិងបំលាស់ប្តូរពីជីវិតរស់នៅបែបប្រពៃណី ទៅកាន់ជីវិតរស់នៅមួយបែបទំនើប ដែលមានរបៀបរៀបរយល្អនិងអាចទស្សន៍ទាយជាមុននូវលទ្ធផលដែលគេនឹងទទួលបាននៅពេលអនាគត។ លើសពីនេះទៅទៀតលើក៏បានលើកឡើងផងដែរថា ការអភិវឌ្ឍ គឺទាក់ទងទៅនឹងកាផ្លាស់ប្តូរផលិតកម្មកសិកម្មបែបប្រពៃណី ទៅកាន់ផលិតកម្មដែលមានលក្ខណៈបែបវិទ្យាសាស្ត្រទំនើប ដែលជាទូទៅត្រូវបានគេយកចិត្តទុកដាក់ខ្លាំងទៅលើផ្នែកឧស្សាហកម្ម។[6] លោក Walt W.Rostow បានធ្វើការវែកញែកអំពីដំណាក់កាលសំខាន់ៗក្នុងការអភិវឌ្ឍជាប្រាំដំណាក់កាល ដោយលោកបានអះអាងថា គ្រប់ប្រជាជាតិទាំងអស់អាចឈានទៅរកកម្រិតនៃការអភិវឌ្ឍ ប្រសិនបើគេដើរតាមគន្លងប្រទេសអភិវឌ្ឍន៍ ហើយរក្សានូវលក្ខខណ្ឌក្នុងការធានាឱ្យមានកំណើនសេដ្ឋកិច្ចបានយូរអង្វែងនិងជានិរន្តរ៍។ ទ្រឹស្តីនេះបានបែកចែកជា ៥ ដំណាក់កាលក្នុងការអភិវឌ្ឍជាតិរួមមាន ៖

**ក.សង្គមប្រពៃណី**

សង្គមប្រពៃណី ជាសង្គមមួយដែលមានប្រភពចំណូលចម្បងតែមួយគត់គឺការធ្វើកសិកម្ម (កសិកម្មលក្ខណៈគ្រួសារ) លទ្ធភាពក្នុងការជម្រុញឱ្យមានការកែប្រែសង្គម និងកំណើនផលិតកម្មស្មើសូន្យដែលធ្វើឱ្យកម្រិតជីវភាពទាប ហើយប្រជាជនមិនមានផ្នត់គំនិតផ្លាស់ប្តូរ ខ្វះការយល់ដឹង មានការរើសអើងក្នុងសង្គម ជាពិសេសគឺធ្វើកសិកម្មដោយពឹងផ្អែកលើទឹកភ្លៀងនិង បណ្តោយតាមយថាកម្ម មានន័យថាជាប្រទេសមួយដែលមានការរីកចម្រើនតិចតួចបំផុត។

**ខ.សង្គមដែលមានលក្ខណៈរបត់ទៅរកការអភិវឌ្ឍ**

សំដៅលើសង្គមដែលមានការធ្វើបដិវត្តនៅក្នុងផ្នត់គំនិត (បំលាស់ប្តូរទំនាក់ទំនងក្នុងការផលិត) មានការចូលរួមចំណែកពីធាតុសំខាន់ៗផ្សេងទៀត និងមានការកើនឡើងផ្នែកវិនិយោគ មានន័យថា ជាប្រទេសដែលស្ថិតនៅក្នុងចន្លោះអន្តរកាលនៃការអភិវឌ្ឍ។ ចំណុចដែលអាចឈានរកការអភិវឌ្ឍ រួមមានធាតុសំខាន់ៗដូចជា៖

[6] សារណាបញ្ចប់កាសិក្សា *ការលើកកម្ពស់ជីវភាពគ្រួសារតាមរយៈការដាំបន្លែ*, និស្សិត៖ អិន សុគា និង ឡាញ់ស្រីនាថ

- ការពង្រីកហេដ្ឋារចនាសម្ព័ន្ធអោយបានល្អប្រសើរ
- ការធ្វើឱ្យប្រសើរឡើងផ្នែកបច្ចេកវិទ្យា ( ជម្រុញកំណើនផលិតលើវិស័យកសិកម្ម)
- ការធ្វើឱ្យប្រជាជនមានភាពជាម្ចាស់កម្មសិទ្ធលើអចលនវត្ថុ ព្រមទាំងធ្វើឱ្យកើនឡើងនៃការសន្សំ វិនិយោគ ។

**គ. ដំណាក់កាលនៃការចាប់ផ្តើមអភិវឌ្ឍ**

- វិស័យអាទិភាពនៃសេដ្ឋកិច្ចបានចាប់កំណើត និងរីកចម្រើនជំធាត់ជាលំដាប់
- កំណើនសេដ្ឋកិច្ចបានក្លាយទៅជាបញ្ហាសាមញ្ញ
- អាចរក្សាបានដោយស្វ័យប្រវត្តិនូវស្ថេរភាពសេដ្ឋកិច្ច ។

ប្រសិនបើប្រទេសទាំងឡាយណាដែលមានចំណុចដូចខាងលើ គេអាចហៅថាជា ប្រទេសឧស្សាហកម្មថ្មីដោយពឹងផ្អែកលើ ភាពខ្លាំងនៃអត្រាវិនិយោគ អាទិភាពនៃនយោបាយ ស្ថាប័នដែលនាំឱ្យមានការរំកិលនៃកំណើនសេដ្ឋកិច្ច និងការបង្កើតឧស្សាហកម្មសំខាន់ៗដើម្បីជាការផ្លាស់ប្តូរ។

**ឃ.ដំណាក់កាលទុំ**

នៅក្នុងដំណាក់កាលនេះ ការអភិវឌ្ឍបានជ្រាបចូលទៅគ្រប់ច្រកល្ហកនៅទូទាំងប្រទេស ជាពិសេសវិស័យថ្មីៗនៃផលិតកម្មដែលបានលេចឡើងជារចនាសម្ព័ន្ធនៃ ការផលិតបានចេញពីវិស័យកសិកម្មទៅវិស័យឧស្សាហកម្ម ។ ការអភិវឌ្ឍចេះតែឈានទៅមុខ ឧស្សាហកម្មដែលមានវ័យចំណាស់ ត្រូវវាបានផ្លាស់ប្តូរចេញឱ្យមានភាពកាន់តែទំនើបថែមទៀត ឬវិស័យឧស្សាហកម្មថ្មី ។

**ង. ដំណាក់កាលនៃបម្រើបម្រាស់ទ្រង់ទ្រាយធំ**

ការផលិតទំនិញ និងសេវាកម្មក្នុងគោលបំណងប្រើប្រាស់ចុងក្រោយ ត្រូវបានធ្វើនៅក្នុងវិស័យឧស្សាហកម្មនៃផលិតកម្មទំនិញ។ ដោយសារតែចំណូលប្រជាជនមានកើនឡើងបានអនុញ្ញាតដល់ការប្រើប្រាស់ក្នុងទ្រង់ទ្រាយធំនៃទំនិញដែលមិនមានភាពចាំបាច់ត្រង់ចំណុចនេះបញ្ជាក់ថា៖

- ការអភិវឌ្ឍកំពុងតែចាប់ផ្តើមដំណើរការខ្លាំង ដោយសារចំណុចកំណើនតម្រូវការខ្ពស់
- សេចក្តីត្រូវការជាមូលដ្ឋានត្រូវបានដោះស្រាយជាស្ថាពរ
- មានការអភិវឌ្ឍវិស័យសុខាភិបាលសង្គម
- មានការពង្រីកអំណាចសេដ្ឋកិច្ច ។

ប្រទេសដែលមានលក្ខណៈដូចខាងលើគេហៅថា ប្រទេសមហាអំណាចសេដ្ឋកិច្ច ដូច្នេះហើយលោកបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការសាយភាពនៃគ្រឿងយន្ត ដែលមានតម្លៃថោកដែលធ្វើឱ្យមានឥទ្ធិពល

ដល់ជីវិតរស់នៅក្នុងសង្គម កម្រិតជីវភាពមិនស្មើគ្នា ការបែងចែកប្រាក់ចំណូលថ្មី និងការបង្កើតប្រព័ន្ធគ្រោងទុកនៃសង្គម ។[7]

**១.១.២.២. ទ្រឹស្តីគំរូកំណើនរបស់លោក** Harrod-Domar

ដោយយោងតាមគំរូរបស់លោក Harrod-Domar បានលើកឡើងថា គ្រប់បណ្តាសេដ្ឋកិច្ចទាំងអស់ចាំបាច់ត្រូវតែមានការសន្សំដោយសមាមាត្រពិតប្រាកដនិងចំណូលជាតិ ដើម្បីយកទៅចំណាយលើទំនិញមូលធន (Capital Goods) ដែលចាស់ៗ ខូចខាតដែលត្រូវធ្វើការជួសជុលដូចជា អាគារ ឧបករណ៍ សម្ភារៈផ្សេងៗដែលបង់រំលោះ និងគ្រឿងបរិក្ខាជាដើម។

ដើម្បីឱ្យមានកំណើនសេដ្ឋកិច្ច គឺចាំបាច់ត្រូវតែមានការវិនិយោគថ្មីបន្ថែមទៀតទៅលើផ្នែកស្តុកមូលធន (Capital Stock) ។ លោកបានសន្មតថា វាមានទំនាក់ទំនងសេដ្ឋកិច្ចពីរ ដោយផ្ទាល់រវាងទំហំសរុបនៃស្តុកមូលធន (K) និងផលិតផលក្នុងស្រុកសរុប (GDP) នោះមានន័យថា គេនឹងយកមួយភាគរយនៃផលិតផលក្នុងស្រុក ដែលបានតាមរយៈការសន្សំទៅធ្វើការវិនិយោគថ្មី ពោលគឺ យកទៅវិនិយោគលើស្តុកមូលធន ដើម្បីបង្កើននូវទិន្នផល។

គំរូរបស់លោក Harrod-Domar ត្រូវបានចែកចេញជាបីដំណាក់កាល នៅក្នុងការបង្ហាញពីទំនាក់ទំនងនៃកំណើនសេដ្ឋកិច្ចដែលរួមមាន៖

- ទំនាក់ទំនងរវាងការសន្សំ និងចំណូលសរុប
- ទំនាក់ទំនងរវាងការវិនិយោគ និងបម្រែបម្រួលស្តុកមូលធន
- សន្សំជាតិសរុបត្រូវតែស្មើនឹងវិនិយោគសរុប ។

តាមទស្សនៈរបស់សេដ្ឋវិទូខាងលើ គន្លឹះនៃការអភិវឌ្ឍគឺ ស្ថិតនៅលើការចេះប្រមូលមូលធនក្នុងស្រុកសរុប ដោយធ្វើឱ្យកម្រិតនៃការសន្សំនៅក្នុងស្រុកមានកម្រិតខ្ពស់ និងការយកមូលធនដែលប្រមូលបានពីការសន្សំ ដើម្បីយកទៅធ្វើការវិនិយោគទាំងអស់នោះជាលទ្ធផលគេនឹងទទួលបានអត្រាកំណើនកាន់តែខ្ពស់តាមនេះដែរ។ តាមទស្សនៈនេះមានន័យថា បើកាលណាអត្រាកំណើនសេដ្ឋកិច្ចកាន់តែខ្ពស់ការអភិវឌ្ឍនឹងមានសភាពកាន់តែខ្លាំងផងដែរ។[8]

[7] និស្សិតៈ ព្រំ បញ្ញា និង ហួ លីហួង, សារណាបញ្ចប់ការសិក្សា *( ការអភិវឌ្ឍជនបទ ឃុំព្រៃរំ ស្រុកល្វាឯម ខេត្តកណ្តាល )*

[8] *សៀវភៅ Michael P.Todaro and Stephen C.Smith*, ២០០៩ ទំព័រ ១១២

### ១.១.២.៣. ទ្រឹស្តីរបស់លោក Michael P.Todaro

បើតាមទ្រឹស្តីលោក Michael P.Todaro ចំពោះអត្ថន័យនៃពាក្យ **អភិវឌ្ឍន៍** លោកបានយល់ឃើញថា ការអភិវឌ្ឍ អាចកើតមានឡើង និងប្រកបដោយចីរភាព វាត្រូវបានចាប់ផ្តើមឡើងពីតំបន់ជនបទ ជាពិសេសក្នុងវិស័យកសិកម្ម ហើយប្រទេសមួយអាចឈានដល់ការអភិវឌ្ឍបានយ៉ាងហោចណាស់ត្រូវមានចំណុចបីយ៉ាងដូចខាងក្រោម ៖

- ការពន្លឿនអូរភុត (Output) តាមរយៈការធ្វើកំណែទម្រង់ស្ថាប័ន និងបច្ចេកវិទ្យា ដែលត្រូវបានរៀបចំឡើងដើម្បីបង្កើនផលិតភាពសម្រាប់កសិករតូចតាច។
- បង្កើនតម្រូវការក្នុងស្រុកសម្រាប់ផលិតផលកសិកម្ម ដែលមានប្រភពច្បាស់លាស់មកពីយុទ្ធសាស្រ្តអភិវឌ្ឍន៍ការងារតំបន់ជាយក្រុង។
- សកម្មភាពអភិវឌ្ឍន៍ ជនបទដើម្បីពង្រីកកម្លាំងពលកម្ម និងវិស័យផ្សេងៗទៀតដែលគាំទ្រដោយផ្ទាល់ ឬដោយប្រយោលពីស្ថាប័នពាក់ព័ន្ធ។[9]

### ១.១.២.៤. ទ្រឹស្តីរបស់លោក Francois Peroux

លោក Francois Peroux ជាអ្នកទ្រឹស្តីនៃការអភិវឌ្ឍលើមនុស្ស គាត់បានអោយនិយមន័យថា ការអភិវឌ្ឍ គឺជាការចូលរួមនៃបំលាស់ប្តូរគំនិតចំពោះសង្គមរបស់ប្រជាជនមួយក្រុម ហើយក្នុងការរួមផ្សំនេះបានផ្តល់មកវិញនូវកំណើនសេដ្ឋកិច្ចផ្ទួនៗ និងស្ថិតថេរនៃផលិតផលសរុបរបស់ពួកគាត់ ។

**ការអភិវឌ្ឍ** គឺជាដំណើរការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គម វប្បធម៌ ដែលធ្វើឱ្យមានភាពសុក្រិតយុត្តិធម៌នៅក្នុងស្ថាប័ន និងរាជរដ្ឋាភិបាលនៅក្នុងការជំរុញឱ្យមានការអភិវឌ្ឍដើម្បីកាត់បន្ថយភាពក្រីក្រ ដែលធ្វើឱ្យមានភាពមិនស្មើគ្នារវាងអ្នកមាន និងអ្នកក្រ ដើម្បីលុបបំបាត់អនក្ខរភាព ដោយផ្តល់សេវាបំណ្តុះបណ្តាលចំណេះដឹងដល់ប្រជាជនទូទៅដើម្បីថែរក្សាបរិស្ថាន ឬធនធានធម្មជាតិឱ្យមានតុល្យភាព និងប្រទេសជាតិមានការរីកចម្រើនជានិរន្តរ៍ ។

តាមរយៈនិយមន័យនេះ ដើម្បីឱ្យមានការអភិវឌ្ឍគេចាំបាច់ត្រូវបង្កើតឱ្យមានការរីកចម្រើនខាងសេដ្ឋកិច្ចជាមុនសិន ហើយផលទទួលបានពីការរីកចម្រើនសេដ្ឋកិច្ចនោះ ត្រូវបានគេយកទៅរៀបចំជាមូលដ្ឋានដើម្បីពង្រឹងកំណើនសេដ្ឋកិច្ចហើយបែងចែកដោយ សមធម៌ទៅលើគ្រប់ផ្នែកសេដ្ឋកិច្ចទាំងអស់ ។ ក្នុងន័យនេះដែរ

[9] *ការអភិវឌ្ឍវិស័យកសិកម្មសហគមន៍ក្រពាំងសង្កែ* , និស្សិតៈ ឡុង សុខជា និង សុត វុន , ទំព័រទី ៨, របាយការណ៍កម្មសិក្សា

យើងឃើញថា ការដែលមានកំណើនសេដ្ឋកិច្ច មិនមែនសុទ្ធតែមានការអភិវឌ្ឍនោះទេ តែផ្ទុយទៅវិញការអភិវឌ្ឍចាំបាច់ត្រូវតែមានកំណើនសេដ្ឋកិច្ច។[10]

**១.១.២.៥. ទ្រឹស្តីរបស់លោក** W. Arthur Lewis

លោក Lewis បានឱ្យនិយមន័យ អភិវឌ្ឍន៍ថា ជាការផ្លាស់ប្តូរនូវអ្វីដែលជាភាពចាំបាច់ដំបូង ឬការផ្លាស់ប្តូររចនាសម្ព័ន្ធ សម្រាប់ជាតម្រូវការមូលដ្ឋានរបស់ប្រជាពលរដ្ឋ ។ ជាក់ស្តែងការអភិវឌ្ឍប្រទេសមួយជាដំបូង គេត្រូវពឹងផ្អែកយ៉ាងសំខាន់ទៅលើវិស័យកសិកម្ម ហើយទើបគេធ្វើបំលាស់ប្តូរទៅរកវិស័យផ្សេងៗទៀតដែលទាក់ទងគ្នា ។ នេះគេហៅថាការផ្លាស់ប្តូររចនាសម្ព័ន្ធ (Structural Transformation) ។

លោក Lewis បានឱ្យម៉ូឌែលគំរូអភិវឌ្ឍនៃសេដ្ឋកិច្ចអភិវឌ្ឍមាន ២ វិស័យគឺ៖

- **វិស័យកសិកម្មបែបប្រពៃណី** ៖ វិស័យនេះគ្រាន់តែចិញ្ចឹមជីវិតនៅជនបទដោយប្រើប្រាស់កម្លាំងពលកម្មលើសដែលផលិតភាពពលកម្មស្មើសូន្យ (Zero Marginal Labor Productivity) ។ ដោយសារតែផលិតភាពទាបធ្វើឱ្យកម្រិតជីវភាពប្រជាជនទាប គេអាចដកកម្លាំងពលកម្មពីវិស័យនេះ ដោយមិនប៉ះពាល់ដល់កម្រិតនៃទិន្នផល។ ទាំងនេះហើយ ជាមូលហេតុដែលលោកអាចលើកយកអំណះអំណាងពី ភាពលើសនៃកម្លាំងពលកម្មនៅក្នុងវិស័យកសិកម្ម ក្នុងន័យកម្លាំងពលកម្មលើស ឬខ្វះខ្នាយកម្លាំងពលកម្ម បណ្តាលឱ្យទិន្នផលទាប និងប៉ះពាល់ដល់កម្រិតនៃជីវភាពរបស់ប្រជាជន ដោយគេអាចដកចេញកម្លាំងពលកម្មពីក្នុងវិស័យកសិកម្មទៅវិស័យឧស្សាហកម្ម ដោយគ្មានការខាតបង់នូវកសិផលឡើយ។
- **វិស័យឧស្សាហកម្មទំនើប** ៖ ជានៅក្នុងទីក្រុងដែលប្រើប្រាស់ផលិតភាពខ្ពស់ ដែលត្រូវបានគេបញ្ចូលនូវពលកម្មលើសពីវិស័យកសិកម្ម។ កត្តាចម្បងនៃគំរូនេះ គឺជាដំណើរការនៃការផ្ទេរពលកម្មវិស័យប្រពៃណីទៅវិស័យទំនើប ត្រូវបានធ្វើជាបុព្វហេតុដោយសារការកើនឡើងនៃផលិតផល និងបង្កើនពលកម្មក្នុងវិស័យទំនើប។ ជាមួយនឹងល្បឿននៃការពង្រីកនេះបាននាំមកនូវអត្រាវិនិយោគឧស្សាហកម្ម និងការកើនឡើងអត្រាមូលធន ឬប្រាក់ចំណូលខ្ពស់នៅក្នុងវិស័យទំនើប បណ្តាលអោយបរិមាណតម្រូវការពលកម្មកាន់តែច្រើន ដើម្បីបំពេញ

[10] វេបសាយ https://Regional-Economic-Development-Francois-Perroux/dp/ (ចូលមើលថ្ងៃទី០៣ ឧសភា ឆ្នាំ ២០២០)

នូវកំណើនផលិតភាពខ្ពស់ ដែលអាចផ្តល់លទ្ធភាព ឪកាសដល់អ្នកវិនិយោគមានផលចំណេញបន្តចូលរួមសន្សំនិងវិនិយោគបន្ថែមទៀត ។[11]

### ១.១.៣. គោលបំណងនៃការអភិវឌ្ឍ

ពាក្យថា **អភិវឌ្ឍន៍** ជាដំណើរការនៃការធ្វើឱ្យប្រសើរឡើងខាងគុណភាពនៃការរស់នៅរបស់មនុស្សទាំងអស់ដែលបង្ហាញតាមលក្ខខណ្ឌបីយ៉ាងគឺ ៖

ក. ការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាជន ដូចជា កម្រិតប្រាក់ចំណូល និងការដោះស្រាយបញ្ហាប្រើប្រាស់នៃកំណើនតម្រូវការរបស់ប្រជាជនអោយសមស្របតាមដំណើរនៃទំនាក់ទំនងសេដ្ឋកិច្ច។

ខ. ការបង្កើតលក្ខខណ្ឌ ដែលនាំឱ្យមានការគោរពខ្លួនឯងរបស់មនុស្សជាតិដោយឆ្លងតាមរយៈស្ថាប័នសង្គម នយោបាយ និងស្ថាប័នសេដ្ឋកិច្ច ។

គ.ការកើនឡើងនៃសេរីភាពក្នុងការប្រើប្រាស់មានទំហំកាន់តែធំដូចជា ប្រជាជនមានសិទ្ធិក្នុងការជ្រើសរើស ការប្រើប្រាស់ទំនិញ និងសេវាកម្មជាដើម ។[12]

**ការអភិវឌ្ឍ** មានសមាសធាតុ ឬតម្លៃស្នូលចំនួន ៣យ៉ាងត្រូវបានព្រមព្រៀងជាមួយមូលដ្ឋានគ្រឹះដែលពឹងផ្អែកលើគំនិត និងគោលការណ៍ប្រតិបត្តិ ដើម្បីយល់ដឹងពីអត្ថន័យខាងក្នុង។ តម្លៃស្នូលទាំងបីនោះគឺចីរភាព ការគោរពខ្លួនឯង និងសេរីភាពដែលបានបង្ហាញនូវគោលបំណងរួមរបស់បុគ្គលនីមួយៗ និងសង្គមនានា។ តម្លៃទាំងនោះទាក់ទងទៅនឹងតម្រូវការជាមូលដ្ឋានរបស់មនុស្សដែលមាននៅក្នុងសង្គម និងវប្បធម៌នានាជាដរាប។

យើងអាចសន្និដ្ឋានថា ការអភិវឌ្ឍជាសច្ចភាព ជារូបវ័ន្ត និងជាសភាពផ្លូវចិត្តដែលតាមរយៈការរួមផ្សំនៃដំណើរការសង្គម សេដ្ឋកិច្ច និងស្ថាប័ននេះ ឱ្យមានមធ្យោបាយនានាដើម្បីសម្រេចបាននូវជីវិតដ៏ល្អប្រសើរ។ បើទោះជាសមត្ថភាពនៃជីវិតល្អបែបណាក៏ដោយ យ៉ាងហោចណាស់ការអភិវឌ្ឍក្នុងសង្គមត្រូវមានគោលដៅ ៣ ដូចតទៅ ៖

- ដើម្បីបង្កើនលទ្ធភាពអាចរកបាន និងដើម្បីពង្រីកការបែងចែកទំនិញជីវិតជាមូលដ្ឋានដូចជាម្ហូបអាហារ ផ្ទះសំបែង សុខភាព និងការថែរក្សាសុវត្ថិភាព ។
- ដើម្បីបង្កើនកម្រិតជីវភាពដែលរួមមានការផ្តល់ឪកាសការងារច្រើន បង្កើនស្តង់ដាការអប់រំឱ្យប្រសើរជាងមុន យកចិត្តទុកដាក់ខ្លាំងទៅលើតម្លៃវប្បធម៌ មនុស្សធម៌ជាបន្ថែមទៅលើចំណូលខ្ពស់

[11] *ការអភិវឌ្ឍជនបទ ឃុំព្រែកដំ ស្រុកល្វាឯម ខេត្តកណ្តាល*,និស្សិតៈ ព្រំ បញ្ញា និង ហួ លីហួង, សារណាបញ្ចប់ការសិក្សា

[12] សារណាបញ្ចប់ការសិក្សា,( *ការលើកកម្ពស់ជីវភាពគ្រួសារតាមរយៈការដាំបន្លែ*) និស្សិតៈ អិន សុគា និងឡាញ់ ស្រីនាថ,ទំព័រទី១២

ជាងមុន ហើយធាតុទាំងនោះនឹងជួយលើកកម្ពស់សុខុមាលភាពជាសម្ភារៈ ថែមទាំងជួយបង្កើតការគោរពជាតិ និងបុគ្គលម្នាក់ៗផងដែរ។

- ❖ ដើម្បីពង្រីកលំដាប់នៃជម្រើសសេដ្ឋកិច្ច សង្គម ដែលបុគ្គលនីមួយៗ និងជាតិនានា គឺត្រូវប្រាន ចេញពីភាពអវិជ្ជា និងទុក្ខសោក។[13]

### ១.១.៤. កត្តាដែលជម្រុញឱ្យមានការអភិវឌ្ឍ

បើយើងតាមការសិក្សា ទ្រឹស្តីរបស់សេដ្ឋវិទូបានកំណត់ថា ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសមួយឱ្យមានការរីកចម្រើនបាន មិនថាប្រទេសអ្នកមាន ឬប្រទេសអ្នកក្រចាំបាច់ត្រូវតែមានកត្តា ៤យ៉ាងសំខាន់ៗគឺ ៖

#### ក. កត្តាធនធានធម្មជាតិ

ធនធានធម្មជាតិគឺជាធនធានដែលកើតឡើងដោយខ្លួនឯង ដែលមានប្រភពពីលើអាកាស លើដី ក្រោមដី និងក្នុងទឹកជាដើម ។ ( ទឹក ដី រ៉ែ ប្រេង គុណភាពនៃបរិស្ថាន )

ធនធានធម្មជាតិជាធាតុផ្សំសំខាន់ៗ នៃប្រព័ន្ធអេកូឡូស៊ី ដែលផ្តល់ជាទ្រព្យសម្បត្តិនិងសេវាកម្មក្នុងការប្រើប្រាស់ដើម្បីបំពេញសេចក្តីត្រូវការគ្រប់សភាវៈដែលមានជីវិតទាំងអស់ រួមទាំងការចិញ្ចឹមជីវិតរស់នៅរបស់មនុស្សជាតិផងដែរ។

ធនធានធម្មជាតិជាធនធានដែលមានសារៈសំខាន់បំផុតក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងឧស្សាហកម្ម ដែលត្រូវបានគេទាញយកមកកែច្នៃ ដើម្បីផលិតនូវផលិតផលសម្រេចនានាដែលជះឥទ្ធិពលដល់ការផ្លាស់ប្តូររបស់មនុស្ស និងសម្ភារៈ។

បើយើងសង្កេតមើលទៅ បណ្តាប្រទេសកំពុងអភិវឌ្ឍគេច្រើនប្រើប្រាស់ធនធានទាំងនេះ ដើម្បីទ្រទ្រង់ជីវភាពក៏ដូចជាធ្វើឱ្យប្រសើរឡើងនូវគុណភាពរស់នៅរបស់មនុស្ស ហើយធនធានដែលមានតម្លៃជាងគេគឺ ដីដែលអាចដាំដុះបាន ព្រោះភាគច្រើននៃប្រជាជនដែលរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ប្រកបរបរ កសិកម្ម ដាំដុះ និងចិញ្ចឹមសត្វដែលអាស្រ័យដោយផ្ទាល់ទៅលើដី។

#### ខ. ធនធានមនុស្ស

អ្នកសេដ្ឋវិទូ បានយល់ឃើញថា ធនធានមនុស្ស គឺជាអ្នកកំណត់នូវអត្តចរិកលក្ខណៈសេដ្ឋកិច្ច សង្គម វប្បធម៌ របស់ប្រទេសមួយដើម្បីឈានទៅរកការអភិវឌ្ឍផងដែរ។ ធនធានមនុស្សគឺជា មនុស្សដែលពេញលេញបរិបូរណ៍ដោយចំណេះដឹង និងការបណ្តុះបណ្តាលជាប្រភពសម្រាប់កសាងប្រទេសជាតិ។

[13]សារណាបញ្ចប់ការសិក្សា( *ការអភិវឌ្ឍវិស័យកសិកម្មប្រទេសកម្ពុជា* ), និស្សិត៖ ឡៃ ប៉ូរ៉ាពីន, ទំព័រទី ៩ និង ១០

ធនធានមនុស្សមានតួនាទីសំខាន់ណាស់ក្នុងការអភិវឌ្ឍដែលស្ថិតក្នុងគោលបំណង ដើម្បីមនុស្សនិងសង្គមជាតិ។ ការអភិវឌ្ឍ បានបង្ហាញយ៉ាងច្បាស់ថា ប្រទេសជាតិនីមួយៗអាចរីកចម្រើនទៅមុខបាន គឺអាស្រ័យដោយធនធានមនុស្សដើរតួយ៉ាងសំខាន់ក្នុងការបំពេញរាល់សកម្មភាពទាំងនោះដែលមានមនុស្សមានសមត្ថភាព ឬមនុស្សមានគុណភាពពោលគឺជាប្រជាពលរដ្ឋសកម្មព្រោះថា មនុស្សជាកត្តាផលិតកម្មដ៏សំខាន់ក្នុងការជម្រុញកំណើនសេដ្ឋកិច្ចតាមរយៈវិស័យកសិកម្ម វិស័យឧស្សាហកម្ម និងសេវាកម្មផ្សេងៗក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនទៅមុខជានិរន្តរ៍ ។

**គ. កត្តាមូលធន**

បើតាមសេដ្ឋវិទូបាននិយាយថា ដំណើរការដំបូងនៃការអភិវឌ្ឍ គឺបង្កើតឱ្យមានមូលធនតាមរយៈការសន្សំ និងការវិនិយោគ។ មូលធន គឺជាកត្តាសំខាន់បំផុតនៅក្នុងដំណើរការអភិវឌ្ឍក៏ដូចជាកំណើនសេដ្ឋកិច្ច ដោយសារតែមូលធនជាប្រភពដែលនាំឱ្យមានកត្តាផលិតកម្ម ឧបករណ៍សម្រាប់ដោះដូរទំនិញ និងជាប្រភពតម្រូវការចាំបាច់មួយសម្រាប់មនុស្ស ដែលធ្វើឱ្យមានភាពប្រសើរឡើងនៃប្រាក់ចំណូលនិងគុណភាពរស់នៅរបស់មនុស្សដើម្បីធ្វើការអភិវឌ្ឍ។ ការកើនឡើងនៃមូលធនចេញជាលទ្ធផលនៅពេលដែលសមាមាត្រនៃចំណូលបច្ចុប្បន្នត្រូវបានសន្សំ និងវិនិយោគធ្វើកើនឡើងនូវទិន្នផល និងប្រាក់ចំណូលនៅពេលអនាគត។ នៅពេលដែលការវិនិយោគមូលធនកើនឡើង នោះការងារផលិតកម្មក៏កើនឡើងដែរ។ ការវិនិយោគផ្ទាល់ទាំងនោះគឺត្រូវបានបន្ថែមដោយការវិនិយោគទៅលើអ្វីដែលត្រូវបានគេស្គាល់នៅក្នុងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គមដូចជា ផ្លូវថ្នល់ អគ្គិសនី ទឹកស្អាត ការទាក់ទងសម្របសម្រួលគ្នាក្នុងសកម្មភាព សមាហរណកម្មសេដ្ឋកិច្ច។

**ឃ. កត្តាបច្ចេកវិទ្យា**

បើនិយាយពីបច្ចេកវិទ្យាអាចចាត់ទុកថា ជាប្រភពចម្បងនៅក្នុងការធ្វើឱ្យមានកំណើនសេដ្ឋកិច្ច ហើយការជម្រុញផ្នែកបច្ចេកវិទ្យាបានរួមចំណែកយ៉ាងខ្លាំងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលធ្វើឱ្យមានការអភិវឌ្ឍប្រទេសរីកចម្រើនយ៉ាងរហ័សនិងលេចធ្លោ។ ចំពោះបច្ចេកវិទ្យា បាននាំឱ្យមានការប្រែប្រួលនៅក្នុងដំណើរការនៃផលិតកម្មដែលគេអាចផលិតផលិតផលបានច្រើន មានគុណភាពល្អជាងមុននិងសន្សំពលកម្ម ព្រមទាំងសន្សំមូលធនគឺជាអ្វីដែលគេត្រូវការបំផុត។ បម្រែបម្រួលបច្ចេកវិទ្យា គឺជារកដំណើរការនៃការកែលម្អគុណភាពក្នុងទ្រង់ទ្រាយតូចទៅទ្រង់ទ្រាយធំជាបន្តបន្ទាប់ដែលទាមទារឱ្យមានការជម្រុញនិងការអភិវឌ្ឍសេដ្ឋកិច្ច។

ប្រភពនៃបច្ចេកវិទ្យាកំពុងអភិវឌ្ឍ គឺជាការទិញឬនាំចូលបច្ចេកវិទ្យាពីប្រទេសរីកចម្រើនដែលប្តូរជាមួយទំនិញនាំចេញរបស់ខ្លួន។ ដូច្នេះបច្ចេកវិទ្យាមានសារៈសំខាន់ណាស់សម្រាប់ធានានូវកំណើនសេដ្ឋកិច្ច ក្នុងរយៈពេលវែងដែលមានការចាត់ថ្នាក់ជាមូលដ្ឋានបី គឺ ៖

- កំណើនបច្ចេកវិទ្យាអព្យាក្រឹត ៖ កើនឡើងនៅពេលផលិតផលខ្ពស់ត្រូវបានសម្រេចនៅបរិមាណដូចគ្នាពីការផ្សំនៃកត្តាផលិតកម្ម។
- កំណើនបច្ចេកវិទ្យាតាមរយៈការសន្សំពលកម្ម ៖ កើនឡើងនៅពេលកម្រិតនៃផលិតផលកើនឡើងជាមួយនឹងបរិមាណនៃកត្តាពលកម្មដដែលនោះ។ តួយ៉ាងមានដូចជា កុំព្យូទ័រ អគ្គីសនី គឺត្បាញដោយស្វ័យប្រវត្តិ ត្រាក់ទ័រ ម៉ាស៊ីនច្រូតស្រូវ និងឧបករណ៍ទំនើបផ្សេងៗទៀត បានចាត់ទុកជាការសន្សំពលកម្ម ។
- កំណើនបច្ចេកវិទ្យាតាមរយៈការសន្សំមូលធន ៖ ជាការកើនឡើងនៅកម្រិតបរិមាណផលិតផលជាមួយបរិមាណកត្តាមូលធន។ ការរីកចម្រើនបច្ចេកវិទ្យានេះកើតមានតាមរយៈការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្រ របបគំហើញនូវឧបករណ៍ថ្មីៗសម្រាប់ប្រើប្រាស់ក្នុងដំណើរការផលិតកម្មគឺការសន្សំមូលធន។[14]

### ១.១.៥. កត្តាដែលរាំងស្ទះដល់ការអភិវឌ្ឍ

ការអភិវឌ្ឍជាទូទៅមិនអាចធ្វើឱ្យស្មើគ្នាគ្រប់តំបន់ឡើយ ជាពិសេសក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ និងប្រទេសក្រីក្រ ដែលងាយរងគ្រោះ និងជួបឧបសគ្គមួយចំនួនដូចជា ៖

- **កំណើនប្រជាជន**

  កំណើនប្រជាជននៅតែជាបញ្ហាចម្បងសម្រាប់ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ដែលអត្រាកំណើនប្រជាជនបានកើតឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលជាហេតុនាំឱ្យមានការរាំងស្ទះដល់ការអភិវឌ្ឍ។ ចំពោះការកើនឡើងចំនួនប្រជាជនធ្វើឱ្យមានការកើនឡើងនូវតម្រូវការប្រើប្រាស់ សម្ភារៈ ការទាញយកធនធានធម្មជាតិជាច្រើនដែលជាហេតុធ្វើឱ្យជះឥទ្ធិពលដល់ការសន្សំ ចំណូល និងការផ្គត់ផ្គង់មិនទាន់តម្រូវការប្រើប្រាស់គ្រប់គ្រាន់សម្រាប់ជីវិតរស់នៅរបស់ពួកគាត់។

- **ការអប់រំមានកម្រិតទាប**

[14] *ការអភិវឌ្ឍជនបទ ឃុំព្រែកដំ ស្រុកល្វាឯម ខេត្តកណ្តាល*, និស្សិត៖ ព្រំ បញ្ញា និង ហួ លីហួង(សារណាបញ្ចប់ការសិក្សា)

ជាការពិតណាស់នៅក្នុងសង្គម ការអប់រំក៏ត្រូវបានផ្សារភ្ជាប់ទៅនឹង សេដ្ឋកិច្ចផងដែរគឺសេដ្ឋកិច្ចសង្គម និងសេដ្ឋកិច្ចគ្រួសារ។ សេដ្ឋកិច្ច គឺជាកត្តាមួយដែលសំខាន់នៅក្នុងការជម្រុញដំណើរការនៃការអប់រំប្រព្រឹត្តទៅបានយ៉ាងរលូន និងជោគជ័យ ដោយសារតែប្រទេសកំពុងអភិវឌ្ឍគឺជាប្រទេសដែលទើបតែងើបចេញពីភាពក្រីក្រ ដូច្នេះសក្តានុពលសេដ្ឋកិច្ចនៅមានកម្រិតនៅឡើយ ជាហេតុជះឥទ្ធិពលដល់បញ្ហាសេដ្ឋកិច្ចគ្រួសារដែលបណ្តាលឱ្យ គ្រួសារពុំមានលទ្ធភាពក្នុងការផ្គត់ផ្គង់ដល់ការរៀនសូត្ររបស់កុមារ។ នៅប្រទេសកំពុងអភិវឌ្ឍភាគច្រើនប្រឈមនឹងបញ្ហាអត្រាអនក្ខរជនច្រើន ជាពិសេសនៅតាមតំបន់ជនបទដែលជាវិបត្តិមួយក្នុងការអភិវឌ្ឍ ដោយសារការអប់រំជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការបង្កើនធនធានមនុស្ស ឱ្យឆ្ពោះទៅរកការអភិវឌ្ឍប្រទេសទាំងមូល។

- **និកម្មភាព**

បញ្ហានិកម្មភាពគឺបញ្ហាមួយដែល គួរឱ្យព្រួយបារម្ភខ្លាំងសម្រាប់សកលលោក ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ បើយោងតាមការសង្កេតជាក់ស្តែងចំនួននៃនិកម្មភាពមានចំនួនខ្ពស់ដែលមនុស្សជាច្រើនមិនអាចរកការងារបាន ដោយទីផ្សារការងារមិនទាន់សំបូរបែប ធ្វើឱ្យប្រជាជនធ្វើការផ្លាស់ប្តូរទីលំនៅជាច្រើនពីជនបទមកទីក្រុង ដោយសារតែគេរំពឹងថានឹងរកការងារ ដែលមានប្រាក់បៀវត្សខ្ពស់ជាងប្រាក់ដែលធ្វើបរកសិកម្ម។

- **កត្តានយោបាយ**

ជាការពិតណាស់ប្រទេសមួយអាចអភិវឌ្ឍន៍ឬអត់ គឺអាស្រ័យលើស្ថានភាពនយោបាយរបស់ប្រទេសនោះមានស្ថានភាពដូចម្តេច? ប្រសិនបើប្រទេសនោះស្ថិតក្នុងអសន្តិភាពនយោបាយ អសន្តិសុខប្រឈមមុខនឹងភាពអនាធិបតេយ្យ ចលាចល ឬច្បាប់ប្រទេសស្ថិតក្នុងសភាពទន់ខ្សោយ ដែលមិនអាចធានាសន្តិសុខ យុត្តិធម៌ជូនប្រជាពលរដ្ឋបាន នេះជាបញ្ហាដ៏ធំបំផុតមួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងប្រទេសជាតិទាំងមូល។ ផលប៉ះពាល់ទាំងនេះគឺបាត់បង់នូវទំនុកចិត្តពីបណ្តាប្រទេសនានាក្នុងការ វិនិយោគ ឬផ្តល់ជាជំនួយជាដើម។ ហេតុតែគ្មានទំនុកចិត្តមិនថាតែត្រៀមវិនិយោគប៉ុណ្ណោះទេ សូម្បីតែអ្នកវិនិយោគរួចហើយក៏អាចបាត់បង់ទៅវិញដែរ។ បញ្ហាទាំងនេះនឹងធ្វើឱ្យប្រជាជន ក៏ដូចជាប្រទេសជាតិទាំងមូលបាត់នូវចំណូល និងបញ្ហាផ្សេងៗទៀតដែលរាំងស្ទះដល់ការអភិវឌ្ឍប្រទេសជាតិ។ [15]

[15] សារណាបញ្ចប់ការសិក្សា, (*ការអភិវឌ្ឍជនបទ ឃុំព្រែកធំ ស្រុកល្វាឯម ខេត្តកណ្តាល*), និស្សិត៖ ព្រំ បញ្ញា និង ហួ លីហ្វុង

### ១.១.៦. ទ្រឹស្តីជាមូលដ្ឋានជម្រុញការអភិវឌ្ឍវិស័យកសិកម្ម

#### ១.១.៦.១. និយមន័យកសិកម្ម

ពាក្យថា **កសិកម្ម** ត្រូវបានអ្នកប្រាជ្ញនីមួយៗ ឱ្យនិយមន័យទៅតាមទស្សនៈយល់ឃើញផ្សេងៗពីគ្នា តែអត្ថន័យរបស់វាក៏មិនខុសពីគ្នាប៉ុន្មានដែរ។ និយមន័យទាំងនោះរួមមាន ៖

**កសិកម្ម** សំដៅដល់ផ្នែកមួយនៃការធ្វើពលកម្មរបស់មនុស្សជំនាន់ដើមដែលមានការចូលរួមពីកត្តាផលិតកម្មផ្សេងៗដូចជា កម្លាំងពលកម្មរបស់មនុស្ស ដើម្បីធ្វើការកែប្រែដីកសិកម្ម និងការចិញ្ចឹមសត្វ។

**កសិកម្ម** គឺជាវិទ្យាសាស្ត្រ ឬសិល្បៈនៃការកែច្នៃដី ការធ្វើគ្រាប់ពូជ ការផលិត ការបង្កាត់ពូជ និងស្បៀងអាហារគ្រប់ប្រភេទសម្រាប់ការផ្គត់ផ្គង់ទីផ្សារ។

**កសិកម្ម** គឺជាការភ្ជួររាស់ ឬការងារដែលគេប្រកបក្នុងការភ្ជួររាស់ គឺការធ្វើស្រែចំការ។

ការអភិវឌ្ឍវិស័យកសិកម្មសំដៅលើការធ្វើឱ្យប្រែប្រួល ទិន្នផលកសិកម្មជាវិជ្ជមាន និងកែប្រែគុណភាពពីទាបទៅខ្ពស់ ឬធ្វើការផ្លាស់ប្តូរបច្ចេកវិទ្យាថ្មីក្នុងផលិតកម្មកសិកម្ម។[16]

#### ១.១.៦.២. មុខងារកសិកម្មក្នុងការអភិវឌ្ឍ

បច្ចុប្បន្ននេយើងឃើញថាប្រទេសដែលមានការអភិវឌ្ឍកាន់តែខ្ពស់ការចូលរួមចំណែករបស់វិស័យកសិកម្ម ចំពោះផលិតផលក្នុងស្រុកសរុបកាន់តែតិចទៅៗ ដោយផ្ទុយពីវិស័យឧស្សាហកម្ម សម្រាប់ប្រទេសក្រីក្រនិងប្រទេសកំពុងអភិវឌ្ឍន៍ ផ្ទុយពីប្រទេសអភិវឌ្ឍន៍កសិកម្មមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ការរួមចំណែករបស់វិស័យកសិកម្មក្នុងផលិតផលសរុបមានកម្រិត និងបានចូលរួមកម្លាំងពលកម្មច្រើនជាង ៧០% ។ ដូច្នេះហើយ ប្រទេសកំពុងអភិវឌ្ឍន៍ ឬប្រទេសក្រីក្រគួរតែសិក្សា ពិចារណាឱ្យបានច្បាស់លាស់ ព្រមទាំងស៊ីជម្រៅទៅលើទំនាក់ទំនង និងកត្តាដែលវិស័យកសិកម្មនេះនាំឱ្យមានការអភិវឌ្ឍដល់សេដ្ឋកិច្ច។[17]

### ១.១.៧. និយមន័យសហគមន៍

**សហគមន៍** គឺជាការរស់នៅប្រមូលផ្តុំរវាងមនុស្សម្នាក់ៗ និងគ្រួសារនីមួយៗនៅក្នុងភូមិសាស្ត្រជាមួយនឹងប្រជាជនដែលស្គាល់គ្នាយ៉ាងជិតស្និទ្ធ ចេះជួយទុក្ខធុរៈគ្នាទៅវិញទៅមកមានសាមគ្គីភាពល្អជាមួយគ្នា មានជីវភាពរស់នៅប្រហាក់ប្រហែលគ្នា។ ជាទូទៅការរៀបចំចងក្រងជាសហគមន៍ គឺជាវិធីមួយដែលផ្តល់ឱ្យសមាជិកនីមួយៗរបស់សហគមន៍នូវ ចំណេះដឹង ជំនាញ ឥរិយាបថ ក្នុងការបង្ហាញ និងកំណត់អាទិភាព

[16] បណ្ឌិត ឈុន ពហុ, *សៀវភៅ ការអភិវឌ្ឍជនបទ* ( ភ្នំពេញ ៖ ស.ភ.វ.ស, ២០០៩ ) , ទំព័រ ២៣

[17] ឡៃ ប៉ូរ៉ាពីន, *ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា* (២០១៧), ទំព័រ១២-១៥ ។

សេចក្តីត្រូវការ បញ្ហារបស់ពួកគាត់ដោយត្រូវបានប្រើប្រាស់ធនធានដែលពួកគាត់មាន ដើម្បីដោះស្រាយបញ្ហា និងរួមគ្នាធ្វើសកម្មភាពផ្សេងៗឱ្យរីកចម្រើនទាំងអស់គ្នា។[18]

**សហគមន៍** គឺសំដៅលើក្រុមមនុស្សដែលរស់នៅតំបន់ជាមួយគ្នា មានបំណងរួមគ្នា ប្រយោជន៍រួមគ្នា មានវប្បធម៌ដូចគ្នា មានបញ្ហាប្រហាក់ប្រហែលគ្នា ហើយចែករំលែកនូវចំណេះដឹង បទពិសោធន៍ និងដោះស្រាយបញ្ហាជាមួយគ្នា ។[19]

**សហគមន៍** គឺជាស្ថាប័នស្វយ័តរបស់សមាជិកដែលចូលរួមដោយស្ម័គ្រចិត្តក្នុងការបំពេញតម្រូវការរួម ផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ និងបំណងប្រាថ្នាតាមរយៈសហគ្រាសមួយដែលគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ និងមានម្ចាស់រួមគ្នា។

**សហគមន៍** គឺជាអង្គការស្ម័គ្រចិត្ត ដែលបើកចំហដល់មនុស្សគ្រប់រូបក្នុងការប្រើប្រាស់សេវាកម្មរបស់ពួកគាត់ និងសុខចិត្តទទួលយកការទទួលខុសត្រូវភាពជាសមាជិកដោយគ្មានការរើសអើងទៅលើ យេនឌ័រ សង្គម ពូជសាសន៍ នយោបាយ និងសាសនា។[20]

### ១.១.៨. និយមន័យការអភិវឌ្ឍសហគមន៍

បន្ទាប់ពីបានសិក្សាពីអត្ថន័យពាក្យថា សហគមន៍រួចមក យើងបន្តសិក្សាស្វែងយល់ពីអត្ថន័យរបស់ ការអភិវឌ្ឍសហគមន៍ ដែលសរុបជារួមមក ការអភិវឌ្ឍសហគមន៍កន្លងមកនេះ យើងសង្កេតថា ត្រូវបានគេមើលឃើញច្រើនបំផុត គឺជាការអភិវឌ្ឍសម្រាប់តែមនុស្ស។ វាពិតជាមានអត្ថន័យត្រឹមត្រូវ និងចាំបាច់ប៉ុន្តែវាគ្រាន់តែជាទស្សនៈវិស័យនិងការយល់ឃើញដល់ខ្លីមួយ ដែលមិនគ្រប់គ្រាន់សម្រាប់អត្ថន័យនៃការអភិវឌ្ឍសហគមន៍នៅឡើយទេ។ ហេតុដូចនេះហើយ ទើបយើងឃើញមានការលើកឡើងផ្សេងៗគ្នាទាក់ទងនឹងនិយមន័យនៃការអភិវឌ្ឍសហគមន៍ផងដែរ។ ដើម្បីសិក្សាស្វែងយល់ពីអត្ថន័យ ឱ្យកាន់តែច្បាស់លាស់និងស៊ីជម្រៅបន្ថែមទៀត យើងនឹងធ្វើការបកស្រាយ និងលើកឡើងពីទស្សនៈយល់ឃើញដូចខាងក្រោម ៖

**ការអភិវឌ្ឍសហគមន៍** គឺជាការរួមបញ្ចូលនូវដំណោះស្រាយ និងសកម្មភាពទាំងឡាយដែលមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវសុខមាលភាព និងកម្រិតជីវភាពក្នុងការរស់នៅរបស់ប្រជាជននៅតាមជនបទ

---

[18] និស្សិត៖ ឡុង សុខជា និង សុត វុន, ( *ការអភិវឌ្ឍវិស័យកសិកម្មសហគមន៍ត្រពាំងសង្កែ* ), របាយការណ៍បញ្ចប់ការសិក្សា, ទំព័រ ៨

[19] នួន វណ្ណា , ឆៃលាង បញ្ញា និងឯម វណ្ណារ៉ា, ( *គំរោងអភិវឌ្ឍន៍សហគមន៍អ្នកក្រីក្រក្នុងរាជធានីភ្នំពេញ* ), របាយការណ៍កម្មសិក្សាថ្នាក់បរិញ្ញាបត្រ, ២០០៦, ទំព័រទី ១៣

[20] (*សៀវភៅ គោលការណ៍ណែនាំស្តីពីការសិក្សាស្រាវជ្រាវសម្រាប់បណ្តុះបណ្តាលសមាជិកសហគមន៍កសិកម្ម និងមន្ត្រី នៅកម្ពុជា ទំព័រ២២, ២៣)*

និងតំបន់ដាច់ស្រយាលដើម្បីធ្វើការអភិវឌ្ឍ។ ដំណោះស្រាយទាំងនេះត្រូវតែគិតគូរយ៉ាងយកចិត្តទុកដាក់ចំពោះបញ្ហាសង្គម ជាពិសេស គឺរៀបចំសហគមន៍ឱ្យបានល្អប្រសើរ។

**ការអភិវឌ្ឍសហគមន៍** ជាដំណើរការបន្តបន្ទាប់ឥតឈប់ឈរមួយដែលធ្វើសន្សឹមៗក្នុងរយៈពេលយូរអង្វែងដើម្បីនាំមកនូវការរីកចម្រើន ផ្លាស់ប្តូរកែប្រែ ជឿនលឿនដែលអាចទទួលយកបានសម្រាប់កែលម្អជីវភាពរស់នៅរបស់សង្គមឱ្យកាន់តែប្រសើរឡើងជាលំដាប់។[21]

**ការអភិវឌ្ឍសហគមន៍** ជាតម្រូវការចាំបាច់ក្នុងការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជនបទ និងបានចូលរួមយ៉ាងសកម្មក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈការពង្រឹងសមត្ថភាពសហគមន៍មូលដ្ឋានការអភិវឌ្ឍន៍ភូមិចម្រុះ ការលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈ គ្រួសារការផ្តល់ជំនាញមូលដ្ឋានដល់សហគមន៍ជនបទសម្រាប់បង្កើតមុខរបរនិងការបង្កើនសមត្ថភាពសហគមន៍ទប់ស្កាត់ និងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយផ្សេងៗនៅតាមសហគមន៍។ នេះជាយន្តការគន្លឹះមួយដែលធ្វើសកម្មភាពដោយផ្ទាល់ជាមួយសហគមន៍មូលដ្ឋាន សំដៅធ្វើឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយាឥរិយាបថនិងផ្នត់គំនិតរបស់សហគមន៍ជនបទដើម្បីធានាការអភិវឌ្ឍមានភាពជាម្ចាស់។ តួនាទីសំខាន់របស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ គឺការបង្កើត និងពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ( គ.អ.ភ ) អភិវឌ្ឍន៍ភូមិចម្រុះ លើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារកាត់បន្ថយអនក្ខរភាពនិងការអភិវឌ្ឍមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ។[22]

### ១.១.៩. និយមន័យសហគមន៍កសិកម្ម

**សហគមន៍កសិកម្ម** គឺជាអង្គការឯកជនមួយដែលបង្កើតឡើង ដោយកសិករមួយក្រុមតាមការស្ម័គ្រចិត្ត រួមគ្នាបង្កើតទុន រួមគ្នាធ្វើជាម្ចាស់ និងគ្នាគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យ សំដៅលើកកម្ពស់សេដ្ឋកិច្ចសង្គម វប្បធម៌របស់សមាជិក ដោយអនុលោមតាមគោលការណ៍គ្រឹះទាំងប្រាំពីរ របស់សម្ព័ន្ធសហគមន៍អន្តរជាតិ និងច្បាប់ស្តីពីសហគមន៍កសិកម្មកម្ពុជា។ នៅក្នុងនេះ សហគមន៍កសិកម្មមានទិសដៅដូចជា៖

- លើកកម្ពស់សេដ្ឋកិច្ចរបស់សមាជិក៖ ធ្វើឱ្យសមាជិកមានជីវភាពធូរធា តាមរយៈការបង្កើនប្រាក់ចំណូលក្នុងគ្រួសារពីអាជីវកម្មកសិកម្ម។

[21] *វេបសាយ* *https://en.wikipedia.org/wiki/Rural-Community-Development* , (ចូលមើលថ្ងៃទី ២០ ឧសភា ២០២០)
[22] ( *សៀវភៅ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ* ) ,ឆ្នាំ ២០១៤- ២០១៨ ,រៀបចំដោយ នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ ក្រសួងអភិវឌ្ឍន៍ជនបទ ,ទំព័រទី ០៦

- លើកកម្ពស់សង្គមៈ បង្កើនសាមគ្គីភាព ធានានូវសមភាព សមធម៌ និងការជួយគ្នាទៅវិញទៅមកក្នុងសហគមន៍កសិកម្ម ព្រមទាំងចូលរួមក្នុងការអភិវឌ្ឍសង្គម។
- លើកកម្ពស់វប្បធម៌៖ ចូលរួមគាំទ្រដល់កិច្ចការវប្បធម៌ដូចជាការថែរក្សាប្រពៃណីរបស់ប្រជាកសិករ។[23]

**សហគមន៍កសិកម្ម** គឺជាអង្គកាសង្គមសេដ្ឋកិច្ចប្រជាធិបតេយ្យពលរដ្ឋស្ម័គ្រចិត្ត ជាកន្លែងដែលកសិករជាសមាជិករួបរួមគ្នាជាក្រុមដើម្បីជួយដោះស្រាយបញ្ហា និងបង្កើនកម្រិតជីវភាពដល់សមាជិកក្នុងក្រុម។ សហគមន៍កសិកម្មទាំងនេះផ្តល់ឥណទាន ( សម្រាប់ផលិតកម្ម និងការប្រើប្រាស់ ) ការធ្វើទីផ្សារផលិតផលរបស់សមាជិក ការផ្តល់វត្ថុធាតុដើមកសិកម្មដូចជា ជី និងគីមីកសិកម្ម និងគ្រប់ពូជ និងសេចក្តីណែនាំជាទម្រង់ពង្រីកកសិកម្ម និងធ្វើឱ្យជីវភាពរស់នៅមានភាពប្រសើរឡើង។

**សហគមន៍កសិកម្ម** គឺជាស្ថាប័នប្រជាធិបតេយ្យ ដោយប្រជាជនមួយក្រុមជាសមាជិកធ្វើមហាសន្និបាតបោះឆ្នោតជ្រើសតាំង (មិនមែនតែងតាំង) ដែលកើតឡើងចេញពីការសម្រេចចិត្ត និងរួមមតិកសាងដើម្បីផលប្រយោជន៍រួម ដឹកនាំឆ្ពោះទៅរកមាគ៌ាជោគជ័យ អភិវឌ្ឍន៍ដល់សេដ្ឋកិច្ចគ្រួសារ សង្គម និងរួមចំណែកកាត់បន្ថយកម្រិតភាពក្រីក្រ។

**សហគមន៍កសិកម្ម** គឺជាសហគមន៍ស្វយ័តមួយដែលបង្កើតឡើងដោយមនុស្សមួយក្រុមដោយស្ម័គ្រចិត្តដើម្បីសម្រេចគោលបំណងរួម បំពេញតម្រូវការវប្បធម៌ សង្គម និងសេដ្ឋកិច្ច តាមរយៈការចាប់ផ្តើមសហគ្រាសសហកម្មសិទ្ធ និងគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ។[24]

បើយោងតាមមាត្រាទី៤ នៃបទប្បញ្ញត្តិទូទៅស្តីពីការបង្កើតសហគមន៍កសិកម្មបានឱ្យ និយមន័យថា សហគមន៍កសិកម្ម ជានីតិបុគ្គលឯកជនមានលក្ខណៈជាសហគ្រាសសេដ្ឋកិច្ចកសិកម្មដែលបង្កើតឡើងដោយរូបវន្តបុគ្គលមួយក្រុម តាមការស្ម័គ្រចិត្ត រួមគ្នាបង្កើតដើមទុន រួមគ្នាធ្វើម្ចាស់ និងរួមគ្នាគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យ ដើម្បីពង្រីកសមត្ថភាពផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម សំដៅលើកកម្ពស់សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់សមាជិក។[25]

---

[23] *សៀវភៅ គោលគំនិតសហគមន៍កសិកម្ម*, ឆ្នាំ២០១៥, រៀបចំដោយ (គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅការធ្វើជំនួញ BPAC នៃនាយដ្ឋានសហគមន៍កសិកម្ម)

[24]( *គោលការណ៍ណែនាំស្តីពី ការសិក្សាស្រាវជ្រាវសម្រាប់បណ្តុះបណ្តាលសមាជិកសហគមន៍កសិកម្ម និងមន្ត្រីនៅកម្ពុជា* ), រៀបចំដោយ៖ គម្រោង (BPAC), ឆ្នាំ២០១៥

[25] *ច្បាប់ស្តីពី សហគមន៍កសិកម្ម, អនុម័តដោយរដ្ឋសភា ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៣*

### ១.១.១០. ការអភិវឌ្ឍសហគមន៍កសិកម្ម

ការអភិវឌ្ឍសហគមន៍កសិកម្ម មានន័យថា ជាការអភិវឌ្ឍដែលជម្រុញដល់ការធ្វើឱ្យប្រសើរឡើងនូវសហគមន៍កសិកម្ម និងការលើកទឹកចិត្តដល់ប្រជាកសិករឱ្យចងក្រងគ្នាជាសហគមន៍កសិកម្មដើម្បីពង្រីកអំណាចទីផ្សារ កាត់បន្ថយថ្លៃដើមផលិតកម្ម បង្កើនកំណើនផលិតកម្មក្នុងវិស័យកសិកម្ម បង្កើនប្រាក់ចំណូលដល់គ្រួសាររបស់ប្រជាកសិករ និងសេដ្ឋកិច្ចសង្គម។[26]

ជាពិសេសទៅទៀត ការអភិវឌ្ឍសហគមន៍កសិកម្មអាចជួយសម្រួលឱ្យប្រជាកសិកម្មមានការងាយស្រួលក្នុងការប្រកបរបរកសិកម្មដោយពួកគាត់អាចមានលទ្ធភាពក្នុងការធ្វើកសិកម្មដោយទទួលបាននូវឥណទានពីសហគគមន៍កសិកម្ម ជីធម្មជាតិ គីមី ឧបករណ៍និងសម្ភារៈប្រើប្រាស់នៅក្នុងដំណើរការផលិតកម្មរហូតដល់ពេលប្រមូលផល។ បន្ថែមពីនេះ ការអភិវឌ្ឍនេះក៏អាចជួយផ្តល់ចំណេះដឹងបន្ថែមអំពីបច្ចេកទេសបែបទំនើបនៅក្នុងដំណើរការធ្វើកសិកម្ម បង្កើនទិន្នផលតាមតម្រូវការ ស្វែងរកទីផ្សារបន្ថែម ពង្រីកការយល់ដឹងនូវផ្នត់គំនិត និងស្វែងរកដំណោះស្រាយអំពីបញ្ហាផ្សេងៗ ដើម្បីជួយសម្រួលដល់ការធ្វើកសិកម្មរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ ហើយអាចរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមដែលជម្រុញឱ្យប្រទេសមានការអភិវឌ្ឍប្រកបដោយចីរភាព។

សរុបសេចក្តីមក ការអភិវឌ្ឍសហគមន៍កសិកម្មនេះ អាចជួយសម្រួលដល់ប្រជាកសិករដែលរស់នៅក្នុងសហគមន៍ទទួលបាននូវចំណេះដឹងពីបច្ចេកទេសធ្វើកសិកម្ម ផ្តល់លទ្ធភាពដល់ប្រជាកសិករក្រីក្រ បង្កើនកម្រិតជីវភាពដល់ប្រជាពលរដ្ឋ កាត់បន្ថយអត្រាភាពក្រីក្រក្នុងសង្គម និងបង្កើនផលិតផលក្នុងស្រុកសរុប (GDP) ដែលជម្រុញកំណើនសេដ្ឋកិច្ចជាតិឱ្យប្រទេសមានការអភិវឌ្ឍប្រកបដោយ ចីរភាព និងនិរន្តរភាព។[27]

## ១.២. គោលគំនិតនៃការអភិវឌ្ឍសហគមន៍

### ១.២.១. ទស្សនៈវិស័យនៃការអភិវឌ្ឍសហគមន៍

នៅក្នុងទស្សនៈវស័យនៃការអភិវឌ្ឍសហគមន៍គឺ ៖

- ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងភាពក្រីក្រ ភាពមិនចេះអក្សរ ភាពមានជម្ងឺ និងភាពអសកម្មរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍។

[26] វេបសាយ http://wmc.org.kh

[27] *សៀវភៅ គោលគំនិតសហគមន៍កសិកម្ម*, ឆ្នាំ២០១៥, រៀបចំដោយ (គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅការធ្វើជំនួញ BPAC នៃនាយដ្ឋានសហគមន៍កសិកម្ម)

- ដើម្បីចូលរួមចំណែកនៅក្នុងបង្កើនកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដែលនាំទៅរកការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសជាតិ។
- ដើម្បីធ្វើឱ្យបានសម្រេចនូវការបែងចែកធនធាន និងផលនៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងនិរន្តរភាព។
- ដើម្បីសម្រេចឱ្យបាននូវ យុត្តិធម៌ សមភាពរបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងសហគមន៍ និងក្នុងពិភពលោកដោយមិនគិតពីជាតិសាសន៍ ជំនឿសាសនា វប្បធម៌ ស្ថានភាពសង្គម សេដ្ឋកិច្ច និងនិន្នាការនយោបាយជាដើម។[28]

### ១.២.២.គោលការណ៍នៃការអភិវឌ្ឍសហគមន៍

តាមគោលការណ៍នៃការអភិវឌ្ឍសហគមន៍ចែកចេញជាបួនចំណុចសំខាន់ៗ ដែលមានក្នុងនោះរួមមានការចូលរួមក្នុងសហគមន៍ ភាពជាអ្នកដឹកនាំ ការផ្តល់អំណាច និងរៀនពីជីវិត។

- **ការចូលរួមក្នុងសហគមន៍** មនុស្សម្នាក់ៗបានធ្វើវិភាគទានដែលមានតម្លៃមួយ និងបានចូលរួមជាសមាជិករបស់សហគមន៍ ដែលអាចចូលរួមក្នុងកម្រិតណាមួយដែលខ្លួនមានបំណង ហើយសមាជិកមានសិទ្ធិពេញលេញចំពោះការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងការវាយតម្លៃ ការសាកល្បង ការចូលរួម និងការកំណត់ទិសដៅនៅគ្រប់ជាន់ថ្នាក់ទាំងអស់។

- **ភាពជាអ្នកដឹកនាំសហគមន៍** សមាជិកទាំងអស់នៅក្នុងសហគមន៍មានទំនាក់ទំនងគ្នាយ៉ាងសកម្មនៅក្នុងការធ្វើការសម្រេចចិត្ត និងមានភាពដឹកនាំនៃសកម្មភាពនៅកណ្តាល។ ការបញ្ចូលនូវគណៈកម្មាធិការគ្រប់គ្រងអ្នកស្ម័គ្រចិត្ត ត្រូវបានជ្រើសរើសដោយសមាជិកដែលរស់នៅ និងធ្វើការ ឬមានការចូលរួមពីសហគមន៍នៅក្នុងស្រុក ដើម្បីគ្រប់គ្រងគណៈកម្មាការកណ្តាលនីមួយៗ។

- **ការផ្តល់អំណាច** ជាដំណើរការមួយដែលមានការគោរព មានគុណតម្លៃ និងពង្រឹងនូវសមត្ថភាពរបស់មនុស្ស ដើម្បីបំពេញនូវតម្រូវការរបស់ពួកគាត់ ស្មារតីនៅក្នុងការយល់ដឹងដោយខ្លួនឯង និងបង្ហាញពីវិធីដែលធ្វើឱ្យមានគុណប្រយោជន៍នៃជំនាញ បទពិសោធន៍ និងសក្តានុពល។

- **រៀនពីជីវិត** ជាការរួមបញ្ចូលគ្នានូវគ្រប់រូបភាពទាំងអស់នៃសកម្មភាពកណ្តាលដូចជាការបង្កើននូវចំណេះដឹង គាំទ្រនូវជំនាញ ចំណេះដឹង និងសមត្ថភាព ព្រមទាំងភាពមិនចុះញមរបស់មនុស្ស។ ពួកគាត់បាន

---

[28] ឡុង សុខជា និងសុត វុន ( *ការអភិវឌ្ឍវិស័យកសិកម្មរបស់សហគមន៍ត្រពាំងសង្កែ* ),ស.ភ.វ.ស ២០១៩, របាយការណ៍បញ្ចប់ការសិក្សា, បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍ, ទំព័រ ១០

ពង្រឹងនូវសុខភាព សុខមាលភាព ទំនាក់ទំនងរវាងគ្នាទៅវិញទៅមក និងគ្រួសារ តាមរយៈវិធីសាស្ត្រជាផ្លូវការ និងមិនផ្លូវការ នៅការសិក្សាអប់រំ ការស្វែងយល់អំពីបទពិសោធន៍ កិច្ចការ និងការអភិវឌ្ឍខ្លួនឯង។

សរុបមក គោលការណ៍នៃការអភិវឌ្ឍសហគមន៍នេះគឺចង់ឱ្យប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ទាំងមូលទទួលបាននូវផលប្រយោជន៍យ៉ាងច្រើន ដោយអាចឱ្យពួកគាត់បានអភិវឌ្ឍន៍ខ្លួនរបស់ពួកគាត់ និងក្រុមគ្រួសារផងជាហេតុធ្វើឱ្យសហគមន៍ទាំងមូលទទួលបាននូវវឌ្ឍនៈភាព និងការអភិវឌ្ឍយ៉ាងឆាប់រហ័ស។[29]

### ១.២.៣.គោលបំណងនៃការអភិវឌ្ឍសហគមន៍

ពាក្យថា**ការអភិវឌ្ឍ** គឺជាកត្តាមួយដែលជម្រុញឱ្យមានការរីកចម្រើនតាមរយៈការអភិវឌ្ឍពីកម្រិតប្រាក់ចំណូលទាបទៅរកកម្រិតប្រាក់ចំណូលខ្ពស់។ ហេតុនេះហើយ ទើបនាំឱ្យកើតមានការបង្កើតសហគមន៍នៅតាមតំបន់ជនបទ និងទីដាច់ស្រយាលនៅក្នុងគោលបំណងដើម្បីបង្កើនកម្រិតជីវភាពក្នុងការរស់នៅរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយអត្រាភាពក្រីក្រនៅក្នុងសង្គម។ ដូច្នេះហើយទើបរដ្ឋាភិបាលបានខិតខំយ៉ាងយកចិត្តទុកដាក់ទៅលើការបង្កើតផែនការនិងវិធីសាស្ត្រថ្មីៗដើម្បីអភិវឌ្ឍសហគមន៍អោយបានល្អប្រសើរ និងប្រកបដោយចីរភាព។ សកម្មភាពទាំងអស់នេះបានឆ្លុះបញ្ចាំងពីគោលបំណងនៃការអភិវឌ្ឍសហគមន៍ ដូចជា ៖

- បង្កើននូវកម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងសហគមន៍
- បង្កើតសុខភាព អនាម័យ និងសុខាភិបាល
- អភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ដើម្បីឱ្យផលិតផលមានចរន្តចេញចូល
- បង្កើតឱកាសការងារជាច្រើនដល់ប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយបញ្ហាចំណាកស្រុក
- ផ្តល់ឱកាសដល់ប្រជាពលរដ្ឋក្នុងការសម្រេចចិត្ត និងប្រើប្រាស់សិទ្ធិនៅក្នុងសហគមន៍
- ធ្វើការបង្កើននូវទិន្នផលខ្ពស់ ដើម្បីបង្កើនប្រាក់ចំណូលដល់គ្រួសារ
- ផ្តល់ឱកាសដល់ប្រជាពលរដ្ឋឱ្យចេះជួយសង្គ្រោះ និងឱ្យយល់នៅសិទ្ធិរបស់ខ្លួនបានច្រើនថែមទៀត មានសីលធម៌ល្អ និងទំនាក់ទំនងគ្នាបានល្អ
- បង្រៀននិងពន្យល់ពីបច្ចេកទេសក្នុងការធ្វើកសិកម្ម និងដោះស្រាយបញ្ហានានា។

សរុបជារួមមកគោលបំណងក្នុងការអភិវឌ្ឍសហគមន៍ គឺមានបំណងចង់ឱ្យប្រជាពលរដ្ឋមានកម្រិតជីវភាពក្នុងការរស់នៅល្អប្រសើរ បង្កើនទិន្នផលកសិកម្ម ចែករំលែកចំណេះដឹង បទពិសោធន៍ បច្ចេកទេស ផ្ទត់

[29] ស៊ុត សុជាមុនីរត្ន និងស៊ាង សុខ, ( *ការអភិវឌ្ឍសហគមន៍របស់អង្គការស៊ីស៊ីឌីដើម្បីកាត់បន្ថយភាពក្រីក្រក្នុងខេត្តក្រចេះ* ), ស.ភ.វ .ស របាយការណ៍បញ្ចប់ការសិក្សា ២០១១, ទំព័រទី ៨,៩ ។

គំនិតអភិវឌ្ឍឱ្យមានភាពសហការ ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់សេដ្ឋកិច្ចរបស់ប្រទេសឱ្យមានការរីកចម្រើន។[30]

### ១.២.៤. មូលហេតុនៃការអភិវឌ្ឍសហគមន៍

យើងសង្កេតឃើញថាប្រជាជននៅតាមជនបទ និងទីដាច់ស្រយាលនៅតែមានស្ថានភាពសេដ្ឋកិច្ចគ្រួសារកម្រិតទាបនៅឡើយដោយមានការ ខ្វះខាតលទ្ធភាព កង្វះអនាម័យ កង្វះបច្ចេកទេស កង្វះប្រព័ន្ធសិក្សាអប់រំ និងកង្វះខាតប្រព័ន្ធគមនាគមន៍។ ជាងនេះទៅទៀត កម្រិតនៃការបែងចែកប្រាក់ចំណូលនិងការអភិវឌ្ឍមានកម្រិតទាបបើធៀបនឹងប្រជាជនដែលរស់នៅទីក្រុង ដែលបណ្ដាលឱ្យមាន និកម្មភាព អត្រាកំណើននៃភាពក្រីក្រ កំណើនបំលាស់ទីរស់នៅ និងប៉ះពាល់ដល់បញ្ហាសេដ្ឋកិច្ចរបស់ប្រទេស។ ហេតុដូចនេះហើយទើបរាជរដ្ឋាភិបាល ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលបានជម្រុញនិងធ្វើការបង្កើតឡើងឱ្យមានសហគមន៍នៅតាមតំបន់ជនបទ ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍកម្រិតជីវភាពនិងការរស់នៅរបស់ប្រជាជនឱ្យប្រសើរឡើងប្រកបដោយចីរភាព និងការរីកចម្រើនជាដរាប។

## ១.៣. គោលនយោបាយរបស់រដ្ឋាភិបាលដើម្បីអភិវឌ្ឍន៍សហគមន៍

ការបង្កើត និងបំពេញភារកិច្ចនៃនាយកដ្ឋានអភិវឌ្ឍសហគមន៍ បន្ទាប់ពីធ្វើការបោះឆ្នោតជាសាកលឆ្នាំ ១៩៩៣ ក្រសួងអភិវឌ្ឍជនបទត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលនៅក្នុងអាណត្តិទី១ យោងតាមព្រះរាជក្រមលេខ នស/រកម/១១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសឱ្យប្រើប្រាស់ច្បាប់ស្ដីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ និងយោងតាមអនុក្រិតលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូរ ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។ នៅក្នុងទិសដៅបង្កើនកម្រិតជីវភាពប្រជាជន និងកាត់បន្ថយភាពក្រីក្រនៅតាមជនបទផងដែរនោះ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍បានចាប់បដិសន្ធិឡើងនៅក្រោមអាណាព្យាបាលរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលជានាយកដ្ឋានជំនាញទទួលបន្ទុកការងារអភិវឌ្ឍន៍សហគមន៍ទូទាំងប្រទេស ដើម្បីធ្វើឱ្យមានការប្រែប្រួលសង្គមជនបទទាំងមូល។

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ មានគោលនយោបាយសម្រាប់ផែនការអភិវឌ្ឍន៍សហគមន៍រយៈខ្លីមធ្យម និងរយៈពេលយូរវែងដោយសិក្សាស្រាវជ្រាវលើគម្រោងជួសជុល កសាងហេដ្ឋារចនាសម្ព័ន្ធជនបទដូចជាស្ពាន ផ្លូវ ថ្នល់ សាលារៀន មជ្ឈមណ្ឌលសុខភាពអភិវឌ្ឍន៍ភូមិ។ ព្រមទាំងធ្វើការគ្រប់គ្រងមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ដោយធ្វើការរៀបចំបែបជនបទ ដែលពាក់ព័ន្ធទៅនឹង ដំណើរការថែរក្សា

[30] ឡៅ ធន់សោភ័ណ្ឌ និងអន សុខអេង, ( ការអភិវឌ្ឍសហគមន៍នៅក្នុងភូមិព្រៃទទឹង ), របាយការណ៍បញ្ចប់ការសិក្សា ស.ភ.វ.ស

ហេដ្ឋារចនាសម្ព័ន្ធជនបទរបស់ប្រជាជន ដើម្បីធ្វើការធានាឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាព តាមផែនការដែលបានដាក់ចុះដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងជម្រុញ លើកទឹកចិត្តដល់ប្រជាពលរដ្ឋ ឱ្យបង្កើននូវផលិតផលបន្ថែមដើម្បីផ្គត់ផ្គង់គ្រួសារនិងទីផ្សារ។ ចំពោះការអប់រំក្រៅប្រព័ន្ធ នាយកដ្ឋានមានតួនាទីបញ្ជូនភ្នាក់ងារអភិវឌ្ឍន៍សហគមន៍ ចុះតាមមូលដ្ឋានដើម្បីធ្វើការអប់រំប្រជាពលរដ្ឋអំពីអក្ខរកម្ម ការការពារបរិស្ថាន និងធនធានធម្មជាតិ ព្រមទាំងលើកទឹកចិត្តឱ្យប្រជាជនចូលរួមសហការគ្នាបង្កើតជាសហគមន៍កសិកម្ម ដើម្បីអភិវឌ្ឍលើវិស័យកសិកម្មនិងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ។ នាយកដ្ឋានត្រូវយកចិត្តទុកដាក់ក្នុងការបង្កើតពង្រឹងរចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទ ជាពិសេសគណកម្មាធិការអភិវឌ្ឍន៍ភូមិឃុំ និងជួយដោះស្រាយដល់ជនមាតុភូមិនិវត្តន៍ និងជនផ្លាស់ប្តូរទីលំនៅ។[31]

### ១.៣.១. គោលនយោបាយអភិវឌ្ឍន៍សហគមន៍

**ការអភិវឌ្ឍសហគមន៍** សំដៅលើយន្តការដ៏ល្អមួយដែលធ្វើសកម្មភាពដោយផ្ទាល់ជាមួយសហគមន៍មូលដ្ឋានដែលសំដៅដល់ការធ្វើឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា ឥរិយាបថ ផ្នត់គំនិតរបស់ប្រជាសហគមន៍នៅតាមទីជនបទ ដើម្បីធ្វើការអភិវឌ្ឍមួយឆ្ពោះទៅរកភាពរីកចម្រើននិងប្រកបដោយនិរន្តរភាព។ សកម្មភាពអភិវឌ្ឍន៍សហគមន៍បានចូលរួមយ៉ាងសំខាន់ នៅក្នុងការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ ដែលសកម្មភាពនេះធ្វើឡើងស្របគោលនយោបាយ វិមជ្ឈការ វិសហមជ្ឈការ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ជានាយកដ្ឋានមួយចំណុះឱ្យអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានតួនាទីជាសេនាធិការទទួលបន្ទុកការងារអភិវឌ្ឍន៍សហគមន៍ជនបទ ទូទាំងប្រទេស។ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយ កាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ នាយកដ្ឋានបានធ្វើសកម្មភាពអភិវឌ្ឍន៍សហគមន៍ចម្រុះដូចជាការបង្កើត ពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ការអភិវឌ្ឍភូមិចម្រុះ ការបណ្តុះបណ្តាលអនក្ខរកម្ម ការលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារនិងការពង្រឹងនូវសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ។ ហើយសកម្មភាពទាំងអស់នេះ ក៏បានចូលរួមយ៉ាងសំខាន់នៅក្នុងការជួយគាំទ្រដល់យុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល និងគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជាឱ្យទទួលបានជោគជ័យផងដែរ។[32]

---

[31] សែម ឡុងឌី និងយឹង មឿន, ( ការអភិវឌ្ឍសហគមន៍តាមរយៈកសិកម្មចម្រុះ ), របាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ស.ភ.វ.ស ២០០៧, ទំព័រទី ១៦,១៧ ។

[32] http://fia.maff.gov.kh/newsdetail/skvYfIaFbf ( ចូលមើលថ្ងៃ ២៥ ឧសភា ឆ្នាំ ២០២០ )

### ១.៣.២. ទិសដៅអភិវឌ្ឍន៍

នៅក្នុងការអភិវឌ្ឍ គឺជាបំផ្លាស់ប្តូរពីភាពដែលគ្មានមកមាន និងពីស្ថានភាពអន់ថយមកប្រសើរឡើង ដោយមានលក្ខណៈទិសដៅនិងគោលបំណងច្បាស់លាស់ដើម្បីឈានទៅរកមាគ៌ារីកចម្រើនជានិរន្តរ៍។ ដូចគ្នានេះផងដែរ ការអភិវឌ្ឍសហគមន៍ក៏មានទិសដៅក្នុងការអភិវឌ្ឍមួយចំនួនដូចខាងក្រោម ៖

- លើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមជនបទ ឱ្យមានស្វ័យភាពសេដ្ឋកិច្ចគ្រប់គ្រាន់ និងឈានឡើងប្រហាក់ប្រហែលបណ្តាប្រទេសនានា នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ក្នុងពេលអនាគត ដោយត្រូវតែខិតខំបំពេញនូវតម្រូវការដែលចាំបាច់ ដើម្បីជាមូលដ្ឋាននៅក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ ព្រមទាំងបង្កើននូវប្រាក់ចំណូល និងមុខរបរដល់ប្រជាពលរដ្ឋ។
- លើកទឹកចិត្ត និងចលនាប្រជារាស្ត្រជនបទឱ្យចូលរួមគ្រប់ដំណាក់កាលនៃគម្រោងការងារអភិវឌ្ឍន៍ ដើម្បីធានានូវប្រសិទ្ធភាពការងារ និងភាពស្ថិតស្ថេរនៃគម្រោងទៅអនាគត។ រៀបចំកម្មវិធីសេដ្ឋកិច្ចឱ្យសមស្របទៅតាមលទ្ធភាព និងជំនាញនៃប្រជាពលរដ្ឋតាមជនបទ ជាពិសេសបង្កើតវគ្គបណ្តុះបណ្តាល ណែនាំប្រជាកសិករឱ្យចូលរួមកែលម្អផលិតកម្មកសិកម្ម ផ្តល់ជាការបង្ហាត់បង្ហាញបច្ចេកទេសបែបទំនើប ផ្តល់ឥណទានឱ្យប្រជាពលរដ្ឋមានលទ្ធភាពគ្រប់គ្រាន់ រកទីផ្សារដែលអាចជម្រុញឱ្យសេដ្ឋកិច្ចជាតិកាន់តែល្អប្រសើរឡើង។
- ប្រគល់សិទ្ធិ និងភារកិច្ចជូនប្រជាកសិករឱ្យមានទំនុកចិត្តលើខ្លួនឯង ទទួលបានការសាមគ្គីភាព មានសិទ្ធិសេរីភាពក្នុងការសម្រេចចិត្ត និងមានតួនាទីយ៉ាងសំខាន់នៅក្នុងការចូលរួមដោះស្រាយបញ្ហាដែលកើតមានឡើងនៅក្នុងសហគមន៍របស់ពួកគាត់ដោយផ្ទាល់ ជាជាងរងចាំការដោះស្រាយពីរដ្ឋាភិបាល ឬពីភ្នាក់ងារអភិវឌ្ឍន៍ជនបទផ្សេងទៀត។
- បន្តការខិតខំសហការជាមួយស្ថាប័នដែលពាក់ព័ន្ធ និងធ្វើការដោះស្រាយបញ្ហាដែលកំណើនប្រជាពលរដ្ឋនៅក្នុងទីក្រុង ដែលបង្កឡើងដោយការជម្លៀសចេញមកពីជនបទ នៅរយៈពេលសង្គ្រាមបីទសវត្សកន្លងមកនេះ។
- ខិតខំស្តារឡើងវិញ និងបន្តអនុវត្តន៍តាមគោលនយោបាយរបស់រដ្ឋាភិបាល នៅក្នុងយុទ្ធសាស្ត្រចតុកោណស្តីការអភិវឌ្ឍសហគមន៍ ដើម្បីចូលរួមលើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋនៅ

តាមជនបទកាត់បន្ថយភាពក្រីក្រ ដែលជម្រុញដល់ការរីកចម្រើនដល់សហគមន៍ និងកំណើនសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។[33]

### ១.៣.៣. យុទ្ធសាស្ត្រការអភិវឌ្ឍ

បន្ទាប់ពីបានកំណត់ទិសដៅអភិវឌ្ឍន៍ខាងលើ រាជរដ្ឋាភិបាលបានកំណត់នូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាពដូចជា ៖

- ជម្រុញសកម្មភាពក្នុងការសិក្សាស្រាវជ្រាវ និងស្រង់ទិន្នន័យនៅតាមថ្នាក់ភូមិឃុំឱ្យបានឆាប់រហ័សដើម្បីជាមូលដ្ឋានបង្អែកដ៏រឹងមាំក្នុងការកសាងផែនការអភិវឌ្ឍន៍ជនបទប្រកបដោយប្រសិទ្ធភាព។
- ដំណើរការការងារក្នុងការអភិវឌ្ឍ ដោយយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លានៅក្នុងការដោះស្រាយបញ្ហាសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងសន្តិសុខនៅតំបន់ណាដែលបានកំណត់ជាក់លាក់ទៅតាមលំដាប់លំដោយ នៃអាទិភាពសមស្របទៅតាមស្ថានភាពជាក់ស្តែង និងតម្រូវការរបស់ប្រជាពលរដ្ឋដោយធ្វើវិមជ្ឈការទំនួលខុសត្រូវជូនគណៈកម្មាការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង នៅក្នុងការកំណត់តំបន់គោលដៅនៅតាមមូលដ្ឋានរបស់គេ។
- លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់ ដូចជាតំបន់ដាច់ស្រយាល តំបន់មិនសូវលូតលាស់ តំបន់មធ្យម និងតំបន់កំពុងមានការរីកចម្រើន។ រាជរដ្ឋាភិបាលបានប្រមូលផ្តុំកម្លាំង និងធនធាននៅក្នុងការអភិវឌ្ឍតំបន់មិនសូវលូតលាស់ និងតំបន់លូតលាស់មធ្យម។ ទន្ទឹមនឹងនេះ ក៏មានគាំទ្រវិនិយោគទុនដោយផ្អែកលើឯកជននៅតំបន់កំពុងមានការរីកចម្រើន។
- ជម្រុញនិងគាំទ្រដល់ប្រជាកសិករក្នុងការបង្កើតសហគមន៍ ប្រជាពលរដ្ឋជនបទទូទៅនៅក្នុងការដោះស្រាយបញ្ហាដោយផ្ទាល់ខ្លួនឯង និងឈានទៅដល់ការដោះស្រាយបញ្ហារបស់សហគមន៍ដែលអាចលើកទឹកចិត្តឱ្យសហគមន៍ ប្រជាពលរដ្ឋកាន់តែប្រសើរឡើងនូវសកម្មភាពស្វ័យឧបត្ថម្ភ និងទំនុកចិត្តលើខ្លួនឯង។[34]

### ១.៣.៤. បេសកកម្មរបស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាស្ថាប័នមានសមត្ថកិច្ចក្នុងការជម្រុញនិងគាំទ្រក្នុងការបង្កើតការចុះបញ្ជី ប្រតិបត្តិការនិងការអភិវឌ្ឍរបស់សហគមន៍កសិកម្ម។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវមាន នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ដោយអនុលោមតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រង

[33] *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ៥ឆ្នាំលើកទី២*, រៀបចំដោយក្រសួងអភិវឌ្ឍន៍ជនបទ

[34] *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤ - ២០១៨*, រាជរដ្ឋាភិបាលកម្ពុជា, ឆ្នាំ២០១០

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ដើម្បីសម្របសម្រួលដល់ការបង្កើត និងគាំទ្រការអនុវត្តន៍សហគមន៍កសិកម្មនៅទូទាំងប្រទេសកម្ពុជាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ នៅក្នុងកិច្ចប្រឹងប្រែងមួយដែលឈរលើទិសដៅអភិវឌ្ឍន៍លើវិស័យកសិកម្ម និងលើកកម្ពស់កម្រិតប្រជាពលរដ្ឋ ប្រកបដោយ សមធម៌ និរន្តរភាព និងប្រសិទ្ធភាព នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មត្រូវបំពេញបេសកកម្មដូចខាងក្រោម ៖

- រៀបចំបង្កើត ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានា ( រួមមាន សេចក្តីណែនាំតួនាទី បទបញ្ជា និង បទបញ្ញាត្តិជាដើម) និងគាំទ្រដល់ការអនុវត្តច្បាប់
- ជម្រុញ គាំទ្រការប្រព្រឹត្តទៅ ការប្រតិបត្តិ និងការអភិវឌ្ឍរបស់សហគមន៍កសិកម្ម
- សិក្សា រៀបចំគោលនយោបាយ ក្របខណ្ឌ័គតិយុត្ត ផែនការយុទ្ធសាស្ត្រ និងកម្មវិធីបណ្តុះបណ្តាលសម្រាប់ការជម្រុញ ការពង្រឹងសមត្ថភាពនិងការអភិវឌ្ឍសហគមន៍កសិកម្ម
- កំណត់អង្គភាពទទួលបន្ទុកការងារចុះបញ្ជី និងគ្រប់គ្រងទិន្នន័យសហគមន៍កសិកម្ម
- ផ្តល់សេវាកម្មបណ្តុះបណ្តាលដល់សហគមន៍កសិកម្មនិងភ្នាក់ងារអភិវឌ្ឍន៍សហគមន៍កសិកម្ម
- អនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំ លើកកម្ពស់ការយល់ដឹងនិង បណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរបស់សហគមន៍កសិកម្ម
- កំណត់ទម្រង់បញ្ជីគណនេយ្យរបស់សហគមន៍កសិកម្ម ដោយមានការឯកភាពក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សម្របសម្រួលរវាងសហគមន៍កសិកម្មជាមួយផ្នែកឯកជន ឬផ្នែកពាក់ព័ន្ធផ្សេងទៀតនៅក្នុងប្រទេស ឬក្រៅប្រទេស
- សិក្សានិងវាយតម្លៃពីស្ថានភាពសេដ្ឋកិច្ចរបស់សហគមន៍កសិកម្មដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារ ព្រមទាំងផ្តល់ព័តមានទីផ្សារកសិផលដល់សហគមន៍កសិកម្ម
- ធ្វើកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌជាតិនិងអន្តរជាតិស្តីពីសហគមន៍កសិកម្ម
- ជ្រើសរើសសវនករ ឬអ្នកត្រួតពិនិត្យនិងអ្នកជម្រះបញ្ជីក្នុងករណីដែលសហគមន៍កសិកម្មណាមួយត្រូវបានរំលាយ
- តាមដាន និងវាយតម្លៃការប្រព្រឹត្តទៅនិងប្រតិបត្តិការរបស់សហគមន៍កសិកម្ម
- ចូលរួមដោះស្រាយរាល់ទំនាស់របស់សហគមន៍កសិកម្ម

- បំពេញភារកិច្ចផ្សេងទៀតក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍសហគមន៍កសិកម្មក្រោមវិសាលភាពនៃច្បាប់ពីប្រមុខរដ្ឋាភិបាល។[35]

[35] *ច្បាប់ស្តីពី សហគមន៍កសិកម្ម, រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៣*

# ជំពូកទី២

# ស្ថានភាពទូទៅជុំវិញការអភិវឌ្ឍរបស់សហគមន៍កសិកម្មភ្នំដិន សែនសុខ

## ២.១. ប្រវត្តិនិងទីតាំងភូមិសាស្ត្ររបស់សហគមន៍

ប្រទេសកម្ពុជា ជាប្រទេសមួយដែលមានសក្តានុពលធនធានធម្មជាតិតាំងពីសម័យដើមមកម្ល៉េះ ជាពិសេសនោះគឺផ្តោតទៅលើវិស័យកសិកម្ម ជាកត្តាចម្បងក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើន។ ដូចគ្នាផងដែរនោះ ខេត្តតាកែវ ជាខេត្តមួយក្នុងចំណោមខេត្តទាំងអស់ដែលមានប្រវត្តិ និងទីតាំងភូមិសាស្ត្រមួយដែលមានសក្តានុពលខ្លាំងលើវិស័យកសិកម្ម។ ឃុំភ្នំដិន ជាឃុំមួយនៅក្នុងខេត្តតាកែវដែលកើតឡើងតាំងពីដើមមក ដែលពេលនោះប្រជាពលរដ្ឋភាគច្រើនប្រកបរបរកសិកម្ម តាមបែបប្រពៃណីដើម្បីចិញ្ចឹមជីវិតរស់នៅរបស់ក្រុមគ្រួសារពួកគាត់។ រហូតមកដល់ឆ្នាំ ១៩៧៥ ប្រជាពលរដ្ឋបាននាំគ្នាចាកចេញពីភូមស្រុកធ្វើដំណើរទៅកាន់ខេត្តផ្សេងៗ ដោយសារតែសង្គ្រាមប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ (ប៉ុល ពត)។ ក្រោយថ្ងៃ ០៧ មក ឆ្នាំ ១៩៧៩ ប្រជាជនក្នុងភូមិនេះក៏វិញមករស់នៅដូចដើមវិញ និងមានអ្នកចំណូលថ្មីខ្លះៗផងដែរ។ ក្រោយមកដោយសារតែកំណើនប្រជាជនមានការកើនឡើងជាលំដាប់នោះ ឃុំភ្នំដិនមានប្រជាជនប្រហែល ១៥០០ គ្រួសារដែលមករស់នៅ និងប្រកបមុខរបរផ្សេងៗគ្នា។

ក្នុងកំឡុងពេលនោះប្រជាពលរដ្ឋដែលរស់នៅឃុំភ្នំដិនបានជួបឧបសគ្គជាច្រើនដូចជា ក្រោយសង្គ្រាមប្រជាជនបាត់បង់ជម្រក បញ្ហាបែកបាក់គ្រួសារ បាត់បង់ដីធ្លី ជួបបញ្ហាសុខភាព កង្វះខាតមន្ទីរពេទ្យ សាលារៀន ទឹកស្អាតប្រើប្រាស់ គ្មានអគ្គិសនីជាដើម និងគ្មានការអភិវឌ្ឍគ្រប់វិស័យ។ ប្រជាពលរដ្ឋនៅពេលនោះពួកគាត់ប្រកបរបរធ្វើស្រែចំការ ដាំដុះបន្លែដំណាំផ្សេងៗ ដោយផ្អែកតែម្យ៉ាងទៅលើការធ្វើកសិកម្មដើម្បីចិញ្ចឹមជីវិតរស់នៅ។ ស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំភ្នំដិនបានជួបការលំបាកជាច្រើន ដោយការធ្វើកសិកម្មបែបប្រពៃណីទទួលផលបានតិច ខ្វះលទ្ធភាពក្នុងដំណើរការផលិតកម្ម បច្ចេកទេស ការយល់ដឹងលក្ខខណ្ឌអាកាសធាតុមិនអំណោយផលទទួលរងគ្រោះធម្មជាតិ និងធ្វើកសិកម្មដោយពឹងលើទឹកភ្លៀង។ មិនត្រឹមតែប៉ុណ្ណោះទេ ប្រជាជនដែលរស់នៅតំបន់នោះក៏ចាប់ផ្តើមប្រឈមមុខជាមួយបញ្ហាជាច្រើនទៀតដូចជា កម្រិតប្រាក់ចំណូលទាប បញ្ហាដីធ្លី បញ្ហាគំរាមកំហែង បញ្ហាគម្រោងអភិវឌ្ឍន៍ និងក្រុមហ៊ុនឯកជន ជនអ្នកមានអំណាចមកចាប់យកដី បង្កភាពចលាចលដល់ប្រជាជន បញ្ហាកេងបន្លំ បញ្ហាទីផ្សារឡើងចុះតម្លៃផលិតផលកសិកម្មដោយសារឈ្មួញកណ្តាល និងខ្វះការបណ្តុះបណ្តាលពីរដ្ឋាភិបាល ឬអង្គភាពពាក់ព័ន្ធ។ ដោយសារតែបញ្ហាទាំងនោះ ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធទាំងអស់បានរួបរួមគ្នាបង្កើតជាសហគមន៍មួយ

ឈ្មោះថា សហគមន៍កសិកម្មភ្នំដិន សែនសុខ ហៅកាត់ថា ស.ក. ភ.ដ.ស បាន បង្កើតឡើងនៅថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៤ ដោយមានការចុះបញ្ជីត្រឹមត្រូវនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការគាំទ្រពីរដ្ឋាភិបាល និងអង្គភាពពាក់ព័ន្ធ ជាពិសេសដោយប្រជាពលរដ្ឋខ្មែរចំនួន ៨៣ នាក់ដែលមានគំនិតផ្តួចផ្តើមដោយផ្ទាល់ និងអ្នកមានមុខរបរចម្បងក្នុងវិស័យកសិកម្ម ឬសេវាកម្មទាំងឡាយណាដែលមានទំនាក់ទំនងនឹងវិស័យកសិកម្ម ហើយប្រមូលផ្តុំដោយស្ម័គ្រចិត្ត ដែលមានអាស័យដ្ឋាន៖ ភូមិទទឹង ឃុំភ្នំដិន ស្រុកគិរីវង់ ខេត្តតាកែវ ។

ឃុំភ្នំដិន ជាឃុំមួយស្ថិតក្នុងចំណោមឃុំទាំង ១២ នៅក្នុងស្រុងគិរីវង់ដែលមានព្រំប្រទល់ ខាងជើងជាប់នឹង ឃុំគិរីចុងកោះ និងឃុំកំណប់ ខាងត្បូងជាប់នឹង ឃុំសោមនិងវៀតណាម ខាងលិចជាប់នឹង ឃុំចុងកោះ និងឃុំសោម និង ខាងកើតជាប់នឹង ប្រទេសវៀតណាម។ នៅក្នុងឃុំភ្នំដិននេះ មានផ្ទៃដីសរុប ១៩២២ ហិចតា មានភូមិចំនួន ៩ ភូមិ ដូចជា៖ ភូមិផ្សារ ភូមិតាឡឹង ភូមិកណ្តាល ភូមិតារុង ភូមិថ្វា ភូមិអណ្តូងគៀន ភូមិធំ ភូមិទទឹង ភូមិថ្មី ។

## ២.២. ប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម

### ២.២.១. ប្រជាពលរដ្ឋ

បច្ចុប្បន្ននេះសហគមន៍កសិកម្មភ្នំដិន សែនសុខមាន ៖

- ចំនួនប្រជាពលរដ្ឋសរុបក្នុងតំបន់មាន ១២៧៩៣ នាក់ ក្នុងនោះស្រីចំនួន ៤៣៥៣នាក់ និងប្រុសចំនួន ៨៤៤០នាក់ ក្នុងនោះមានចំនួន ២២១៦ គ្រួសារ។ ប្រជាពលរដ្ឋក្នុងតំបន់ជាអ្នកកាន់សាសនាព្រះពុទ្ធ ៩៣% កាន់សាសនាឥស្លាម ២% និងសាសនាគ្រឹស្ត ៥%។
- ក្នុងចំណោមប្រជាពលរដ្ឋនៅក្នុងឃុំភ្នំដិនទាំងអស់ អ្នកមិនចេះអក្សរចំនួន ៨០នាក់ ស្រី ៥៥នាក់ កម្រិតបឋមសិក្សាចំនួន ១០៤៣ នាក់ ស្រី ៥០១នាក់ កម្រិតមធ្យមសិក្សាចំនួន ៤០១នាក់ ស្រី ២៥០នាក់ និងកម្រិតឧត្តមសិក្សាចំនួន ៦៥ នាក់ ស្រីចំនួន ២៥ នាក់។
- ចំនួនស្រីមេម៉ាយក្នុងឃុំភ្នំដិនចំនួន ៣៥ នាក់
- ចំនួនជនពិការក្នុងឃុំភ្នំដិនចំនួន ២០នាក់ ស្រីចំនួន ៥នាក់
- ចំនួនចាស់ជរាក្នុងឃុំភ្នំដិនចំនួន ១០០នាក់ ស្រីចំនួន ៤០នាក់
- ចំនួនកុមារកំព្រាក្នុងឃុំភ្នំដិនចំនួន ២៥នាក់ ស្រីចំនួន ១០ នាក់
- ចំនួនអ្នកមានជម្ងឺរ៉ាំរ៉ៃក្នុងឃុំភ្នំដិនចំនួន ១៥នាក់ ស្រី ៧នាក់។

(ឧបសម្ព័ន្ធទី២)

#### ២.២.២. មុខរបរ

មុខរបរសំខាន់របស់ប្រជាពលរដ្ឋនៅក្នុងឃុំភ្នំដិន រួមមាន៖

- ធ្វើស្រែចម្ការចំនួន ៩០%
- លក់ដូរមានចំនួន ៣%
- មន្ត្រីរាជការចំនួន ២%
- ចិញ្ចឹមសត្វចំនួន ៥ %
- ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ៩,០០០,០០០ រៀល។

### ២.៣. ទស្សនៈវិស័យ និង គោលបំណងរបស់សហគមន៍កសិកម្ម

#### ២.៣.១. ទស្សនៈវិស័យ

សហគមន៍កសិកម្មភ្នំដិនសែនសុខ មានទស្សនៈវិស័យចូលរួមសម្រួលដល់ការដឹកនាំគ្រប់គ្រងលើសកម្មភាពផលិតកម្ម អាជីវកម្ម សិប្បកម្ម ការទិញលក់កសិផល សម្ភារៈកសិកម្ម របស់សហគមន៍ឱ្យមានប្រសិទ្ធភាពសំដៅលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់សមាជិកសហគមន៍ រួមចំណែកបង្កើនប្រាក់ចំណូលប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយភាពក្រីក្រ អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមដែលជម្រុញឱ្យប្រទេសជាតិមានការរីកចម្រើន និងអភិវឌ្ឍន៍ប្រកបដោយចីរភាព។[36]

- លើកកម្ពស់សេដ្ឋកិច្ចរបស់សមាជិក ៖ ដើម្បីឱ្យសមាជិកមានជីវៈភាពធូរធារ តាមរយៈការបង្កើនប្រាក់ចំណូលក្នុងគ្រួសារអាជីវកម្មកសិកម្ម។
- លើកកម្ពស់សង្គម ៖ បង្កើនសាមគ្គីភាព ធានានូវ សមភាព សមធម៌ និង ការជួយគ្នាទៅវិញទៅមកក្នុងសហគមន៍កសិកម្ម ព្រមទាំងចូលរួមអភិឌ្ឍន៍សង្គម។
- លើកតម្កើងវប្បធម៌ ៖ ចូលរួមគាំទ្រដល់កិច្ចការវប្បធម៌ ដូចជាការថែរក្សាប្រពៃណីរបស់ប្រជាកសិករ។

#### ២.៣.២. គោលបំណងរបស់សហគមន៍កសិកម្ម

សហគមន៍កសិកម្ម គឺជាសហគ្រាសអាជីវកម្ម ដែលដំណើរការដោយសមាជិកសម្រាប់ផលប្រយោជន៍ដល់សមាជិក។

តើសហគមន៍កសិកម្ម គួរផ្តល់ផលប្រយោជន៍ជូន សមាជិកយ៉ាងដូចម្តេច?

ចម្លើយ គឺ ផ្តល់ផលប្រយោជន៍តាមរយៈមុខរបររបស់សហគមន៍កសិកម្ម។

[36] សៀវភៅ ការគ្រប់គ្រងសហគមន៍កសិកម្មភ្នំដិន សែនសុខ, ២០១៤, ទំព័រទី ១១

សហគមន៍កសិកម្មពហុបំណងដែលចាត់ទុកថាជាសហគមន៍កសិកម្មគម្រូនៅប្រទេសកម្ពុជា ក៏ដូចជានៅ ប្រទេស ជប៉ុន ថៃ និងបណ្តាលប្រទេសនានានៅអាស៊ី ជាទូទៅប្រកប ( ក) មុខរបរឥណទាន (ខ) មុខផ្គត់ផ្គង់ (គ) មុខរបរទីផ្សារ ( ឃ ) មុខរបរផ្តល់សេវាប្រើប្រាស់រួមគ្នាដោយឯកឯង។

ជាទូទៅសហគមន៍កសិកម្មពហុបំណង ផ្តល់ផលប្រយោជន៍ដល់សមាជិកតាមវិធីដូចខាងក្រោម ៖

- ផ្តល់ប្រាក់កម្ចីដល់សមាជិកដោយអត្រាការប្រាក់ទាបជាងធនាគារឯកជន និងទីភ្នាក់ងារមីក្រូហិរញ្ញវត្ថុដែលនៅជិតៗនោះ ហើយនៅពេលដែលអត្រាការប្រាក់ដូចៗគ្នា សហគមន៍កសិកម្មផ្តល់ប្រាក់កម្ចីឱ្យបានលឿនជាង។
- ផ្តល់ការប្រាក់នៃប្រាក់បញ្ញើសន្សំខ្ពស់ជាង។
- ផ្គត់ផ្គង់ជី និងធាតុចូលកសិកម្មផ្សេងទៀតដល់សមាជិក ដោយតម្លៃទាបជាងហាងលក់ឯកជន ធានាគុណភាព និង បរិមាណដីបានត្រឹមត្រូវ។
- ទិញផលិតផលកសិកម្មពីសមាជិកដោយតម្លៃថ្លៃជាងឈ្មួញកណ្តាល ថ្លឹងផលិតផលកសិកម្មទិញពីសមាជិកដោយលក្ខណៈត្រឹមត្រូវ។
- ផ្តល់សេវាកម្មភ្ជួររាស់ស្រែដោយត្រាក់ទ័រ ដោយតម្លៃទាបជាងឈ្មួញឯកជន។[37]

សហគមន៍កសិកម្មភ្នំដិន សែនសុខ មានកម្មវត្ថុ ៖

១. ឥណទានកសិកម្មខ្នាតតូច និងប្រាក់សន្សំ

២. ទិញ-លក់សម្ភារៈកសិកម្ម

៣. ទិញ-លក់ស្រូវ និងលក់អង្ករ

៤. អាជីវកម្មរោងម៉ាស៊ីនកិនស្រូវ និងកែច្នៃកសិផល

៥. សេវាកម្ម ភ្ជួររាស់ ច្រូតកាត់ និងដឹកជញ្ជូន

៦. លក់ប្រេងឥន្ធនៈ

៧. កែច្នៃចំណីសត្វ លក់ចំណីសត្វ និងគ្រឿងបរិក្ខាបសុពេទ្យ

៨. ផលិតកម្ម អាជីវកម្ម ចិញ្ចឹមសត្វ

៩. លក់គ្រឿងឧបភោគ បរិភោគ

១០. សេវាកម្មរោងការ រោងបុណ្យ ។

[37] *សៀវភៅ គោលការណ៍ណែនាំស្តីពី ការបែងចែកប្រាក់ចំណេញរបស់សហគមន៍កសិកម្មនៅប្រទេសកម្ពុជា*, ២០១៦

### ២.៣.៣. សកម្មភាពរបស់សហគមន៍

សកម្មភាពរបស់សហគមន៍កសិកម្មភ្នំដិនសែនសុខ រួមមាន ៖

- ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីសហគមន៍
- ផ្សព្វផ្សាយពីសារៈប្រយោជន៍ នៃសហគមន៍ តាមរយៈការធ្វើមហាសន្និបាតជាមួយប្រជាពលរដ្ឋ
- ផ្ដល់ឱ្យសមាជិករបស់ខ្លួននូវព័ត៌មានបុគ្គលសំខាន់ៗសម្រាប់ទាក់ទងពីការអនុវត្តដែលប្រសើរបំផុត
- ផ្ដល់នូវជំនួយបច្ចេកទេសដល់សហគមន៍
- ចងក្រងបណ្ដាញសហគមន៍នៅក្នុងតំបន់ និងធ្វើសន្និបាតប្រជុំបណ្ដាញ
- រៀបចំវេទិកាសន្និបាតពិគ្រោះយោបល់ជាមួយប្រជាជនដោះស្រាយបញ្ហា
- ចូលរួមបង្កើនទិន្នផលកសិកម្មដើម្បីបំពេញតម្រូវការទីផ្សារ
- ផ្ដល់សេវាឥណទានដល់ប្រជាជននូវអត្រាការប្រាក់ទាប និងរំលោះរហូតដល់ពេលប្រមូលផល
- បង្ហាត់បង្ហាញពីបច្ចេកទេសក្នុងដំណើរការផលិតកម្មកសិកម្មបែបទំនើប។

ដើម្បីសម្រេចបានទិសដៅឆ្ពោះទៅរកជោគជ័យសហគមន៍កសិកម្មភ្នំដិន សែនសុខបានអនុវត្តន៍សកម្មភាពដូចខាងក្រោម ៖

**១. មុខរបរឥណទានសហគមន៍កសិកម្ម**

គឺជាមុខរបរដែលសហគមន៍កសិកម្ម ទទួលប្រាក់សន្សំពីសមាជិកដោយផ្ដល់អត្រាការប្រាក់ ស្មើ ឬខ្ពស់ជាងក្រុមហ៊ុន និង ផ្ដល់ប្រាក់កម្ចីទៅដល់សមាជិកជាមួយអត្រាប្រាក់ទាបជាង ឬស្មើក្រុមហ៊ុនឯកជន។

**២. មុខរបរទីផ្សារ**

គឺជាមុខរបរ ដែលសហគមន៍កសិកម្មប្រមូលទិញកសិផល ឬផលិតផលផ្សេងៗពីសមាជិក រួចលក់បន្តទៅដល់រោងចក្រ អ្នកនាំចេញ ឬទៅដល់អ្នកប្រើប្រាស់ផ្ទាល់។មុខរបរនេះអាចឱ្យកសិករស្វែងរកបានទីផ្សារ និងមានអំណាចក្នុងការចចារអំពីតម្លៃដើម្បីលក់ផលិតផលនានាបានតម្លៃខ្ពស់។

ឧទាហរណ៍៖សហគមន៍កសិកម្មប្រមូលទិញស្រូវផ្ការំដួលពីសមាជិកបានចំនួន ១០០តោន រួចលក់ទៅឱ្យអ្នកនាំស្រូវទៅលក់នៅបរទេសដោយផ្ទាល់បានតម្លៃមួយខ្ពស់ជាងកសិករម្នាក់ៗលក់ទៅឱ្យឈ្មួញកណ្ដាល។

**៣.មុខរបរផ្គត់ផ្គង់**

គឺជាមុខរបរ ដែលសហគមន៍កសិកម្មទិញទំនិញផ្សេងៗ ដូចជាជីកសិកម្ម ថ្នាំកសិកម្ម ប្រេងម៉ាស៊ូត ដើម្បីលក់បន្តទៅដល់សមាជិក។ មុខរបរនេះធ្វើឱ្យកសិករមានអំណាច ក្នុងការចចារទិញផលិតផលនានាប្រកបដោយគុណភាពក្នុងតម្លៃសមរម្យ និងឈានទៅដល់ការកាត់បន្ថយតម្លៃផលិតកម្មកសិកម្ម។

ឧទាហរណ៍ ៖ សហគមន៍កសិកម្មបានទិញជីកសិកម្មដុំចំនួនម្ភៃ( ២០) តោន យកមកលក់រាយជូនសមាជិក ក្នុងតម្លៃទាបជាងអ្នករាយនៅក្នុងតំបន់។

**៤. មុខរបរប្រើប្រាស់រួម**

គឺជាមុខរបរដែលសហគមន៍កសិកម្ម ទិញឧបករណ៍កសិកម្ម គ្រឿងចក្រកសិកម្ម ឬសាងសង់ឃ្លាំងដើម្បីជួល ឬផ្តល់សេវាដល់សមាជិក។ មុខរបរនេះអាចផលិតផលិតផល ឬផ្តល់សេវាកម្មនានាដែលកសិករម្នាក់ៗមិនអាចធ្វើបាន។

ឧទាហរណ៍ ៖ សហគមន៍កសិកម្មទិញម៉ាស៊ីនច្រូតស្រូវដើម្បីផ្តល់សេវាកម្មគាំទ្រ ដល់ការងារប្រមូលផលស្រូវរបស់សមាជិក ដែលមិនមានលទ្ធភាពទិញយកមកប្រើប្រាស់ដោយខ្លួនឯង ដោយយកប្រាក់ឈ្នួលទាបជាងក្រុមហ៊ុនឯកជន។

### ២.៣.៤. ឈ្មោះ និងស្លាកសញ្ញារបស់សហគមន៍

**រូបភាពទី ១ ៖ ឈ្មោះ និងស្លាកសញ្ញារបស់សហគមន៍កសិកម្មភ្នំដិនសែនសុខ**




ប្រភព ៖ សៀវភៅ ការគ្រប់គ្រងសហគមន៍កសិកម្មភ្នំដិន សែនសុខ

## ២.៤. រចនាសម្ព័ន្ធ ការបែងចែក សិទ្ធិ និង តួនាទីភារកិច្ច

### ២.៤.១. រចនាសម្ព័ន្ធសហគមន៍កសិកម្ម

រចនាសម្ព័ន្ធសហគមន៍កសិកម្មភ្នំដិន សែនសុខមាន ៖

- មហាសន្និបាត
- ក្រុមប្រឹក្សាភិបាល
- គណៈកម្មាធិការត្រួតពិនិត្យ

**រូបភាពទី ២ ៖ រចនាសម្ព័ន្ធគណៈកម្មាធិការសហគមន៍កសិកម្មភ្នំដិន សែនសុខ**




ប្រភព ៖ រូបភាពថតដោយនៅការិយាល័យសហគមន៍កសិកម្មភ្នំដិន សែនសុខ

### ២.៤.២. ការបែកចែកសិទ្ធិ តួនាទីភារកិច្ច

➢ **មហាសន្និបាតសហគមន៍កសិកម្ម**

នៅក្នុងរចនាសម្ព័ន្ធសហគមន៍កសិកម្ម មហាសន្និបាតរបស់សមាជិក គឺជាអង្គភាពមួយដ៏សំខាន់។មហាសន្និបាតនេះរួមមាន បុគ្គលទាំងអស់ទទួលស្គាល់ជាផ្លូវការ បន្ទាប់ពីការបង់ថ្លៃសេវាសមាជិករបស់ខ្លួនរួច និងបានចូលភាគហ៊ុន។ បុគ្គលទាំងនេះត្រូវបានហៅថាសមាជិក និងមានសិទ្ធិ " បោះឆ្នោត " ដោយផ្អែកលើគោលការណ៍ " សមាជិក១ សន្លឹកឆ្នោត១" យោងតាមគោលការណ៍សហគមន៍កសិកម្ម។ សហគមន៍មានស្វ័យភាព និងឯករាជ្យភាពមិនពាក់ព័ន្ធជួររដ្ឋាភិបាល។

មហាសន្និបាត គឺជាស្ថាប័នជាខ្ពស់ ដែលដាក់ចេញនូវគោលការណ៍ និងកម្មវិធីសម្រាប់ស្ថាប័នសហគមន៍កសិកម្ម។ ដើម្បីអនុវត្តគោលការណ៍នេះ ស្ថាប័នដឹកនាំបោះឆ្នោតជ្រើសរើសគណៈកម្មាធិការត្រួតពិនិត្យ/ក្រុមប្រឹក្សាភិបាល និង គណៈកម្មាធិការផ្សេងទៀត។ ពួកគាត់ត្រូវឆ្លើយសំណួរទៅកាន់មហាសន្និបាត។ បន្ទាប់មកគណៈកម្មាធិការត្រួតពិនិត្យត្រូវបានប្រគល់សិទ្ធិឱ្យ ជ្រើសរើសបុគ្គលិក។ កិច្ចប្រជុំមហាសន្និបាតមានច្រើនទម្រង់ដូចខាងក្រោម៖

- កិច្ចប្រជុំមហាសន្និបាតសាមញ្ញាប្រចាំឆ្នាំ កត់សម្គាល់អំពីវិវឌ្ឍនភាពការងារ ដែលសម្រេចបាន និងដាក់ចេញនូវវិធានការណ៍សម្រាប់អនុវត្ត
- កិច្ចប្រជុំមហាសន្និបាតពិសេស បន្ថែមលើការងាររបស់កិច្ចប្រជុំស្ថាប័នថ្នាក់ដឹកនាំសាមញ្ញាបោះឆ្នោតជ្រើសរើសមន្ត្រីទទួលបន្ទុក
- កិច្ចប្រជុំមហាសន្និបាតវិសាមញ្ញ ធ្វើវិសោធនកម្មលក្ខន្តិកៈ
- កិច្ចប្រជុំមហាសន្និបាតតាមការស្នើសុំ ត្រូវបានស្នើដោយសមាជិក ឬ អ្នកចុះបញ្ជីសហគមន៍កសិកម្ម ដើម្បីធ្វើការប្តេជ្ញាចិត្តលើបញ្ហាជាក់លាក់ ។

❖ មុខងារសំខាន់របស់មហាសន្និបាតមានដូចខាងក្រោម ៖

- ក្នុងនាមជាស្ថាប័នជាន់ខ្ពស់នៅក្នុងរចនាសម្ព័ន្ធសហគមន៍កសិកម្ម មហាសន្និបាតទូទៅដាក់ចេញនូវគោលនយោបាយ អនុម័តលើកម្មវិធី និងជ្រើសរើសគណៈកម្មាធិការ
- ការប្រជុំនេះត្រូវបានដឹកនាំដោយប្រធានមហាសន្និបាត ហើយប្រសិនបើប្រធានមហាសន្និបាតអវត្តមាន ត្រូវបានដឹកនាំដោយអនុប្រធានមហាសន្និបាត
- ប្រធានមហាសន្និបាត ឬ បុគ្គលដែលដឹកនាំកិច្ចប្រជុំ មានសំឡេងឆ្នោតមួយ ក្នុងករណីដែលមានទំនាក់ទំនង។

❖ សិទ្ធិអំណាចរបស់មហាសន្និបាត

- បោះឆ្នោតជ្រើសរើស ព្យួរការងារ និងដកសិទ្ធិសមាជិកជាប់ឆ្នោតចេញពីគណៈកម្មាធិការត្រួតពិនិត្យ
- ពិចារណាលើរបាយការណ៍ប្រចាំឆ្នាំ របាយការណ៍សវនកម្ម គណនេយ្យចំណេញ ខាត និងកំណត់សម្គាល់អធិការកិច្ច
- កំណត់កម្រិតឥណទានជាអតិបរមា របស់សមាជិកម្នាក់ៗ
- ធ្វើវិសោធនកម្មលក្ខន្តិកៈ រាល់អាជីវកម្មទាំងអស់ដែលបានពិភាក្សា ឬ បានសម្រេចនៅក្នុងកិច្ចមហាសន្និបាត ត្រូវកត់ត្រានៅក្នុងបញ្ជីនីតិវិធី ដែលត្រូវចុះហត្ថលេខា ដោយប្រធានអង្គប្រជុំ។ រាល់សេចក្ដីសម្រេចទាំងអស់របស់មហាសន្និបាត ត្រូវភ្ជាប់កាតព្វកិច្ចទៅឱ្យសមាជិកសហគមន៍កសិកម្មទាំងអស់មិនថាឡើយពួកគាត់មិនបានបោះឆ្នោតគាំទ្រ ឬ មិនគាំទ្រនោះទេ។

➢ **ភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្មភ្នំដិន សែនសុខ**

ក្រុមប្រឹក្សាភិបាល ជាអង្គការប្រតិបត្តិរបស់សហគមន៍។ ប្រធាន ព្រមទាំងសមាជិកដទៃទៀតនៃក្រុមប្រឹក្សាភិបាលត្រូវជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោមសមាជិកសហគមន៍ នាពេលមហាសន្និបាតសម្រាប់អាណត្តិប្រាំ (៥) ឆ្នាំ ។ ឪពុកម្ដាយ បងប្អូនបង្កើត បងប្អូនជីដូនមួយ ប្ដី ប្រពន្ធ ពុំអាចធ្វើជា សមាជិកក្រុមប្រឹក្សាភិបាលជាមួយគ្នាបានទេ។ ក្រុមប្រឹក្សាភិបាលត្រូវបានបោះឆ្នោតជ្រើសរើសសម្រាប់ អាណត្តិប្រាំ (៥) ឆ្នាំ ហើយអាចត្រូវបានជ្រើសរើសបន្តទៀត បើមានការគាំទ្រពីសមាជិក ។

សមាសភាពមានដូចជា ៖

- ប្រធាន
- អនុប្រធាន
- សមាជិក
- លេខាធិការ
- ហិរញ្ញិក
- ក្រុមប្រឹក្សាភិបាលជ្រើសរើសដោយការបោះឆ្នោតជាសម្ងាត់ ឱ្យទទួលជាហេរញ្ញិកម្នាក់ និងជាលេខាធិការម្នាក់ ក្នុងចំណោមសមាជិករបស់ខ្លួន បើក្នុងចំណោម សមាជិកក្រុមប្រឹក្សាភិបាលមិនអាចរើសបានអាចរើសបាន អាចជ្រើសរើសពីសមាជិក បន្ថែមបាន ។

❖ មុខងារសំខាន់ៗរបស់ក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្មរួមមាន ៖

- កាន់ ឬបញ្ជាឱ្យកាន់បញ្ជីសមទិន ព្រមទាំងធ្វើឱ្យកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់សហគមន៍បានដំណើរការល្អប្រសើរ
- ត្រូវធ្វើគណនេយ្យភាពដោយឡែកពីគ្នា ចំពោះប្រតិបត្តិការជួញដូរ ជាមួយសមាជិក និង ជាមួយអ្នកមិនមែនជាសមាជិកសហគមន៍
- រៀបចំការប្រជុំមហាសន្និបាត
- រាយការណ៍ជូនមហាសន្និបាតនូវរបាយការណ៍ស្តីពី ការគ្រប់គ្រងនៃកាលបរិច្ឆេទកន្លងទៅ ដែលមានរបាយការណ៍ប្រចាំឆ្នាំស្តីពី សកម្មភាព តារាងតុល្យការ និង គណនី អាជីកម្ម ហើយ កម្មវិធីសកម្មភាពបណ្តុះបណ្តាលសមាជិក ព្រមទាំងថវិកា និង គម្រោងសម្រាប់កាលបរិច្ឆេទ នាពេលខាងមុខ
- រៀបចំឯកសារចាំបាច់ដទៃទៀតសម្រាប់ដាក់ជូនមហាសន្និបាត
- រៀបចំមហាសន្និបាតវិសាមញ្ញ នៅពេលដែលសមាជិកសហគមន៍បានស្នើសុំកោះប្រជុំ
- សមាជិកក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវរៀងៗខ្លួន និង រួមគ្នាផងចំពោះកំហុស ដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញបេសកកម្ម ដោយមិនទាន់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ ។

❖ **តួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្មភ្នំដិន សែនសុខ ៖**

➢ **ប្រធាន**

ទទួលភារៈកិច្ចក្តាប់រួម និង ការងារដូចខាងក្រោម ៖

- ដឹកនាំធ្វើការប្រជុំសាមញ្ញ និងវិសាមញ្ញ ប្រចាំឆ្នាំ ឬនៅពេលដែលសមាជិកសហគមន៍ស្នើសុំ
- ដឹកនាំការប្រជុំ ក្រុមប្រឹក្សាភិបាលរយៈពេល ២ ខែម្តង ឬតាមការស្នើសុំរបស់សមាជិក
- ដឹកនាំធ្វើផែនការការងាររបស់សហគមន៍ និង បែងចែកការទទួលខុសត្រូវ
- ដឹកនាំគ្រប់គ្រងរាល់ការធ្វើជំនួញ ការងារឥណទាននៅក្នុងសហគមន៍ឱ្យមានប្រសិទ្ធភាព
- គ្រប់គ្រងព័ត៌មានទីផ្សារ ព័ត៌មានសហគមន៍ ព័ត៌មានកសិកម្ម ដើម្បីផ្សព្វផ្សាយ
- ទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ និង គ្រប់អង្គការអន្តរជាតិ ដើម្បីស្វែងរកការគាំទ្រទុនបន្ថែម និងការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់សមាជិក ។

➢ **អនុប្រធាន**

- ជំនួយប្រធានក្នុងការងាររដ្ឋបាល គ្រប់គ្រងសហគមន៍ និង ការធ្វើជំនួញ
- ទំនាក់ទំនងជាមួយទីផ្សារ ដើម្បីទិញសម្ភារៈកសិកម្មមកលក់ក្នុងសហគមន៍
- គ្រប់គ្រងចាត់ចែង សកម្មភាពលក់សម្ភារៈ និង ទិញ-លក់ ផលិតផលកសិកម្ម
- ធ្វើរបាយការណ៍ពីសកម្មភាពការងារធ្វើជំនួញជូនប្រធាន ។

➢ **សមាជិក**

- គ្រប់គ្រងចាត់ចែង សកម្មភាពធ្វើឥណទានដល់សមាជិកសហគមន៍ និងក្រៅសហគមន៍
- ទំនាក់ទំនងជាមួយសមាជិកសហគមន៍ និង ក្រៅសហគមន៍ ដើម្បីផ្សព្វផ្សាយសកម្មភាពបញ្ញើប្រាក់ក្នុងសហគមន៍
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារឥណទានជូនប្រធាន ។

➢ **ហិរញ្ញិក**

- រៀបចំបញ្ជីអចលនៈទ្រព្យ និង ចលនៈទ្រព្យរបស់សហគមន៍ប្រចាំឆ្នាំ
- ប្ញូកសរុបបញ្ជី ឯកសារ ហិរញ្ញវត្ថុក្នុងសហគមន៍
- ត្រួតពិនិត្យបញ្ជីនៃការធ្វើជំនួញ និង បញ្ជីធ្វើឥណទានក្នុងសហគមន៍
- រៀបចំបែងចែកការ ចំណេញ-ខាត ចែកជូនដល់សមាជិក
- ធ្វើរបាយការណ៍ពីស្ថានភាពហិរញ្ញវត្ថុ ដល់ ប្រធាន សមាជិកក្រុមប្រឹក្សាភិបាល និង គណៈកម្មាធិការត្រួតពិនិត្យរបស់សហគមន៍ ។

➢ **លេខាធិការ**

- គ្រប់គ្រងការងាររដ្ឋបាល និង ឯកសាររបស់សហគមន៍
- រៀបចំធ្វើរបាយការណ៍សហគមន៍ប្រចាំ ត្រីមាស និង ឆ្នាំ
- ជួយប្រធានក្នុងការរៀបចំការប្រជុំសាមញ្ញ និង វិសាមញ្ញ របស់សហគមន៍ ។

❖ ***ភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្មភ្នំជិន សែនសុខរួមមាន ៖***

- អនុវត្តគោលការណ៍ ដែលបានដាក់ចេញដោយមហាសន្និបាត
- ធានាថា សហគមន៍កសិកម្មនេះ មិនខកខានក្នុងការសងបំណុល ឬមិនក្លាយជាបុគ្គលជាប់បំណុល
- ធានាថា សមាជិកគណៈកម្មាធិការ មិនប្រកបអាជីវកម្មដូចគ្នាទៅនឹងសហគមន៍កសិកម្ម

- ធានាថា សមាជិកចូលរួមក្នុងកិច្ចប្រជុំទាំងអស់របស់គណៈកម្មាធិការត្រួតពិនិត្យ
- ទទួលសិក្សា វិភាគរបាយការណ៍សវនកម្ម និងរបាយការណ៍អធិការកិច្ចឱ្យបានគ្រប់ជ្រុងជ្រោយ
- ចាត់វិធានការលើការជំទាស់ណាមួយដែលបានលើឡើង និងការផ្តល់មតិយោបល់/ ការស្នើសុំរបស់សមាជិក
- យល់ដឹងអំពីការផ្លាស់ប្តូរ និងការអភិវឌ្ឍន៍ថ្មីៗ នៅក្នុងច្បាប់ វិធាន បទប្បញ្ញត្តិ និងគោលការណ៍ណែនាំស្តីពីសហគមន៍កសិកម្ម
- យល់ដឹងអំពីសៀវភៅ ផែនការបង្កើតអាជីវកម្ម គម្រោង និង ថវិការបស់សហគមន៍
- ទទួល វិភាគ និងអនុម័ត / បដិសេធការអនុវត្តឥណទានរបស់សមាជិក
- បើកិច្ចប្រជុំទាំងអស់ឱ្យបានទាន់ពេលវេលា និងការរៀបចំការបោះឆ្នោត
- ព្រមានឬចាត់វិធានកាលើសមាជិកដែលបានខ្ចីឥណទាន ប៉ុន្តែមិនបានសងវិញទាន់ពេលវេលា
- ធានាថា រាល់ការសម្រេចចិត្ត ផ្នែកធុរកិច្ចទាំងអស់ ដែលត្រូវរក្សាការសម្ងាត់ មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ
- ទទួលការស្នើសុំពីសមាជិក និងដោះស្រាយបញ្ហារបស់ពួកគាត់
- រក្សាទំនាក់ទំនាក់ជិតស្និទ្ធជាមួយ នាយកដ្ឋានអភិវឌ្ឍសហគមន៍កសិកម្ម និងធនាគារសហគមន៍ ក៏ដូចជាស្ថាប័នពាក់ព័ន្ធនៅក្នុងតំបន់
- ទប់ស្កាត់ការទាញយកផលប្រយោជន៍ខ្លួន និងធានាថាបន្ទុកចំណាយផ្ទាល់ខ្លួនមិនត្រូវឱ្យលាយលំសហគមន៍កសិកម្មឡើយ។
- អនុវត្តគោលការណ៍ ដែលបានដាក់ចេញដោយមហាសន្និបាត
- ធានាថាសហគមន៍កសិកម្មនេះមិនខកខានក្នុងការសងបំណុល ឬមិនក្លាយជាបុគ្គលជាប់បំណុល
- ធានាថា សមាជិកគណៈកម្មាធិការ មិនប្រកបអាជីវកម្មដូចគ្នាទៅនឹងសហគមន៍កសិកម្ម
- ធានាថា សមាជិកចូលរួមក្នុងកិច្ចប្រជុំទាំងអស់របស់គណៈកម្មាធិការត្រួតពិនិត្យ
- ទទួលសិក្សា វិភាគរបាយការណ៍សវនកម្ម និងរបាយការណ៍អធិការកិច្ចឱ្យបានគ្រប់ជ្រុងជ្រោយ

- ចាត់វិធានការលើការជំទាស់ណាមួយដែលបានលើឡើង និងការផ្តល់មតិយោបល់/ ការស្នើសុំរបស់សមាជិក
- យល់ដឹងអំពីការផ្លាស់ប្តូរ និងការអភិវឌ្ឍន៍ថ្មីៗ នៅក្នុងច្បាប់ វិធាន បទប្បញ្ញត្តិ និងគោលការណ៍ណែនាំស្តីពីសហគមន៍កសិកម្ម
- យល់ដឹងអំពីសៀវភៅ ផែនការបង្កើតអាជីវកម្ម គម្រោង និង ថវិការបស់សហគមន៍
- ទទួល វិភាគ និងអនុម័ត / បដិសេធការអនុវត្តឥណទានរបស់សមាជិក
- បើកិច្ចប្រជុំទាំងអស់ឱ្យបានទាន់ពេលវេលា និងការរៀបចំការបោះឆ្នោត
- ព្រមាន ឬចាត់វិធានកាលើសមាជិកដែលបានខ្ចីឥណទានប៉ុន្តែមិនបានសងវិញទាន់ពេលវេលា
- ធានាថា រាល់ការសម្រេចចិត្ត ផ្នែកធុរកិច្ចទាំងអស់ ដែលត្រុវរក្សាការសម្ងាត់ មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ
- ទទួលការស្នើសុំពីសមាជិក និងដោះស្រាយបញ្ហារបស់ពួកគាត់
- រក្សាទំនាក់ទំនាក់ជិតស្និទ្ធជាមួយនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម និងធនាគារសហគមន៍ ក៏ដូចជាស្ថាប័នពាក់ព័ន្ធនៅក្នុងតំបន់
- ទប់ស្កាត់ការទាញយកផលប្រយោជន៍ខ្លួន និងធានាថា បន្ទុកចំណាយផ្ទាល់ខ្លួនមិនត្រូវឱ្យលាយលំសហគមន៍កសិកម្មឡើយ។

❖ **លក្ខខណ្ឌនៃការកោះប្រជុំក្រុមប្រឹក្សាភិបាល ៖**

- ប្រធានក្រុមប្រឹក្សាភិបាល ជាតំណាងសហគមន៍មានសិទ្ធកោះប្រជុំ ក្រុមប្រឹក្សាភិបាលមួយ (១) ខែម្តង
- ប្រធានក្រុមប្រឹក្សាភិបាល អាចកោះប្រជុំបាន តាមសំណើររបស់សមាជិកភាគច្រើនរបស់ខ្លួន ឬ ក្នុងករណីបន្ទាន់ចាំបាច់
- ក្រុមប្រឹក្សាភិបាលអាចប្រជុំបាន លុះត្រាតែមានសមាជិកវត្តមានពាក់កណ្តាល នៃសមាជិករបស់ខ្លួន
- សេចក្តីសម្រេចរបស់អង្គប្រជុំដែលចាត់ទុកជាបានការ គឺភាគច្រើនដាច់ខាតនៃសមាជិកវត្តមាន ។

- ក្រុមប្រឹក្សាភិបាលក្រោយពីការពិគ្រោះយោបល់ ជាមួយគណៈកម្មាធិការត្រួតពិនិត្យ អាចជ្រើសរើស និង តែងតាំងនាយកគ្រប់គ្រងម្នាក់ពីបុគ្គលិកមានបៀវត្ស ដែលមានភារកិច្ចជួយក្រុមប្រឹក្សាភិបាលក្នុងភារកិច្ចគ្រប់គ្រងសហគមន៍ និង ចូលរួមក្នុងកិច្ចប្រជុំរបស់ ក្រុមប្រឹក្សាភិបាលដោយមានសំឡេងត្រឹមតែជាយោបល់ ។

➢ **ភារកិច្ចរបស់គណៈកម្មាធិការត្រួតពិនិត្យសហគមន៍ភ្នំជិន សែនសុខ**

គណៈកម្មាធិការត្រួតពិនិត្យ ជាអង្គការត្រួតពិនិត្យអចិន្ត្រៃយ៍ផ្ទៃក្នុងសហគមន៍ ។ គណៈកម្មធិការនេះ ធ្វើការសម្រាប់តែផលប្រយោជន៍របស់សហគមន៍តែម្យ៉ាង ។ ប្រធានគណៈកម្មធិការត្រួតពិនិត្យ ត្រូវបោះឆ្នោតជ្រើសរើសពីចំណោមសមាជិករបស់ខ្លួន ។ គណៈកម្មធិការត្រួតពិនិត្យអាចព្យួរតួនាទីក្រុមប្រឹក្សាភាបាលបាន ។ ក្នុងករណីដែលក្រុមប្រឹក្សាភិបាល ពុំព្រមធ្វើតាម ឬ ស្ថិតក្នុង អលទ្ធភាព ចំពោះការបំពេញកាតព្វកិច្ចរបស់ខ្លួន គណៈកម្មាធិការត្រួតពិនិត្យ អាចជំនួសបំពេញតួនាទី ក្រុមប្រឹក្សាភិបាលបាន តែមិនឱ្យលើសពី បី (៣) ខែទេ។ នៅក្នុងរយៈពេលនោះគណៈកម្មាធិការត្រួតពិនិត្យត្រូវកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីជ្រើសរើសក្រុមប្រឹក្សារភិបាលថ្មី ។ គណៈកម្មាធិការត្រួតពិនិត្យមានសមាជិកចំនួនពីបី (៣) ទៅប្រាំ (៥) នាក់ជាសមាជិកដែលពុំ មានឈ្មោះនៅក្នុងក្រុមប្រឹក្សាភិបាល ឬ បុគ្គលិកមានបៀវត្សរបស់សហគមន៍ឡើយ ។ បុគ្គលដែលត្រូវជាឪពុកម្តាយ បងប្អូនបង្កើត បងប្អូនជីដូនមួយ ប្តីប្រពន្ធ ជាមួយនឹងសមាជិកក្រុមប្រឹក្សាភិបាល ពុំអាច ធ្វើជាសមាជិកនៃគណៈកម្មាធិការត្រួតពិនិត្យបានទេ ។

សមាសភាពរួមមាន ៖

- ប្រធានទទួលបន្ទុករួម
- អនុប្រធាន
- សមាជិក ។

អាណត្តិរបស់សមាជិកគណៈកម្មាធិការត្រួតពិនិត្យ ត្រូវកំណត់ប្រាំ (៥) ឆ្នាំ ។ សមាជិកម្នាក់ៗ អាចបម្រើការងារនេះបន្តរហូត បើមានការគាំទ្រពីសមាជិក ។ គណៈកម្មាធិការត្រួតពិនិត្យរួមប្រជុំគ្នា តាមការកោះប្រជុំរបស់ប្រធាននៅពេលណាមួយមានការចាំបាច់ ឬតាមសំណូមពររបស់សមាជិកយ៉ាងតិចពីរ (២) នាក់ ។ ក្នុងករណីមានការចែកសំឡេងជាពីរស្មើគ្នា សម្លេង របស់ប្រធានមានអនុភាព ។

❖ **គណៈកម្មាធិការត្រួតពិនិត្យត្រូវមានសិទ្ធិ និង បំពេញភារកិច្ចដូចខាងក្រោម៖**

- ត្រួតពិនិត្យ ឬ បញ្ជាឱ្យត្រួតពិនិត្យសៀវភៅធំគណនេយ្យ និង សៀវភៅគណនេយ្យផ្សេងទៀតរបស់សហគមន៍កសិកម្ម

- ត្រួតពិនិត្យ ឬ បញ្ជាឱ្យត្រួតពិនិត្យរាល់ទ្រព្យសកម្ម និង បំណុលរបស់សហគមន៍កសិកម្ម
- ត្រួតពិនិត្យបញ្ជីសារពើភណ្ឌ និងតារាងតុល្យការ តាមការចាំបាច់
- បញ្ជូនលទ្ធផលដែលរកឃើញទៅក្រុមប្រឹក្សាភិបាល និង បញ្ជូនលទ្ធផលទាំងនោះចូលទៅក្នុងរបាយការណ៍ការប្រចាំឆ្នាំ ដើម្បីដាក់ជូនអង្គមហាសន្និបាត។

❖ **ភារកិច្ចរបស់អ្នកគ្រប់គ្រង/នាយកប្រតិបត្តិ និងបុគ្គលិកផ្សេងៗ៖**

- បម្រើសហគមន៍កសិកម្ម ក្នុងនាមជាបុគ្គលិកឧស្សាហ៍ព្យាយាម ស្មោះត្រង់ និងមានការតាំងចិត្តខ្ពស់
- ផ្តល់ការណែនាំ ដំបូន្មាន និងការគាំទ្រទៅដល់គណៈកម្មាធិការត្រួតពិនិត្យ
- យល់ដឹង អាចផ្តល់ព័ត៌មានអំពីច្បាប់វិធាន បទបញ្ញត្តិស្តីពីសហគមន៍កសិកម្មឱ្យបានគ្រប់ជ្រុងជ្រោយ និងបទបញ្ញត្តិលក្ខន្តិកៈទៅឱ្យមន្ត្រីទទួលបន្ទុកសហគមន៍
- ថែរក្សា រៀបចំទុកដាក់សៀវភៅគណនេយ្យ សាច់ប្រាក់ និង សន្និធិ ព្រមទាំងសេវាកម្មនិងមុខរបរផ្សេងៗទាំងអស់របស់សហគមន៍កសិកម្ម
- រៀបចំផែនការ ការបង្កើតអាជីវកម្ម គម្រោងថវិកា របាយការណ៍ចំណូល ចំណាយរបស់សហគមន៍កសិកម្ម និងដាក់ជូនរបាយការណ៍ប្រចាំខែ របាយការណ៍ប្រចាំត្រីមាស និងរបាយការណ៍ប្រចាំឆ្នាំ
- រក្សា និងធ្វើបច្ចុប្បន្នភាពសៀវភៅប្រាក់បញ្ញើ និងគណនីផ្ទាល់ខ្លួនទាំងអស់របស់សមាជិក
- កំណត់កម្រិតឥណទានអតិបរមា របស់សមាជិក ដូចមានចែងក្នុងបទបញ្ញត្តិរបស់ធនាគារសហគមន៍ និងដាក់ឱ្យគណៈកម្មាធិការត្រួតពិនិត្យ និង មហាសន្និបាតធ្វើការអនុម័ត
- រៀបចំបញ្ជីសមាជិកដែលខកខានក្នុងការសងបំណុល និងអនុវត្តតាមបែបបទសម្រាប់ការទារបំណុល
- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការទាំងអស់ លើកលែងតែករណីពិចារណាលើតម្លៃ និងសេវាកម្មរបស់បុគ្គលមួយចំនួន
- ធានាថា អ្នកគ្រប់គ្រងមិនទុកសៀវភៅបញ្ជីប្រាក់បញ្ញើ និងចុះហត្ថលេខាលើសៀវភៅមូលប្បទានបត្ររបស់សមាជិក
- ចេញបង្កាន់ដៃបង់ប្រាក់ទៅឱ្យសមាជិកសម្រាប់ចំណាយទាំងអស់របស់សមាជិក
- ធ្វើការត្រួតពិនិត្យលើទ្រព្យសកម្ម និងបំណុលទាំងអស់របស់សហគមន៍កសិកម្ម

- ធ្វើការផ្ទៀងផ្ទាត់ជាក់ស្តែងលើបញ្ជីសារពើភណ្ឌទាំងអស់ ដូចជាអចនទ្រព្យ ឃ្លាំងស្តុកទំនិញ ម៉ាស៊ីន និងឧបករណ៍ការិយាល័យ
- សុំការឯកភាពលើការរក្សា "សាច់ប្រាក់ក្នុងដៃ" និងសាច់ប្រាក់លើស ដើម្បីយកទៅផ្ញើនៅធនាគារ
- គ្រប់គ្រងត្រារបស់សហគមន៍កសិកម្ម ឧបករណ៍/សម្ភារៈផ្សេងទៀត សម្រាប់ការទូទាត់សរសេរបញ្ជីប្រាក់ចេញចូល និង សៀវភៅធំរាល់ថ្ងៃច័ន្ទ
- តម្កល់មូលប្បទានបត្រទាំងអស់របស់សហគមន៍កសិកម្ម នៅធនាគារ និងរក្សាគណនីទាំងនោះឱ្យបានត្រឹមត្រូវ
- រៀបចំផ្ទៀងផ្ទាត់គណនីរបស់សហគមន៍ជាមួយធនាគារសហគមន៍កសិកម្ម
- ធានាថារាល់ការទូទាត់ទៅឱ្យអ្នកលក់ និង សមាជិកត្រូវបានធ្វើឡើងទាន់ពេលវេលា
- រៀបចំរបៀបវារៈ កំណត់ហេតុរបៀបវារៈ កំណត់ហេតុកិច្ចប្រជុំ និងរៀបចំការអនុម័តពីគណៈកម្មាធិការត្រួតពិនិត្យ
- រៀបចំតារាងតុល្យការរបស់សហគមន៍កសិកម្ម និង ដាក់ជូនគណៈកម្មាធិការត្រួតពិនិត្យធ្វើការអនុម័ត
- រៀបចំបញ្ជីសមាជិកដែលខកខានក្នុងការសងប្រាក់ និងចេញសេចក្តីជូនដំណឹងអំពីការទារបំណុល
- រៀបចំលក្ខខណ្ឌការងារ សម្រាប់និយោជិតទាំងអស់
- ជួយបង្កើតទំនាក់ទំនងជិតស្និទ្ធរាក់ទាក់គួរសមរវាងសមាជិកនិងគណៈកម្មាធិការត្រួតពិនិត្យ

❖ **សិទ្ធិរបស់អ្នកគ្រប់គ្រង**

- ប្រើប្រាស់សម្ភារៈទាំងអស់ ដែលផ្តល់ឱ្យសហគមន៍អាចជួយឱ្យអ្នកគ្រប់គ្រងបំពេញមុខងាររបស់ខ្លួនដោយត្រឹមត្រូវ
- ស្នើសុំការកែលម្អប្រតិបត្តិការរបស់សហគមន៍ និង លក្ខខណ្ឌការងាររបស់និយោជិត ។

➢ **សិទ្ធិ និងភារកិច្ចរបស់សមាជិកសហគមន៍កសិកម្ម**

❖ ***ភារកិច្ចសមាជិកមានដូចខាងក្រោម ៖***

- ចូលរួមគ្រប់មហាសន្និបាតទាំងអស់
- ប្រតិបត្តិគ្រប់ការផ្គង់ផ្គត់ និងការធ្វើទីផ្សារអាជីវកម្មជាមួយ/ តាមរយៈសហគមន៍កសិកម្ម

- ការពារអត្ថប្រយោជន៍សហគមន៍កសិកម្មពីគូប្រជែង / អ្នករិះគន់
- មិនត្រូវទុកសៀវភៅប្រាក់បញ្ញើ ឬ សៀវភៅមូលប្បទានបត្រ ដែលបានចុះហត្ថលេខារួច និងមានមុខងារសហគមន៍កសិកម្មចោលនោះទេ
- រក្សាប័ណ្ណ និងបង្កាន់ដៃទទួលប្រាក់ទាំងអស់ដែលចេញដោយសហគមន៍កសិកម្មនៅកន្លែងមានសុវត្ថិភាព
- ទទួលបង្កាន់ដៃទទួលប្រាក់ពីសហគមន៍កសិកម្មភ្លាមៗរាល់ការទូទាត់ប្រាក់
- បោះឆ្នោតជ្រើសរើសសមាជិកដែលស្មោះត្រង់ លះបង់ និងឧស្សាហ៍ព្យាយាមឱ្យធ្វើជាគណៈកម្មាធិការត្រួតពិនិត្យ ។

❖ **សិទ្ធិសមាជិក**

- ជួយគ្រប់សេវាកម្មដែលផ្តល់ដោយសហគមន៍កសិកម្ម
- សិក្សា សង្កេតមើលវិធាន បទបញ្ជា និងបទបញ្ញត្តិទាំងអស់នៃលក្ខន្តិកៈ
- សិក្សារបាយការណ៍សវនកម្ម និង របាយការណ៍ប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម
- សួរសំណួរ និងសុំឱ្យមន្ត្រីការិយាល័យបញ្ជាក់ឱ្យច្បាស់
- ប្រើសិទ្ធិបោះឆ្នោះដោយសេរី និងគ្មានការបង្ខិតបង្ខំ ឬ ទំនោរលើនរណាម្នាក់
- ទទួលបានការបោះឆ្នោតជ្រើសតាំងជាគណៈកម្មាធិការត្រួតពិនិត្យបើមិនមានការខកខាន
- យកបង្កាន់ដៃបង់ប្រាក់សម្រាប់ការទូទាត់ប្រាក់ឱ្យសហគមន៍កសិកម្ម
- ទទួលបានឯកសារចម្លងដែលបញ្ជាក់ពីសហគមន៍កសិកម្មដោយមិនគិតថ្លៃ
- បញ្ចេញយោបល់ ទស្សនៈដោយសេរី និងស្មោះត្រង់ ។

## ២.៥. លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍កសិកម្មភ្នំដិន សែនសុខ

### ២.៥.១. លក្ខន្តិកៈក្នុងការចូលជាសមាជិកសហគមន៍កសិកម្ម

➢ លក្ខខណ្ឌនៃការសុំចូលជាសមាជិក សិទ្ធិ និងភារកិច្ច

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានបំណងចូលជា សមាជិកសហគមន៍កសិកម្មភ្នំដិនសែនសុខ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ

- មានមុខរបរចម្បងលើ ការងារកសិកម្ម ឬសេវាកម្មទាំងឡាយដែលទាក់ទងផ្ទាល់នឹងវិស័យកសិកម្ម
- ស្ម័គ្រចិត្តសុំចូលជាសមាជិកសហគមន៍តាមរយៈការដាក់ពាក្យសុំចូលជាសមាជិក
- ឯកភាពបង់ប្រាក់សមាជិកភាព និងជាវភាគហ៊ុន១ហ៊ុនយ៉ាងតិច ។

(ឧបសម្ព័ន្ធទី៣ ៖ ពាក្យសុំចូលជាសមាជិកសហគមន៍កសិកម្ម)

➢ សមាជិកដែលបានបំពេញលក្ខខណ្ឌខាងលើ មានសិទ្ធ ៖

- ត្រូវចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោះស្មើភាពជាមួយ សមាជិកដទៃទៀតដោយពុំគិតកម្រិតដើមទុន ដែលបានវិនិយោគក្នុងសហគមន៍ឡើយ
- បោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត ក្នុងការជ្រើសរើសក្រុមប្រឹក្សាភិបាល ឬ គណៈកម្មាធិការត្រួតពិនិត្យរបស់សហគមន៍
- ទទួលព័ត៌មាន ពីស្ថានភាពសេដ្ឋកិច្ចរបស់សហគមន៍ ពីប្រធានក្រុមប្រឹក្សាភិបាល ឬ គណៈកម្មាធិការត្រួតពិនិត្យ
- ស្នើសុំឱ្យមានការកោះប្រជុំសន្និបាតវិសាមញ្ញាដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយបើមានការគាំទ្រពីសមាជិកយ៉ាងតិចមួយភាគបី( ១/៣) នៃសមាជិកទាំងអស់
- ធ្វើសំណូមពរឱ្យដាក់បញ្ចូលក្នុងរបៀបវារៈនៃមហាសន្និបាតនូវបញ្ហាទាំងឡាយដែលមានប្រយោជន៍សម្រាប់សហគមន៍
- ទទួលភាគចំណេញរៀងៗខ្លួន
- ជួល ប្រើប្រាស់សេវាកម្មសំណង់ និង គ្រឿងឧបករណ៍នានារបស់សហគមន៍ដូចគ្នានឹងសមាជិកដទៃទៀតទាំងអស់ ដោយបង់ថ្លៃសេវាតាមការកំណត់របស់អង្គប្រជុំមហាសន្និបាតមហាសន្និបាតវិសាមញ្ញ
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍
- ទទួលបានស្របតាមលក្ខន្តិកៈនូវភាគហ៊ុន ដែលបានបង់គ្រប់ចំនួនហើយ បូកនឹងការប្រាក់ ឬ ប្រាក់បង្វិលសងវិញនៅពេលដែលសមាជិកសុំលាលែង ឬ ត្រូវគេបណ្តេញចេញក្នុងករណីសល់ពីការខាតបង់របស់សហគមន៍តាមសមាមាត្រនៃការខាតបង់ ។

➢ សមាជិកសហគមន៍កសិកម្មមានកាតព្វកិច្ចដូចខាងក្រោម ៖

- គោរពបទប្បញ្ញត្តិនៃ ព្រះរាជក្រមលេខ នស / រកម / ០៦១៣ / ០០៨ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ២០១៣ ស្តីពីការ បង្កើត និងការប្រព្រឹត្តទៅនៃកសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្ម ។
- គោរពលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍កសិកម្ម
- គោរព និងអនុវត្តសេចក្តីសម្រេចរបស់មហាសន្និបាតសហគមន៍កសិកម្ម
- ត្រូវបង់ភាគហ៊ុនតាមការកំណត់របស់លក្ខន្តិកៈសហគមន៍កសិកម្ម
- ចូលរួមក្នុងសកម្មភាពសហគមន៍ ដើម្បីផលប្រយោជន៍ និងការរីកចម្រើនរបស់សហគមន៍ ។

➢ លក្ខខណ្ឌវិនិច្ឆ័យការលាឈប់ និង ការបណ្តេញចេញពីសមាជិកភាព ៖

- សមាជិកមានសិទ្ធសុំលាលែងពីសមាជិកភាពនៃសហគមន៍ តែការដកភាគហ៊ុន ត្រូវសម្រេចដោយមហាសន្និបាតរបស់សហគមន៍ ។ ភាគហ៊ុនថយចុះ ឬ កើនឡើងអាស្រ័យទៅលើស្ថានភាពហិរញ្ញវត្ថុ ជាក់ស្តែងរបស់សហគមន៍ ។
- ក្នុងករណីដែលមានសមាជិកសហគមន៍ណាម្នាក់ ធ្វើឱ្យមានការប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍ ឬសមាជិកសហគមន៍ដទៃទៀត សមាជិករូបនោះត្រូវបានគេព្យួរ ឬក៏ត្រូវបានគេបណ្តេញចេញពី សហគមន៍ ក្រោយពីបានការពារខ្លួននៅចំពោះមុខក្រុមប្រឹក្សាភិបាល ។ ការព្យួរ ឬ ការបណ្តេញចេញត្រូវសម្រេចដោយមហាសន្និបាត ។ ក្នុងករណីមានការប្រញាប់ ក្រុមប្រឹក្សាភិបាល អាចប្រកាសជាបណ្តោះអាសន្ននូវ ការព្យួរ ឬ ការបណ្តេញចេញបាន តែត្រូវមានកោះប្រជុំមហាសន្និបាតវិសាមញ្ញជាបន្ទាន់ដើម្បីពិភាក្សានិងសម្រេចលើបញ្ហានេះ ។

### ២.៥.២. បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍កសិកម្មភ្នំដិន សែនសុខ

សហគមន៍កសិកម្មភ្នំដិនសែនសុខ មានបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម ៖

➢ ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការត្រួតពិនិត្យ និងសមាជិកទាំងអស់របស់សហគមន៍ ត្រូវមានភាពស្មោះត្រង់ សមាគ្គីភាពផ្ទៃក្នុងសហគមន៍ ជួយស្ថាបនាសហគមន៍ ព្រមទាំងចូលរួមប្រជុំ និងរៀនសូត្របច្ចេកទេសផ្សេងៗ សម្រាប់បម្រើឱ្យការរីកចម្រើនរបស់សហគមន៍ ។

➢ បើបុគ្គលណាមួយនៃសហគមន៍ បានកេងប្រវ័ញ្ចធ្វើឱ្យខូតខាត ឬបាត់បង់ទ្រព្យសម្បត្តិ ផលប្រយោជន៍របស់សហគមន៍ ត្រូវដោះស្រាយតាមនិតិវិធីដូចខាងក្រោម ៖

- ចំពោះសមាជិក បុគ្គល ឬ នាយកគ្រប់គ្រង ត្រូវសងទៅតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យ ។ ក្នុងករណីមិនព្រមសង ត្រូវដាក់ជូនមហាសន្និបាត សម្រេច ។
- ចំពោះក្រុមប្រឹក្សាភិបាល ឬ គណៈកម្មាធិការត្រួតពិនិត្យ ត្រូវសងទៅតាមការសម្រេចរបស់មហាសន្និបាត ។

➢ បើបុគ្គលណាមួយនៃសហគមន៍ បានបង្កទំនាស់ ញុះញង់ បំបែកបំបាក់ក្នុងបំណងបំផ្លាញសហគមន៍ បុគ្គលនោះត្រូវទទួលការណែនាំអប់រំ ឬ ព្រមានពីក្រុមប្រឹក្សាភិបាល ឬ គណៈកម្មាធិការត្រួតពិនិត្យ ។ ក្នុងករណីមិនព្រមកែប្រែ ត្រូវដាក់ជូនមហាសន្និបាតសម្រេច ។

➢ រាល់ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ឬ ការប្រជុំ របស់គណៈកម្មាធិការត្រួតពិនិត្យ ត្រូវគោរពតាមគោលការដូចខាងក្រោម ៖

- មានលិខិតអញ្ជើញប្រជុំដែលបញ្ជាក់ពី ទីកន្លែង ថ្ងៃ ខែ ឆ្នាំ ម៉ោង និង របៀបវារៈ ។
- ត្រូវអនុលោមតាមលក្ខន្តិកៈ និង ការសម្រេចរបស់មហាសន្និបាត ។

➢ ហិរញ្ញិក ជាសេនាធិការឱ្យក្រុមប្រឹក្សាភិបាល មានភារកិច្ចគ្រប់គ្រងនូវចលនទ្រព្យ និង អចលនៈទ្រព្យរបស់ហាគមន៍ ។ រាល់ការចំណាយ និង ចំណូលរបស់សហគមន៍ ត្រូវសម្រេច និង ចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល ។

➢ ការខ្ចីលុយរបស់សហគមន៍ ត្រូវមានកិច្ចសន្យាដោយបញ្ជាក់អំពី ចំនួន ពេលវេលា អត្រាការប្រាក់ និងស្របតាមលក្ខន្តិកៈ ។

➢ ប្រធានក្រុមប្រឹក្សាភិបាល អាចផ្តល់ការឧបត្ថម្ភជាកម្រៃលើកទឹកចិត្តដល់ អ្នកបំពេញការងារជូនសហគមន៍ ។

➢ ក្រុមប្រឹក្សាភិបាល គណៈកម្មធិការត្រួតពិនិត្យ និង សមាជិករបស់សហគន៍ទាំងអស់ ត្រូវគោរព និងអនុវត្តតាមព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៨ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ២០១៣ ស្តីពីការបង្កើត និងការប្រព្រឹត្តទៅនៃសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្ម ការណែនាំរបស់ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ និងលក្ខន្តិកៈរបស់សហគមន៍ ។

ជាទូទៅនៅក្នុងការធ្វើលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងត្រូវបានធ្វើឡើងដោយយកគំរូពីកម្រងលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធ និងយកសហគមន៍កសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈការណែនាំរបស់រដ្ឋបាលនាយកដ្ឋានអភិវឌ្ឍន៍កសិកម្មខេត្តតាកែវ ។ ដូចនេះយើងអាចសង្កេតឃើញថាការបង្កើតឡើងនូវបទ

បញ្ហាផ្ទៃក្នុង និងលក្ខន្តិកៈសហគមន៍កសិកម្មភ្នំដិន សែនសុខត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវនឹងស្រមស្រប ដោយមានការចូលរួមប្រជុំ ដោយដាក់ឆ្នោងសមាជិកសហគមន៍កសិកម្ម គណៈកម្មាធិការសហគមន៍កសិកម្ម រដ្ឋបាលនាយកដ្ឋានអភិវឌ្ឍន៍កសិកម្ម ក្រុមប្រឹក្សាឃុំសង្កាត់ តំណាងអង្គការពាក់ព័ន្ធ ចាស់ព្រឹទ្ធាចារ្យ និង កម្រងលិខិតបទដ្ឋានគតិយុត្តិ ដែលពាក់ព័ន្ធនឹងសហគមន៍កសិកម្មនៃព្រះរាជាណាចក្រកម្ពុជា ។

## ២.៦. ទីតាំងសហគមន៍កសិកម្មភ្នំដិន សែនសុខ និង ធនធានដែលមាននៅក្នុងឃុំភ្នំដិន

### ២.៦.១. ទីតាំង

សហគមន៍កសិកម្មភ្នំដិនសែនសុខ ស្ថិតនៅ ភូមិទទឹង ឃុំភ្នំដិន ស្រុកគិរីវង់ ខេត្តតាកែវ ។ សហគមន៍ កសិកម្មភ្នំដិន សែនសុខ បានចុះបញ្ជីជោគជ័យនៅក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០១៤ ។

**រូបភាពទី ៣ ៖ ផែនទីរបស់សហគមន៍កសិកម្មភ្នំដិន សែនសុខ**




ប្រភព៖ Google Map ឃុំភ្នំដិន

### ២.៦.២. ការកំណត់ព្រំប្រទល់ និងប្រព័ន្ធគមនាគមន៍

សហគមន៍កសិកម្មភ្នំដិន សែនសុខមានព្រំប្រទល់ ៖

- ខាងជើងជាប់នឹង ឃុំគីរីចុងកោះ និងឃុំកំណប់
- ខាងត្បូងជាប់នឹង ឃុំសោម នឹងប្រទេសវៀតណាម
- ខាងកើតជាប់នឹងប្រទេសវៀតណាម
- ខាងលិចជាប់នឹង ឃុំសោម ។

នៅក្នុងឃុំភ្នំដិនមានផ្លូវលំក្រាលគ្រួស ៧ ខ្សែ ដែលមានប្រវែង ២៩៩៩ ម ក្នុងនោះមាន ៤ ខ្សែប្រវែង ២៥៦៩ ម ស្ថាបនាដោយមូលនិធិឃុំ និង ចំនួន ៣ ខ្សែប្រវែង ៤៣០ ម ដែលស្ថាបនាដោយថវិការដ្ឋនិងសប្បុរសជន ។

### ២.៦.៣. ដែនស្រោចស្រព

សហគមន៍កសិកម្មភ្នំដិនសែនសុខ ដែលស្ថិតនៅក្នុងឃុំភ្នំដិន មានប្រព័ន្ធធារាសាស្ត្រដូចជា ៖

- ប្រឡាយមាន ១២ ខ្សែ
- ប្រឡាយមេ ៣ ខ្សែ ប្រវែង ១១២០៤ ម
- ប្រឡាយរង ៩ ខ្សែ ប្រវែង ២០៣២០ ម
- ប្រឡាយជ្រូក១ ផ្លូវទូកប្រវែង ២៧៦២ ម ពីផ្លូវជាតិលេខ២ ទៅផ្លូវទូក
- ប្រឡាយផ្លូវទូក ១ ខ្សែប្រវែង ៣៨១៦ម ។

## ២.៧.ការធ្វើផែនការអភិវឌ្ឍន៍របស់សហគមន៍កសិកម្ម

### ២.៧.១.ការធ្វើផែនការគ្រប់គ្រងសហគមន៍

#### ២.៧.១.១.ការកំណត់បញ្ហា

យោងតាម ការសម្ភាសន៍ជាមួយលោកពូ មេន ប៊ិន ប្រធានក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្ម ភ្នំដិនសែនសុខ គាត់បានមានប្រសាសន៍ថា ការរៀបចំផែនការនេះត្រូវបានធ្វើឡើងតាមរយៈការធ្វើមហាសន្និបាតប្រជុំជាមួយគណៈកម្មាធិការត្រួតពិនិត្យ សមាជិកសហគមន៍ និងស្ថាប័នពាក់ព័ន្ធ ដើម្បីលើកឡើងនូវបញ្ហាដែលកំពុងកើតមាន រិះរកមធ្យោបាយដោះស្រាយដោយសន្តិវិធី និង សមោហាភាព។ ពិសេសនោះ គឺការរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំបន្តបន្ទាប់ទៀត ដូចនេះគេត្រូវបានកំណត់យកអាទិភាពនៃបញ្ហាមកធ្វើការប្រជុំពិភាក្សា ធ្វើដំណោះស្រាយ ក៏ដូចជាកំណត់ផែនការយុទ្ធសាស្ត្រ សម្រាប់ដឹកនាំសហគមន៍កសិកម្ម។

**រូបភាពទី ៤៖ ការសម្ភាសន៍ជាមួយប្រធានក្រុមប្រឹក្សាភិបាលសហគន៍កសិកម្មភ្នំដិន សែនសុខ**



### ២.៧.១.២. ការកសាងផែនការ

ការកសាងផែនការត្រូវបានធ្វើឡើងដូចខាងក្រោមនេះ៖

- បណ្តុះបណ្តាលសមាជិកសហគមន៍ និង ប្រជាពលរដ្ឋពីការរៀបចំទាក់ទងផែនការអភិវឌ្ឍន៍សហគមន៍កសិកម្ម
- សម្របសម្រួលពិភាក្សាជាមួយក្រុមតូចៗ ពិគ្រោះយោបល់សមាជិក និងស្ថាប័នពាក់ព័ន្ធនៅក្នុងសហគមន៍កសិកម្ម
- ធ្វើសេចក្តីព្រាងផែនការគ្រប់គ្រងសហគមន៍កសិកម្ម
- រៀបចំការងារស្រាវជ្រាវបន្ថែម ដើម្បីដឹងកាន់តែស៊ីជម្រៅពីបញ្ហានានានៅក្នុងសហគមន៍កសិកម្ម
- ផែនការគ្រប់គ្រងត្រូវបានសម្រេចដោយមហាសន្និបាត
- ដាក់ឆ្លងផែនការគ្រប់គ្រងទៅគណៈកម្មាធិការត្រួយពិនិត្យនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ។

### ២.៧.១.៣. យុទ្ធសាស្ត្រអនុវត្តផែនការ

នៅពេលដែលផែនការគ្រប់គ្រងសហគមន៍ត្រូវបានរៀបចំ និង អនុវត្តយល់ព្រមហើយនោះសហគមន៍កសិកម្មគប្បីត្រូវអនុវត្តផែនការគ្រប់គ្រងទាំងនោះ ព្រោះជាកត្តាជម្រុញប្រកបដោយភាពជោគជ័យលើដំណើរការនៃការគ្រប់គ្រងសហគមន៍កសិកម្ម។ លើសពីនេះទៅទៀត ដើម្បីអនុវត្តន៍ផែនការឱ្យទទួលបានជោគជ័យ គណៈកម្មាធិការត្រួតពិនិត្យ សហគមន៍កសិកម្មភ្នំដិនសែនសុខ ធ្វើការចងក្រងជាយុទ្ធសាស្ត្រមួយចំនួនសម្រាប់សកម្មភាពអនុវត្តន៍ដូចខាងក្រោម ៖

- បង្កើតគណៈកម្មាធិការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ វាយតម្លៃការអនុវត្តផែនការក្នុងការអនុវត្តផែនការ ក្នុងនោះមានសមាជិកគណៈកម្មការសហគមន៍កសិកម្ម សមាជិកសហគមន៍កសិកម្មដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗ ជាពិសេសអំពីបញ្ហាកសិកម្ម ។
- ស្នើសុំជំនួយបច្ចេកទេសពីនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មដូចជា ការធ្វើផែនការផលិតពូជស្រូវ
- ការរៀបចំដី ការប្រើប្រាស់ថ្នាំការពារ និងការប្រើប្រាស់ឧបករណ៍កសិកម្ម ។
- រៀបចំកម្មវិធីអនុវត្តតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់ ដោយទាក់ទងជាមួយគណៈកម្មាធិការត្រួតពិនិត្យ ដើម្បីស្នើសុំការគាំទ្រ និងជួយរកដៃគូគាំទ្រការទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍កសិកម្ម។
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធជំនាញ អង្គការនានា ម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ ។
- ផ្សព្វផ្សាយផែនការគ្រប់គ្រងសហគមន៍កសិកម្មដល់សមាជិកសហគមន៍ អ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រង ។
- ពង្រឹងសមត្ថភាពបច្ចេកទេស និងការគ្រប់គ្រងរបស់គណៈកម្មការសហគមន៍កសិកម្ម
- បញ្ចូលផែនការគ្រប់គ្រងកន្លែងសហគមន៍កសិកម្មទៅក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់ ។[38]

**២.៧.១.៤. ការគ្រប់គ្រងហិរញ្ញវត្ថុសហគមន៍ និង បញ្ជីឯកសារ**

❖ **ការផ្គត់ផ្គង់ហិរញ្ញវត្ថុ**

យោងតាមការសម្ភាសន៍ជាមួយលោក **មេន ប៊ិន** ជាប្រធានក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្មភ្នំដិនសែនសុខបានមានប្រសាសន៍ថា ប្រភពហិរញ្ញវត្ថុសហគមន៍បានមកពី ៖

- ភាគហ៊ុនដែលជាវ និង បង់ដោយសមាជិក
- មូលនិធិបម្រុងដែលដកចេញពីប្រាក់ចំណេញ
- អំណោយជាកេរមតកឬវិភាគទានផ្សេងៗពី សប្បុរសជន អង្គការ ការឧបត្ថម្ភពីរាជរដ្ឋាភិបាល
- កម្ចីពីតតិយជន
- កម្ចីពីសមាជិកដែលមានរូបភាពជាប្រាក់តម្កល់ ឬ ជាប្រាក់សន្សំ ។

[38] *សៀវភៅ ផែនការគ្រប់គ្រងសហគមន៍កសិកម្មភ្នំដិន សែនសុខ*

រាល់កញ្ចប់ចំណូលថវិការបស់សហគមន៍ត្រូវបានរក្សាទុកនៅបេឡារបស់សហគមន៍ ។ ថវិកាដែលតម្កល់ទុកនៅបេឡាធិការត្រូវបានចំណាយទៅលើការជួសជុលឧបករណ៍ សម្ភារៈ ទីស្នាក់ការ និងយកមកបំពេញតម្រូវការចាំបាច់ផ្សេងៗដូចជា ការងារប្រជុំ ទស្សនៈកិច្ចសិក្សា ក៏ដូចជាសម្រាប់ប្រជាជនដែលខ្វះលទ្ធភាពក្នុងដំណើរការផលិតកម្មកសិកម្ម ។ ជាក់ស្តែងសហគមន៍តម្រូវយកថវិកាទុកសម្រាប់ផ្តល់ជាឥណទានទិញប្រេងឥន្ធនៈ និងនាំចូលផលិតផលកសិកម្មសម្រាប់លក់នៅក្នុងសហគមន៍ ។ ដើមទុនរបស់សហគមន៍កសិកម្មអាចប្រែប្រួលទៅតាមការកើនឡើងបណ្តាលមកពីការចូលថែមសមាជិកថ្មី ឬ ការជាវភាគហ៊ុនបន្ថែម និងការចុះថយបណ្តាលមកពីសងបំណុល ឬ នៅពេលដែលមានដកភាគហ៊ុន ។ ថវិកាសម្រាប់ដំណើរការរបស់សហគមន៍ ត្រូវសម្រេចដោយមហាសន្និបាត ។ បើថវិកាមិនគ្រប់គ្រាន់តាមសេចក្តីត្រូវការ បម្រើសកម្មភាពសហគមន៍ទេនោះ ប្រធានក្រុមប្រឹក្សាភិបាលអាច ស្នើឱ្យមហាសន្និបាតសម្រេចខ្ចីទុនពីខាងក្រៅដោយមិនឱ្យលើសពីបួន (៤) ដងនៃដើមទុនសរុបរបស់ សហគមន៍ទេ ។

❖ **ការបែងចែកហិរញ្ញវត្ថុរបស់សហគមន៍**

នៅពេលដំណើរការបានចំណេញ សហគមន៍កសិកម្មនឹងបង្កើត ៖

- មូលនិធិបម្រុងដោយដកយកម្ភៃភាគរយ (២០%) ពីប្រាក់ចំណេញសុទ្ធរហូតដល់ មូលនិធិនេះមានចំនួនប្រាំ (៥ ) ដងនៃភាគហ៊ុនទាំងអស់ដែលបានបង់ហើយ ។ មូលនិធិបម្រុងទាំងនេះមិនអាចយកទៅ ចែកចាយឱ្យសមាជិកបានទេ ។
- មូលនិធិសម្រាប់បណ្តុះបណ្តាលអប់រំដោយដកបីភាគរយ (៣%) ពីប្រាក់ចំណេញសុទ្ធ ។

❖ **ការរៀបចំបញ្ជីឯកសាររបស់សហគមន៍**

សហគមន៍កសិកម្ម ត្រូវបានរៀបចំឱ្យមានបញ្ជី ៖

- ចំណូលចំណាយថវិកា
- សារពើភ័ណ្ឌ
- សមទិន
- សមាជិកសហគមន៍
- ភាគហ៊ុន
- កំណត់ហេតុអង្គប្រជុំមហាសន្និបាត
- កំណត់ហេតុអង្គប្រជុំក្រុមប្រឹក្សាភិបាល
- កំណត់ហេតុអង្គប្រជុំគណៈកម្មាធិការត្រួតពិនិត្យ

➢ កំណត់ហេតុអង្គប្រជុំអង្គភាពដទៃទៀតនៅក្នុងសហគមន៍ ដែលមហាសន្និបាតបានបង្កើតឡើង ។

### ២.៧.២. ផែនការគ្រប់គ្រង និងសកម្មភាពសំខាន់ៗរបស់សហគមន៍កសិកម្ម

ផែនការ គឺជាគំនិតគិតទុកមុនរបស់មនុស្សប្រកបដោយរបៀបវារៈត្រឹមត្រូវ មានការកំណត់ពេលវេលាច្បាស់លាស់ដើម្បីសម្រេចគោលបំណងអ្វីមួយ ។ ការរៀបចំផែនការ គឺជាដំណើរការនៃការបង្កើតសកម្មភាពការងារ និងវិធីសាស្ត្រដើម្បីសម្រេចគោលដៅនៃគម្រោង ឬកម្មវិធីនៅក្នុងរយៈពេលកំណត់ច្បាស់លាស់ណាមួយដោយមានការចូលរួមពីអ្នកពាក់ព័ន្ធជាច្រើន ។ ដើម្បីគ្រប់គ្រងសហគមន៍កសិកម្មឱ្យមានប្រសិទ្ធភាព និងធ្វើការអភិវឌ្ឍន៍សហគមន៍ប្រកបដោយ សមធម៌ និង និរន្តរភាព សហគមន៍កសិកម្មភ្នំដិនសែនសុខ បានរៀបចំនូវផែនការមួយចំនួនផងដែរ ។

#### ២.៧.២.១. សកម្មភាពសំខាន់ៗរបស់សហគមន៍កសិកម្ម ឆ្នាំ២០១៤- ២០១៩

❖ **មុខរបរឥណទានសហគមន៍កសិកម្ម**

មុខរបរឥណទានសហគមន៍កសិកម្ម គឺជាមុខរបរដែលសហគមន៍កសិកម្មទទួលប្រាក់បញ្ញើសន្សំក្នុងអត្រាការប្រាក់ខ្ពស់និងផ្តល់ប្រាក់កម្ចីក្នុងអត្រាការប្រាក់ទាបដល់សមាជិកសហគមន៍កសិកម្ម។ ដើម្បីធ្វើការអភិវឌ្ឍមុខរបរឥណទានអោយមានប្រសិទ្ធភាព សហគមន៍កសិកម្មភ្នំដិនសែនសុខ បានរៀបចំនូវផែនការសកម្មភាពជាច្រើន ហើយទទួលបានសមិទ្ធផលដូចខាងក្រោម ៖

**តារាង ២.១ សមិទ្ធផលពីមុខរបរឥណទាន**

| បរិយាយ | ចំនួនទឹកប្រាក់ (រៀល) | | |
|---|---|---|---|
| | ឆ្នាំ ២០១៤ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ |
| ប្រាក់ឱ្យសមាជិកសហគមន៍កសិកម្មខ្ចី | ៦៣,៨៨២,៥០០ | ៨៥,៥២៥,០០០ | ៩៤,២៥០,០០០ |
| ប្រាក់ឱ្យអ្នកមិនមែនសមាជិកសហគមន៍កសិកម្មខ្ចី | ២៥,៤៨២,៥០០ | ១៨,៥០០,០០០ | ២១,២០០,០០០ |
| **ប្រាក់ឱ្យខ្ចីសរុប** | ៨៩,៣៦៥,០០០ | ១០៤,០២៥,០០០ | ១១៥,៤៥០,០០០ |
| បរិយាយ | ចំនួនទឹកប្រាក់ (រៀល) | | |
| | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ |

| | | | |
|---|---|---|---|
| ប្រាក់ឱ្យសមាជិកសហគមន៍កសិកម្មខ្ចី | ១៤៣,១០០,000 | ១៦២,១០០,000 | ១៧៨,៣00,000 |
| ប្រាក់ឱ្យអ្នកមិនមែនសមាជិកសហគមន៍កសិកម្មខ្ចី | ១២,៦00,000 | ៧,៩00,000 | ១៥,៥00,000 |
| ប្រាក់ឱ្យខ្ចីសរុប | ១៥៥,៧00,000 | ១៧0,000,000 | ១៩៣,៨00,000 |

❖ **មុខរបរផ្គត់ផ្គង់របស់សហគមន៍កសិកម្ម**

មុខរបរផ្គត់ផ្គង់ គឺជាមុខរបរដែលសហគមន៍កសិកម្មទិញទំនិញពីទីផ្សារ ឬ អ្នកផ្គត់ផ្គង់ និងលក់ឱ្យសមាជិក ក្នុងតម្លៃទាប ឬក្នុងតម្លៃមួយសមរម្យ ។ ដើម្បីសម្រួល និងផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋសហគមន៍កសិកម្មភ្នំដិន សែនសុខបានរៀបចំ និងអភិវឌ្ឍន៍លើផែនការសកម្មភាពមុខរបរផ្គត់ផ្គង់ជាច្រើន ហើយទទួលបាននូវសមិទ្ធផលដូចខាងក្រោម ៖

**តារាង ២.២ សមិទ្ធផលបានពីមុខរបរផ្គត់ផ្គង់**

| បរិយាយ | ចំនួនទឹកប្រាក់ (រៀល) | | |
|---|---|---|---|
| | ឆ្នាំ ២០១៤ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ |
| ចំណូលសរុបពីផ្គត់ផ្គង់ជីកសិកម្ម | ១២៣,១១៣,000 | ១៨៨,៤១៦,000 | ២៣៧,៧២0,000 |
| ចំណូលសរុបពីផ្គត់ផ្គង់ប្រេងឥន្ទនៈ | 0 | ១៣,៦00,000 | ៤៣,២២៥,000 |
| ចំណូលសរុបពីផ្គត់ផ្គង់ពូជស្រូវ | 0 | 0 | 0 |
| **ចំណូលសរុបមុខរបរផ្គត់ផ្គង់** | ១២៣,១១៣,000 | ២0២,0១៦,000 | ២៨0,៩៤៥,000 |
| បរិយាយ | ចំនួនទឹកប្រាក់ (រៀល) | | |
| | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ |
| ចំណូលសរុបពីផ្គត់ផ្គង់ជីកសិកម្ម | ២៧៨,៦៩៨,000 | ២៦៧,៦៥៦,000 | ៣៥៧,៥៤៤,000 |
| ចំណូលសរុបពីផ្គត់ផ្គង់ប្រេងឥន្ទនៈ | ៥៧,៥៤៧,000 | ៨៥,៧៣២,៥00 | ១៧0,៩៥៨,000 |
| ចំណូលសរុបពីផ្គត់ផ្គង់ពូជស្រូវ | ២,៣៧៥,000 | ២១,៥0២,000 | ៦,៤៥0,000 |

| | | | |
|---|---|---|---|
| **ចំណូលសរុបមុខរបរផ្គត់ផ្គង់** | ៣៣៨,៦២០,០០០ | ៣៧៤,៨៩០,៥០០ | ៥៣៨,៩៥២,០០០ |

### ២.៧.២.២. ផែនការអភិវឌ្ឍន៍សហគមន៍កសិកម្ម

**តើអ្វីទៅជាផែនការសកម្មភាពប្រចាំឆ្នាំ ?**

ផែនការសកម្មភាពប្រចាំឆ្នាំ គឺជាសេចក្ដីណែនាំ ឬជាការកំណត់អំពីសកម្មភាពដែលត្រូវអនុវត្តន៍ក្នុងមួយឆ្នាំ ឬលទ្ធផលដែលគ្រោងទុកនឹងទទួលបាននៅចុងឆ្នាំ ។ វាបានណែនាំថាតើសកម្មភាពអ្វីដែលសហគមន៍កសិកម្មត្រូវធ្វើ តើត្រូវធ្វើនៅពេលណា និងដោយអ្នកណា ? តើធនធានចូលអ្វីខ្លះដែលត្រូវការដើម្បីសម្រេចឱ្យបានលទ្ធផលដែលបានគ្រោងទុក ?

**ហេតុអ្វីបានជាសហគមន៍កសិកម្មត្រូវរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ?**

សមាជិកសហគមន៍កសិកម្មទាំងអស់គឺជាម្ចាស់របស់សហគមន៍កសិកម្ម ដូចនេះរាល់កិច្ចការទាំងអស់ត្រូវតែទទួលបានយល់ព្រមដោយសមាជិកសហគមន៍កសិកម្មតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ ឬស្របទៅតាមឆន្ទរបស់សមាជិក ។ ផែនការសកម្មភាព គឺជាវិធីសាស្ត្រដ៏ប្រសើរមួយ ក្នុងការទទួលបានការយល់ព្រមពីសមាជិកក្នុងការអនុវត្តកិច្ចការផ្សេងៗ ក្នុងឆ្នាំនីមួយៗ ។ ផែនការសកម្មផែនប្រចាំឆ្នាំបានជួយយើងឱ្យរៀបចំសកម្មភាពទៅតាមលំដាប់លំដោយ ដឹងពីអ្វីដែលយើងត្រូវធ្វើ និងធ្វើនៅពេលណា ។ មានផែនការសកម្មភាព វាបានជួយឱ្យសហគមន៍កសិកម្មជៀសផុតពីភាពស្មុគស្មាញដោយសារតែមានកិច្ចការច្រើន ។

- **ការងាររដ្ឋបាល**

**តារាង ២.៣ ផែនការការងាររដ្ឋបាល**

| បរិយាយ | ចំនួន(ដង) | កាលបរិច្ឆេទ | កំណត់សម្គាល់ |
|---|---|---|---|
| មហាសន្និបាទប្រចាំឆ្នាំ | ១ | ខែមីនា ឆ្នាំ ២០២០ | មួយឆ្នាំម្ដង |
| កិច្ចប្រជុំក្រុមប្រឹក្សាភិបាល | ១២ | រៀងរាល់ថ្ងៃទី០២ រាល់ខែ | មួយខែមួយដង |

| | | | |
|---|---|---|---|
| កិច្ចប្រជុំគណកម្មាធិការត្រួតពិនិត្យ | ៦ | រៀងរាល់ថ្ងៃទី០៣ រាល់ខែ | ពីរខែមួយដង |

❖ **រចនាសម្ព័ន្ធ**

**តារាង ២.៤ ផែនការរចនាសម្ព័ន្ធ**

| បរិយាកាស | ២០១៩ | ២០២០ | សកម្មភាព |
|---|---|---|---|
| បង្កើនសមាជិក | ១៧៤ | ១៧៩ | អញ្ជើញកសិករមិនមែនសហគមន៍កសិកម្មចូលរួមមហាសន្និបាតប្រចាំ<br>ពន្យល់អំពីគោលគំនិតសហគមន៍កសិកម្មនៅមហាសន្និបាតប្រចាំឆ្នាំ ។ |
| ភាគហ៊ុន | ១៣០៤៩ | ១៤៥៤៩ | បង្កើនសមាជិកភាព<br>ពន្យល់ពីអត្ថប្រយោជន៍ចំពោះសហគមន៍កសិកម្ម និងសមាជិកសហគមន៍កសិកម្មនៅពេលភាគហ៊ុនមានការកើនឡើងនៅមហាសន្និបាតប្រចាំឆ្នាំ ។ |
| ក្រុមផលិតស្រូវសរីរាង្គ | ៤ | ៩ | បង្កើនផែនការមុខជំនួញ<br>ស្វែងរកទីផ្សារ<br>ធ្វើកិច្ចសន្យា ។ |
| នាយកគ្រប់គ្រង | 0 | 0 | បិទប្រកាសនៅលើក្តារព័ត៌មាន និងនៅតាមទីសាធារណៈ<br>ប្រកាសនៅពេលមហាសន្និបាត ។ |
| គណនេយ្យករ | 0 | 0 | បិទប្រកាសនៅលើក្តារព័ត៌មាន និងនៅតាមទីសាធារណៈ<br>ប្រកាសនៅពេលមហាសន្និបាត ។ |

| | | | |
|---|---|---|---|
| នាយកទីផ្សារ | ០ | ០ | បិទប្រកាសនៅលើក្ដារព័ត៌មាន និងនៅតាមទីសាធារណៈ<br>ប្រកាសនៅពេលមហាសន្និបាត ។ |

❖ **សកម្មភាពអប់រំ**

**តារាង ២.៥ ផែនការសកម្មភាពអប់រំ**

| សិក្ខាកាម | ប្រធានបទ | ចំនួនវគ្គ | សកម្មភាព |
|---|---|---|---|
| ក្រុមប្រឹក្សាភិបាល និង គណកម្មាធិការត្រួតពិនិត្យ | ភាពជាអ្នកដឹកនាំ<br>ផែនការមុខជំនួញរបស់សហគមន៍<br>គណនេយ្យ និងបញ្ជីប្រចាំខែ | ០១<br>០១<br>០២ | ទំនាក់ទំនងជាមួយមន្ទីរកសិកម្មខេត្តដើម្បីទទួលបានវគ្គបណ្ដុះបណ្ដាលនេះ |
| សមាជិក | គោលគំនិតសហគមន៍<br>បច្ចេកទេសដាំដុះស្រូវ<br>បច្ចេកទេសដាំបន្លែ<br>បច្ចេកទេសដាំបន្លែ | ០១<br>០២<br>០២<br>០២ | ទំនាក់ទំនងជាមួយមន្ទីរកសិកម្មខេត្តដើម្បីទទួលបានវគ្គបណ្ដុះបណ្ដាលនេះ |

❖ **ទ្រព្យសកម្មអចល័ត**

**តារាង ២.៦ ផែនការទ្រព្យសកម្មអចល័ត**

| បរិយាយ | ចំនួន | ពេលកំណត់ | សកម្មភាព |
|---|---|---|---|
| ដី | ១ | ត្រឹមចុងឆ្នាំ២០២៧ | ស្នើដកប្រាក់ចំណេញប្រចាំឆ្នាំចំនួន ៣,៥ លានរៀលក្នុងមួយឆ្នាំទុកជាមូលនិធិស្ម័គ្រចិត្តសម្រាប់ទិញដី នៅក្នុងមហាសន្និបាត ។ |

| | | | |
|---|---|---|---|
| ការិយាល័យ | ០ | ត្រឹមចុងឆ្នាំ២០២៧ | ស្នើដកប្រាក់ចំណេញប្រចាំឆ្នាំចំនួន ៣,៥ លានរៀលក្នុងមួយឆ្នាំទុកជាមូលនិធិស្ម័គ្រចិត្តសម្រាប់ទិញដី នៅក្នុងមហាសន្និបាត ។ |

### ២.៧.២.៣ ផែនការអភិវឌ្ឍន៍មុខជំនួញ

❖ **មុខរបរឥណទានសហគមន៍កសិកម្ម**

មុខរបរឥណទានសហគមន៍កសិកម្ម គឺជាមុខរបរដែលសហគមន៍កសិកម្មទទួលប្រាក់បញ្ញើសន្សំក្នុងអត្រាការប្រាក់ខ្ពស់និងផ្តល់ប្រាក់កម្ចីក្នុងអត្រាការប្រាក់ទាបដល់សមាជិកសហគមន៍កសិកម្ម។

**តារាង ២.៧ ផែនការមុខរបរឥណទាន**

| **បរិយាយ** | **ចំនួន (រៀល)** | | **សកម្មភាព** |
|---|---|---|---|
| | **ឆ្នាំ ២០១៩ ត្រឹមថ្ងៃទី ៣១-ធ្នូ ២០១៩** | **ផែនការឆ្នាំ ២០២០ ត្រឹមថ្ងៃទី ៣១-ធ្នូ ២០២០** | |
| បញ្ញើសន្សំ | ៣០,៣៩១,០០០ | ៣៣,៣៩១,០០០ | ពន្យល់ពអត្ថប្រយោជន៍នៃការបង្កើនបញ្ញើសន្សំនៅពេលមហាសន្និបាតប្រចាំ |
| ប្រាក់កម្ចី (សមាជិក) | ១៧៨,៣០០,០០០ | ១៨០,៣០០,០០០ | ពន្យល់ពីអត្ថប្រយោជន៍នៃប្រាក់កម្រៃទទួលបានប្រាក់កម្ចីពីសហគមន៍កសិកម្ម |
| ប្រាក់កម្ចី(មិនមែន សមាជិក) | ១៥,៥០០,០០០ | ១៦,៥០០,០០០ | ពន្យល់ពីអត្ថប្រយោជន៍នៃទទួលប្រាក់កម្ចីពីសហគមន៍កសិកម្ម |

❖ **មុខផ្គត់ផ្គង់សហគមន៍កសិកម្ម**

នៅក្នុងដំណើរការនៃការប្រកបមុខរបរផ្គត់ផ្គង់របស់សហគមន៍កសិកម្មភ្នំជិនសែនសុខបានរៀបចំផែនការសកម្មភាពមួយចំនួនដូចខាងក្រោម៖

- ពន្យល់ពីអត្ថប្រយោជន៍នៃការទិញទំនិញពីសហគមន៍នៅមហាសន្និបាតប្រចាំឆ្នាំ
- ពន្យល់ពីបច្ចេកទេសប្រើប្រាស់ជី
- ពន្យល់ពីបច្ចេកទេសផ្តល់ចំណី
- ពន្យល់ពីបច្ចេកទេសប្រើប្រាស់ពូជស្រូវ
- ដាក់ផ្ទាំងផ្សាយពាណិជ្ជកម្មនៅតាមទីសាធារណៈ ។

❖ **មុខទីផ្សារ**

មុខរបរទីផ្សារ គឺជាមុខរបរដែលសហគមន៍កសិកម្មទិញផលិតផលពីកសិករដែលជាសមាជិក ឬមិនមែនសមាជិកសហគមន៍កសិកម្មហើយលក់ឱ្យទីផ្សារដើម្បីជានាទីផ្សារ និងតម្លៃផលិតផលរបស់សមាជិកសហគមន៍កសិកម្ម ។ ដើម្បីសម្រួលដល់ប្រជាកសិករ និងអភិវឌ្ឍន៍មុខរបរទីផ្សារ សហគមន៍កសិកម្មភ្នំជិនសែនសុខ បានរៀបចំផែនការសកម្មភាពមួយចំនួនដូចខាងក្រោម ៖

- សិក្សាលទ្ធភាពផ្គត់ផ្គង់របស់សមាជិក
- ពិភាក្សាអំពីបរិមាណតម្រូវការជាមួយនឹងអ្នកទិញ
- ស្វែងរកអ្នកទិញបន្ថែម
- ដាក់ផ្ទាំងផ្សព្វផ្សាយនៅទីសាធារណៈ ។

### ២.៧.៣. ផែនការយុទ្ធសាស្ត្រសំខាន់ៗសម្រាប់បន្តនាពជោគជ័យ

ដើម្បីអនុវត្តន៍ផែនការឱ្យទទួលបានជោគជ័យ គណៈកម្មាធិការត្រួតពិនិត្យសហគមន៍កសិកម្មភ្នំជិនសែនសុខ ធ្វើការចងក្រងជាយុទ្ធសាស្ត្រមួយចំនួនសម្រាប់សកម្មភាពអនុវត្តន៍ដូចខាងក្រោម៖

- សហគមន៍កសិកម្មចាំបាច់ត្រូវបង្កើតឱ្យមានអត្ថប្រយោជន៍ជាក់ស្តែងនឹងភ្នែក ( ផ្នែកសេដ្ឋកិច្ច និង សង្គម) សម្រាប់សមាជិកច្រើនជាងការចំណាយពាក់ព័ន្ធនៅក្នុងសហគមន៍កសិកម្ម។ សហគមន៍កសិកម្មអាចអភិវឌ្ឍន៍ខ្លួនទៅជាអង្គការស្វយ័តជួយខ្លួនឯងបាន នៅពេលពួកគាត់មានលទ្ធភាព និងទទួលបានការអនុញ្ញាតឱ្យដំណើរការស្ថាប័នអាជីវកម្ម ដែលត្រូវរៀបចំឡើងដើម្បីឱ្យទទួលបានជោគជ័យនៅក្នុងការប្រកួតប្រជែងក្នុងទីផ្សារ។
- សហគមន៍កសិកម្មបានជម្រុញលើកទឹកចិត្តអ្នកគ្រប់គ្រងដែលមានបទពិសោធន៍ ភាពស្វាហាប់ដែលមានសមត្ថភាពអាចធ្វើផែនការ និង អនុវត្តគោលនយោបាយអាជីវកម្ម។ ពួកគាត់ត្រូវមាន

សមត្ថភាពអាចផ្ដល់សេវាកម្ម និង ទំនិញដែលសមាជិកត្រូវការ ដោយគិតគូរទាំងចំណាប់អារម្មណ៍ សេចក្ដីត្រូវការរបស់សមាជិក ព្រមទាំងគោលបំណងសហគ្រិនភាពរបស់សហគ្រាសសហគមន៍កសិកម្មផងដែរ។

- រចនាសម្ព័ន្ធ ការគ្រប់គ្រងអង្គភាពពាក់ព័ន្ធត្រូវទាក់ទងនឹងសមត្ថភាពរបស់សមាជិករបស់ខ្លួន។ ប្រសិនបើសមាជិកខ្វះសមត្ថភាព ការលើកទឹកចិត្ត ការលើកកម្ពស់ដើម្បីបង្កើតសហគមន៍កសិកម្មដែលស្មុគស្មាញ និងសាំញ៉ាំ មិនអាចទៅរួចឡើយ។
- សមាជិកចូលរួមក្នុងនាមជាអ្នកប្រើប្រាស់ផង និងជាម្ចាស់ផង។

សហគមន៍កសិកម្ម គឺជាអង្គការចូលរួមជួយខ្លួនឯង ដែលក្នុងនោះសមាជិកក៏ជាសហកម្មសិទ្ធិដែរ និងមានទាំងសិទ្ធិ ទាំងកាតព្វកិច្ចចូលរួមនៅក្នុងការកំណត់គោលដៅ ការធ្វើសេចក្ដីសម្រេចចិត្ត ការគ្រប់គ្រង និងការវាយតម្លៃដំណើរការរបស់សហគមន៍កសិកម្មពួកគាត់។ សមាជិកធ្វើសេចក្ដីសម្រេចលើសេវាកម្មដែលត្រូវផ្ដល់ជូន និង អត្ថប្រយោជន៍ដែលសហគមន៍កសិកម្មបានបង្កើតឡើងរឺទទួលបាន។ វាគួរតែមានគ្រឿងសម្រាប់លើកទឹកចិត្តសម្រាប់ពួកគាត់ ដែលរួមចំណែកផ្ដល់ធនធានផ្ទាល់ខ្លួនរបស់ពួកគាត់(ដើមទុន កម្លាំងពលកម្ម ផលិតផល) សម្រាប់ការអភិវឌ្ឍសហគមន៍កសិកម្ម គឺកង្វះការចូលរួមពីសមាជិក។

តាមរយៈការរៀបចំផែនការ យុទ្ធសាស្ត្រសម្រាប់គ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍កសិកម្មនេះ សហគមន៍កសិកម្មភ្នំដិនសែនសុខ មានការរំពឹងទុកថា ប្រជាពលរដ្ឋនៅក្នុងសហគមន៍ និង មូលដ្ឋានទាំងមូលនឹងចូលរួមសហការក្នុងដំណើរការគម្រោងនេះដោយយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់។ជាងនេះទៅទៀត តាមរយៈការអភិវឌ្ឍនេះប្រជាពលរដ្ឋនៅក្នុងសហគមន៍នឹងមានជីវភាពកាន់តែប្រសើរឡើងមួយកម្រិតទៀត ដែលជាហេតុធ្វើសហគមន៍កសិកម្មមានការរីកចម្រើនឡើងប្រកបដោយនិរន្តរភាព ។

# ជំពូកទី៣

# ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

## ៣.១. ការវិភាគលើស្ថានភាពរបស់សហគមន៍កសិកម្មភ្នំដិន សែនសុខ

### ៣.១.១. ស្ថានភាពរស់នៅមុនពេលបង្កើតសហគមន៍កសិកម្មភ្នំដិន សែនសុខ

មុនពេលបង្កើតនូវសហគមន៍កសិកម្មភ្នំដិនសែនសុខ ប្រជាជនរស់នៅក្នុងឃុំភ្នំដិន ភាគច្រើនរស់នៅក្នុងសភាពក្រីក្រ ដោយពួកគាត់ប្រកបរចិញ្ចឹមជីវិតដោយពឹងផ្អែកលើការជួញដូរទំនិញជាលក្ខណៈអន្តរជាតិជាមួយប្រទេសវៀតណាម ចិញ្ចឹមសត្វ និង ធ្វើស្រែចម្ការខ្លះៗតែប៉ុណ្ណោះ។ លើសពីនេះទៅទៀត មុនពេលមិនទាន់បង្កើតសហគមន៍កសិកម្មឡើងគេឃើញថាប្រជាកសិករនៅក្នុងឃុំភ្នំដិនភាគច្រើន ពួកគាត់មិនសូវបានយល់ច្បាស់ពីបច្ចេកទេសនៅក្នុងការធ្វើកសិកម្មដើម្បីទទួលបានទិន្នផលខ្ពស់ ដូចជាមិនយល់ពី ការប្រើប្រាស់ជី ថ្នាំការពារផ្សេងៗ និង ការប្រើប្រាស់ឧបករណ៍កសិកម្ម ។ មិនត្រឹមតែប៉ុណ្ណោះទេ គេក៏ឃើញមានពីបញ្ហានៃការថែរក្សាការពារស្រូវ ដំណាំផ្សេង ពីសត្វល្អិតចង្រៃ និង ជម្ងឺផ្សេងៗ ដែលជាហេតុធ្វើឱ្យទិន្នផលកសិកម្មទទួលបានមានចំនួនតិចតួច ។ ចំណែកឯស្ថានភាពរស់នៅ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានសភាពដុបដាបយ៉ាងខ្លាំង ដោយសារតែពួកគាត់គ្មានលទ្ធភាពដើម្បីទ្រទ្រង់ជីវភាពគ្រួសារ ព្រោះទិន្នផលកសិកម្មទទួលបានទាប ហើយបែរជាងាកទៅរកខ្ចីបំណុលគេដើម្បីមកដោះស្រាយបញ្ហាជីវភាពគ្រួសាររបស់ពួកគាត់ ។ ពួកគាត់បាននិយាយថា មូលហេតុដែលការទទួលបានទិន្នផលកសិកម្មទាបគឺដោយសារតែពួកគាត់ខ្វះខាតជំនាញ បច្ចេកទេស និង ប្រព័ន្ធធារាសាស្ត្រនៅមានកម្រិត ។

លើសពីនេះទៅទៀត បញ្ហាទាំងអស់នេះបានជះឥទ្ធិពលទៅដល់ការរៀនសូត្រ សិក្សាអប់រំរបស់កូនៗរបស់ពួកគាត់ ដោយពុំមានលទ្ធភាពផ្គត់ផ្គង់នូវសម្ភារៈសិក្សា និងថ្លៃសិក្សាឡើយដោយពួកគាត់ជាទូទៅមានលទ្ធភាពរៀនសូត្របានត្រឹមតែកម្រិតបឋមសិក្សា និង អនុវិទ្យាល័យតែប៉ុណ្ណោះ ។ ដូច្នេះពួកគាត់ ត្រូវបង្ខំចិត្តបោះបង់សិក្សាចោលដើម្បីជួយឪពុកម្តាយរបស់គេ ដោយជួយការងារផ្ទះ ការងារសំណង់ ការងារកសិកម្ម និង ចំណាកស្រុក ដើម្បីជួយសម្រួលបន្ទុកគ្រួសារ ។ ទន្ទឹមនឹងនេះផងដែរការផ្តល់តម្លៃទៅលើស្ត្រី និង កុមារក៏នៅមានកម្រិតនៅឡើយពួកគាត់ត្រូវទទួលបានការមើលងាយ និងអំពើហិង្សាពីពួកបុរសៗ ព្រោះថាបុរសៗអ្នកប្រកបរបរចិញ្ចឹមគ្រួសារទាំមូល ចំណែកឯស្រីនៅធ្វើការងារផ្ទះតែប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀតចំពោះផ្នែកការថែទាំសុខភាព សុខុមាលភាពវិញ នៅពេលមានជម្ងឺពួកគាត់ពុំសូវមកព្យាបាលនីមន្ទីរពេទ្យឡើយ គឺភាគច្រើនពួកគាត់ពឹងផ្អែកលើជំនឿពីបុរាណ និង ការប្រើប្រាស់ថ្នាំបុរាណ ។

តាមរយៈស្ថានភាពទាំងអស់នេះហើយ វាបានឆ្លុះបញ្ចាំងនូវស្ថានភាពរស់នៅ និងជីវភាពប្រចាំថ្ងៃរបស់ប្រជាជននៅក្នុងឃុំភ្នំដិននៅមុនពេលមិនទាន់បង្កើតសហគមន៍កសិកម្ម ពិតជាមានភាពលំបាក និងកង្វះខាតនៅបច្ចេកទេសផ្សេងៗទាក់ទងនឹងវិស័យកសិកម្ម ដែលជាហេតុធ្វើឱ្យមានគោលគំនិតនៃការបង្កើតសហគមន៍កសិកម្មឡើង ដោយបានសុំការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ និងស្ថាប័នពាក់ព័ន្ធនានា ហើយផ្តល់តួនាទីទៅឱ្យអគ្គនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មជាអ្នកត្រួតពិនិត្យទៅលើរាល់សកម្មភាពរបស់សហគមន៍កសិកម្មទាំងអស់ ។

### ៣.១.២. ស្ថានភាពរស់នៅក្រោយពេលបង្កើតសហគមន៍កសិកម្ម

ក្រាហ្វិក ៣.១ បង្ហាញពីស្ថានភាពរស់នៅក្រោយពេលបង្កើតសហគមន៍កសិកម្មភ្នំដិន សែនសុខ




ប្រភព៖ សៀវភៅសមិទ្ធផលប្រចាំឆ្នាំសហគមន៍កសិកម្មភ្នំដិនសែនសុខ

បើយោងទៅតាមក្រាហ្វិកដែលបានពីឯកសារចាស់ៗក្នុង ២០១៥ ស្តីពីស្ថានភាពគ្រប់គ្រងសហគមន៍កសិកម្មភ្នំដិន សែនសុខ ដែលគេបានធ្វើការសម្ភាសន៍ជាមួយប្រជាជននៅក្នុងសហគមន៍ផ្ទាល់បានបង្ហាញទិន្នន័យថា ការធ្វើកសិកម្មបន្ទាប់ពីបង្កើតសហគមន៍រួច ពួកគាត់ទទួលបានទិន្នផលកសិកម្មខ្ពស់ជាងមុនច្រើនណាស់ដែលបានជួយលើកកម្ពស់ដល់កម្រិតជីវភាពប្រជាជនក្នុងសហគមន៍ចំនួន ៧៥ % បើធៀបទៅនឹងការងារផ្សេងៗទៀត ។ ក្នុងនោះការបង្កើតការងារបន្ថែម ដូចជាការងារដាំផ្សិត ដាំបន្លែ ការចិញ្ចឹមសត្វមានចំនួន ៥៨ % ។ ដូចគ្នានេះដែរវិស័យអប់រំមានចំនួន ៤៣% ដោយសារតែនៅក្នុងគ្រួសារនីមួយៗមានកម្រិតជីវភាពសមរម្យអាចមានលទ្ធភាពគ្រប់គ្រាន់ដើម្បីឱ្យកូនចូលរៀនបានច្រើនជាងមុន ។

យោងតាមការសម្ភាសន៍បន្ថែមរបស់យើងខ្ញុំ បានធ្វើការសាកសួរពីប្រជាពលរដ្ឋ និងសម្ភាសន៍ជាមួយនឹងលោក **មេន ប៊ន** ជាប្រធានក្រុមប្រឹក្សាភិបាលរបស់សហគមន៍កសិកម្មភ្នំដិន សែនសុខបន្ថែមរួចមកបង្ហាញថា ក្រោយពីបង្កើតសហគមន៍កសិកម្មនេះ ពីឆ្នាំ ២០១៤ មកដល់ឆ្នាំ ២០២០ នេះកម្រិតជីវភាពប្រជាជនមានការប្រសើរឡើងជាងមុន តាមរយៈការបង្កើតមុខរបរឥណទាន និងមុខរបរផ្គត់ផ្គង់ដែលបានជួយសម្រួលដល់ប្រជាពលរដ្ឋឱ្យមានលទ្ធភាពនៅក្នុងដំណើរផលិតកម្មកសិកម្ម ។ ក្រៅពីនេះសហគមន៍បានធ្វើការបណ្តុះបណ្តាលប្រជាពលរដ្ឋពីវិធីសាស្ត្រ ការពារ ប្រើប្រាស់សម្ភារៈកសិកម្ម និងបច្ចេកទេសថែទាំទៅតាមដំណាក់កាលនីមួយៗ ចាត់តាំងពីដំបូងរហូតដល់ពេលប្រមូលផលដែលធ្វើយ៉ាងណាជម្រុញឱ្យមានកំណើនទិន្នផល តាមរយៈបច្ចេកទេសកសិកម្មបែបទំនើប ។ ជាពិសេសទៅទៀត ក្រោយបង្កើតសហគមន៍កសិកម្ម ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានទទួលបាននូវអត្ថប្រយោជន៍ជាច្រើនពីសហគមន៍ដូចជា កម្ចីឥណទានអត្រាការប្រាក់ទាប ថ្នាំកសិកម្ម ដីគីមី ស្វែងរកទីផ្សារ និងទទួលបាននូវកម្រិតជីវភាពក្នុងគ្រួសារល្អប្រសើរដែលនាំប្រទេសមានការអភិវឌ្ឍ និងជួយកាត់បន្ថយភាពក្រីក្រនៅក្នុងសង្គម ។

ចំពោះការអភិវឌ្ឍវិញមានភាពរីកចម្រើន និងងាយស្រួលជាងមុន ដោយមានផ្លូវជាតិ ផ្លូលំ សាលារៀនមន្ទីរពេទ្យ ដើម្បីអោយមនុស្សជំនាន់ក្រោយ និង មនុស្សរស់នៅបច្ចុប្បន្នមានភាពងាយស្រួលក្នុងការប្រកបរបរចិញ្ចឹមជីវិត ។ ចំពោះផ្នែកសន្តិសុខវិញមានសណ្តាប់ធ្នាប់ល្អ គ្មានអំពើលួចឆក់ប្លន់ ដែលប៉ះពាល់ដល់ការប្រកបរបររបស់ប្រជាជនឡើយ ។ មិនត្រឹមតែប៉ុណ្ណោះប្រព័ន្ធអគ្គីសនីវិញមានស្ទើរគ្រប់ផ្ទះ និង មានទឹកគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ ។ បើនិយាយពីស្ថានភាពរស់នៅក្រោយឆ្នាំ ប្រជាជននៅទីនោះគឺមិនសូវជាជឿនលឿនប៉ុន្មានទេ ពីព្រោះមានអ្នកចេះដឹងតិចតួច។ សព្វថ្ងៃនេះបើប្រៀបធៀបទៅនឹងឆ្នាំមុនៗ គឺវាមានភាពផ្ទុយស្រឡះពីមុន ព្រោះពេលនេះមាន អ្នកដឹកនាំជាច្រើនមានភាពវៃឆ្លាតដែលបានសាងសង់សាលារៀនគឺ សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យជាច្រើនដែលអាចឱ្យកុមារាកុមារីបានចូលរៀនបានស្ទើរទូទាំងស្រុកដែលអាចកាត់បន្ថយអត្រាការ មិនចេះអក្សរបានមួយភាគធំរបស់ប្រជាពលរដ្ឋក្នុងឃុំភ្នំដិននឹងបានកាត់បន្ថយការចំណាយផ្សេងៗក្នុងកាធ្វើដំណើរទៅរៀននៅសាលាឆ្ងាយពីផ្ទះ។ នេះគឺជាសមិទ្ធផលល្អសំរាប់ប្រទេសជាតិក្នុងការជួយអភិវឌ្ឍន៍ប្រទេសលើគ្រប់វិស័យ ។

សេដ្ឋកិច្ចរបស់ឃុំភ្នំដិនតាំងពីដើមប្រជាជនរស់នៅក្នុងសហគមន៍នេះប្រកបរបរធ្វើស្រែចំការ និងត្បាញហូលជាដើម ។ បច្ចុប្បន្ននេះប្រជាជនភូមិនេះ មានការបង្កើនមុខរបរបន្ថែមដូចជា ត្បាញហូល ធ្វើនំតាមរដូវនិងមានការលក់ដូរ។ បើប្រៀបធៀបប្រជាជនតាំងពីមុនមកបច្ចុប្បន្ននេះមានជីវភាពធូរធារច្រើនណាស់ការប្រមូលផលដំណាំផ្សេងៗគឺមានការមានការកើនឡើងខ្ពស់ជាលំដាប់ រហូតមកដល់បច្ចុប្បន្ននេះ។

## ៣.២. សមិទ្ធផលរបស់សហគមន៍កសិកម្មភ្នំដិនសែនសុខ

ចាប់តាំងពីបង្កើតឡើងនូវសហគមន៍កសិកម្មភ្នំដិនសែនសុខ ក្នុងឆ្នាំ២០១៤ រហូតមកដល់សព្វថ្ងៃនេះ ក្រោមការដឹកនាំ គ្រប់គ្រង និងការអភិវឌ្ឍយ៉ាងល្អពី ប្រធានក្រុមប្រឹក្សាភិបាល គណៈកម្មការសហគមន៍កសិកម្ម សមាជិកសហគមន៍កសិកម្ម អាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ក៏ដូចជាប្រពលរដ្ឋនៅក្នុងមូលដ្ឋាន ដែលបានខិតខំប្រឹងប្រែងធ្វើការងារសំខាន់ៗជាច្រើនដូចជា ការបើកវគ្គបណ្តុះបណ្តាលទាក់ទងនឹងវិស័យកសិកម្ម រួមមានដំណើរការនៃការធ្វើកសិកម្ម ការថែរក្សា ការពារ និងការប្រើប្រាស់ឧបករណ៍កសិកម្ម ព្រមទាំងវិធីសាស្ត្រ បច្ចេកទេសផ្សេងទៀតជាដើម ។ បន្ថែមលើនេះផងដែរសហគមន៍ក៏បានសម្រេចនៅលទ្ធផលជោគជ័យជាច្រើនផងដែរដូចជា ៖

- ការរៀបចំសកម្មភាពមហាសន្និបាតប្រចាំឆ្នាំ និងសកម្មភាពរដ្ឋបាលជាច្រើន
- រៀបចំលក្ខន្តិកៈសហគមន៍ និងបទបញ្ជាផ្ទៃក្នុង
- កំណើនចំណូលពីមុខរបរឥណទាន មុខរបរផ្គត់ផ្គង់
- ទីស្នាក់ការសហគមន៍ និងសាលប្រជុំសម្រាប់សហគមន៍កសិកម្ម
- ចំនួនសមាជិកសហគមន៍មានការកើនឡើង
- ដើមទុនកើនឡើងដោយសារមានកំណើនភាគហ៊ុន
- ក្លាយជាសហគមន៍កសិកម្មគម្រូ នៅ ក្នុងខេត្តតាកែវ
- រ៉ឺម៉កសម្រាប់ជួល
- ស្ថាបនាផ្លូវលំក្រាលក្រោសនៅក្នុងសហគមន៍
- ឧបករណ៍កសិកម្ម ដូចជា ៖ គោយន្ត ម៉ាស៊ីនបូមទឹក និងទ្រព្យសម្បត្តិផ្សេងៗទៀត ។

## ៣.៣. បញ្ហាប្រឈមចំពោះការអភិវឌ្ឍសហគមន៍កសិកម្ម

ទោះបីជានៅក្នុងដំណើរការអភិវឌ្ឍន៍សហគមន៍កសិកម្មភ្នំដិនសែនសុខ មានការអភិវឌ្ឍបានល្អប្រសើរយ៉ាងណាក៏ដោយ ក៏នៅតែមានបញ្ហាមួយចំនួនតូច ដែលជះឥទ្ធិពលអវិជ្ជមានទៅលើដំណើរការអភិវឌ្ឍន៍នេះដូចជា៖

- ទ្រឹស្តីសហគមន៍កសិកម្មជាទ្រឹស្តីថ្មី ពុំទាន់មានការអនុវត្តណាមួយឱ្យបានទូលំទូលាយនៅតាមតំបន់នោះទេ ដែលជាកត្តាធ្វើឱ្យការយល់ដឹងរបស់ប្រជាជននៅតាមតំបន់នីមួយៗមានកម្រិត

ទាប ដែលជាហេតុធ្វើឱ្យមានការលំបាកនៅក្នុងការរៀបចំ និងការអនុវត្តតាមស្ថានភាពជាក់ស្តែង

- ការរក្សាពូជស្រូវបានជួបប្រទះបញ្ហាប្រឈម ដោយសារពុំទាន់មានឃ្លាំងទុកដាក់មិនបានសមស្របតាមបទដ្ឋានបច្ចេកទេស ដែលធ្វើឱ្យមានបញ្ហាប្រឈមនៅតាមមូលដ្ឋានខ្លះក្នុងពេលកន្លងមក
- បម្រែបម្រួលអាកាសធាតុ ជួបបញ្ហាគ្រោះធម្មជាតិ (ទឹកជំនន់, គ្រោះរាំងស្ងួត)
- កង្វះដីសម្រាប់ធ្វើរោងម៉ាស៊ីនសម្ងួតស្រូវ
- កង្វះដីបន្ថែមសម្រាប់ធ្វើស្រូវគម្រូ
- កង្វះថវិកាសម្រាប់ពង្រីកមុខរបរ
- ប្រព័ន្ធធារាសាស្ត្រនៅមានតិចតួច
- កង្វះខាតផ្លូវគមនាគមន៍ ក្នុងការដឹកជញ្ជូនផលិតផលកសិកម្ម
- បញ្ហាធំចុងក្រោយដែលជាកង្វល់របស់សហគមន៍កសិកម្ម និងប្រជាពលរដ្ឋនៅក្នុងសហគមន៍ គឺក្រសួងពាក់ព័ន្ធមិនយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហា តម្លៃទីផ្សារផលិតផលកសិកម្ម ជាពិសេសតម្លៃស្រូវ ដែលបណ្តាលមកពីឈ្មួលកណ្តាលបន្ទាបតម្លៃ បង្កជាផលប៉ះពាល់ដល់ដំណើរការផលិត និងកម្រិតជីវភាពរបស់ប្រជាពលរដ្ឋមានការអន់ថយ ។

## ៣.៤. ដំណោះស្រាយចំពោះបញ្ហាប្រឈមនៃការអភិវឌ្ឍសហគមន៍កសិកម្ម

ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនេះ សហគមន៍កសិកម្មភ្នំជិនសែនសុខ បានចាត់វិធានការ ដើម្បីដោះស្រាយបញ្ហាទាំងនេះដូចខាងក្រោម៖

- សហគមន៍កសិកម្ម បានបើកវគ្គបណ្តុះបណ្តាលទាក់ទងនឹង ដំណើរការនៃការធ្វើកសិកម្ម ការការពារសត្វចង្រៃ ការប្រើប្រាស់ជី ថ្នាំកសិកម្ម បច្ចេកទេសបង្កើនទិន្នផល ទ្រឹស្តីផ្សេងៗ បទបញ្ជារបស់សហគមន៍កសិកម្មដល់សមាជិកសហគមន៍ និងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានទាំងមូល
- រៀបចំពេលវេលា បែងចែកកាលវិភាគប្រចាំការនៅទីស្នាក់ការសហគមន៍ឱ្យបានត្រឹមត្រូវ
- ផ្តល់ឥណទានដល់សមាជិក ប្រជាពលរដ្ឋក្នុងសហគមន៍នូវអត្រាការប្រាក់ទាប
- ស្នើសុំជំនួយផ្នែកបច្ចេកទេសបន្ថែមពីអគ្គនាយកដ្ឋានអភិវឌ្ឍសហគមន៍កសិកម្ម
- ខ្ចីថវិកាពីធនាគារ
- ស្វែងរកការវិនិយោគបន្ថែម

- បង្កើតជារោងមាស៊ីនឡសម្ងួតស្រូវ
- បង្កើតឃ្លាំងស្តុកទិន្នផលអោយបានត្រឹមត្រូវតាមបច្ចេកទេស
- ស្វែងរកទីផ្សារដែលអាចលក់ផលិតផលកសិកម្មបានខ្ពស់
- ផ្គត់ផ្គង់ពូជស្រូវដល់ប្រជាពលរដ្ឋ និងទទួលនាំចូលវិញដោយឱ្យតម្លៃថ្លៃជាងឈ្មួញ ដើម្បីកាត់ផ្តាច់ទីផ្សារឡើង ចុះតម្លៃដែលបណ្តាលពីឈ្មួញកណ្តាល ។

## ៣.៥.ការវិភាគ SWOT

ក្រោយពីបានធ្វើការចុះកម្មសិក្សា នៅក្នុងសហគមន៍កសិកម្មភ្នំដិនសែនសុខ ដែលស្ថិតនៅក្នុងភូមិទទឹង ឃុំភ្នំដិន ស្រុកគិរីវង់ ខេត្តតាកែវ ពីការអភិវឌ្ឍវិស័យកសិកម្មរបស់សហគមន៍កសិកម្មភ្នំដិនសែនសុខរួចមក យើងខ្ញុំបានយល់ដឹងអំពី ដំណើរការនៃការធ្វើកសិកម្ម វិធីសាស្ត្រក្នុងការធ្វើផែនការ យុទ្ធសាស្ត្រនៃការអភិវឌ្ឍ និងដំណើរការ នៃការអភិវឌ្ឍរបស់សហគមន៍កសិកម្មកាន់តែច្បាស់។ យើងខ្ញុំបានសង្កេតឃើញ សហគមន៍កសិកម្មទាំងមូលក៏មាននូវ ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងកត្តាគម្រាមកំហែងផងដែរ។ ចំណុចទាំងអស់នោះ ត្រូវបានធ្វើការវិភាគដូចខាងក្រោមនេះ ៖

### ៣.៥.១. ការវិភាគលើចំណុចខ្លាំង

- មានផែនការសកម្មភាព យុទ្ធសាស្ត្រច្បាស់លាស់
- អនុវត្តន៍រាល់គម្រោងផែនការដែលបានគ្រោងទុក
- មានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់
- ប្រធានក្រុមប្រឹក្សាភិបាល គណៈកម្មាធិការ និងសមាជិកសហគមន៍មានទំនួលខុសត្រូវខ្ពស់ទៅលើតួនាទី និងភារកិច្ច
- មានសមិទ្ធផលជាច្រើន
- ធនធានកសិកម្មនៅក្នុងសហគមន៍កសិកម្មមានការកើនឡើង
- ពង្រីកមុខរបរសម្រាប់រកចំណូលបន្ថែម
- មានទំនាក់ទំនាក់ល្អជាមួយស្ថាប័នពាក់ព័ន្ធ
- ប្រជាកសិករ បានយល់ដឹងបន្ថែមទាក់ទងនឹង ដំណើរការនៃការធ្វើកសិកម្មដើម្បីទទួលបានទិន្នផលខ្ពស់
- សមាជិកចូលរួមរាល់កិច្ចប្រជុំទាំងអស់ដែលបានរៀបចំឡើង ។

### ៣.៥.២. ការវិភាគលើចំណុចខ្សោយ

- ធនធាននៅមានកម្រិត( មនុស្ស សម្ភារៈ និងថវិកា)
- ចំណូលមិនទៀងទាត់
- ខ្វះខាតឧបករណ៍កសិកម្មទំនើបៗ
- ប្រជាពលរដ្ឋមិនទាន់យល់ច្បាស់ពីបញ្ហាប្រឈមនៅពេលអនាគត
- ការអនុវត្តផែនការនៅមានកម្រិត
- សមត្ថភាពផ្នែកបច្ចេកទេសរបស់សមាជិកសហគមន៍នៅមានចំណុចខ្វះខាត
- ការផ្សព្វផ្សាយពីការបើកវគ្គបណ្តុះបណ្តាលមិនទាន់បានទូលំទូលាយ
- ជីវភាពប្រជាជននៅមានកម្រិត
- ប្រជាកសិករខ្លះមិនទាន់មានទំនុកចិត្ត
- ប្រជាពលរដ្ឋខ្វះលទ្ធភាព និង គ្មានបច្ចេកទេសពីការធ្វើកសិកម្មតាមបែបទំនើប។

### ៣.៥.៣. ឱកាស

- មានការស្ម័គ្រចិត្តចូលរួមជាសមាជិកពីប្រជាកសិករនៅក្នុងតំបន់
- មានការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលដូចជា JICA , FAO, CWCDD, FACT, ActionAid និងអង្គការផ្សេងៗទៀត
- មានការយកចិត្តទុកដាក់ខ្ពស់ពីអគ្គនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម
- មានការសហការយ៉ាងល្អជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ
- ក្លាយជាសហគមន៍គម្រូនៅក្នុងស្រុក និង រាជធានីខេត្ត
- តម្លៃផលិតផលកសិកម្មលក់ចេញមានតម្លៃប្រសើរជាងមុន
- ទាក់ទាញការវិនិយោគ និងជំនួយពីស្ថាប័នពាក់ព័ន្ធ ។

### ៣.៥.៤. ការគំរាមកំហែង

- ការអន្តរាគមន៍ពីមន្ត្រីជំនាញ និងមន្ត្រីរដ្ឋបាលតាមស្ថាប័ននៅមានកម្រិត
- ទទួលការគំរាមកំហែង ការជិះជាន់ពីសំណាក់អ្នកមានអំណាចលើបញ្ហាដីធ្លី
- បញ្ហាការឡើង ចុះតម្លៃផលិតផលកសិកម្ម បង្កឡើងដោយឈ្មួញកណ្តាល
- បញ្ហាអាកាសធាតុមិនអំណោយផល ដល់ការធ្វើកសិកម្ម ២ រដូវក្នុងមួយឆ្នាំ ។

# សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

បើយោងទៅតាមរបាយការណ៍នៃកម្មសិក្សាស្តីពី ការអភិវឌ្ឍវិស័យកសិកម្មរបស់សហគមន៍កសិកម្មភ្នំដិន សែនសុខ ដែលមានទីតាំងស្ថិតនៅ ភូមិទទឹង ឃុំភ្នំដិន ស្រុកគិរីវង់ ខេត្តតាកែវ បានបង្ហាញឱ្យឃើញដំណើរការនៃការអភិវឌ្ឍវិស័យកសិកម្មរបស់សហគមន៍កសិកម្មភ្នំដិនសែនសុខ មានភាពល្អប្រសើរគួរឱ្យកត់សម្គាល់ ហើយរីកមម្រើនល្អពីមួយឆ្នាំទៅមួយឆ្នាំ ចាប់តាំងពីការរៀបចំកកើតសហគមន៍កសិកម្មមក ដូចជាកសាងនូវឯកសារបទដ្ឋានគតិយុត្តិ ការរៀបចំរចនាសម្ព័ន្ធ ការបែងចែកតួនាទី ភារកិច្ច ការរៀបចំផែនការ យុទ្ធសាស្ត្រផែនការ ការអនុវត្តផែនការ ការដោះស្រាយបញ្ហាប្រឈមនានា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការរៀបចំផែនការសម្រាប់ឆ្នាំបន្តបន្ទាប់ ។ ជាក់ស្តែងសហគមន៍កសិកម្មភ្នំដិនសែនសុខ បានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍលើវិស័យកសិកម្ម ការអភិវឌ្ឍផ្នែកបច្ចេកទេសដល់ប្រជាកសិករ ជាពិសេសបានបង្កើននូវកម្រិតជីវភាពរស់នៅរបស់ប្រជាជននៅក្នុងមូលដ្ឋានឱ្យមានភាពប្រសើរជាងមុន និងបានបង្កើនកំណើនសេដ្ឋកិច្ច ដើម្បីសម្រួលដល់ការអភិវឌ្ឍប្រទេសប្រកបដោយនិរន្តរភាព ។

បន្ថែមលើសពីនេះទៀត មានកត្តាជាច្រើនទៀតដែលជាកម្លាំងចលករជម្រុញឱ្យ សហគមន៍កសិកម្មភ្នំដិន សែនសុខ មានការរីកចម្រើន គឺដោយសារតែមានការយកចិត្តទុកខ្ពស់ពីក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ អគ្គនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម លោកប្រធានក្រុមប្រឹក្សាភិបាល ការសហការយ៉ាងល្អពីគណៈកម្មាធិការត្រួតពិនិត្យ សមាជិក និងប្រជាពលរដ្ឋក្នុងអនុវត្តផែនការសកម្មភាពទាំងឡាយរបស់សហគមន៍កសិកម្មបានយ៉ាងល្អ ។ បន្ថែមលើនេះសហគមន៍កសិកម្មភ្នំដិនសែនសុខ មានទំនាក់ទំនងល្អជាមួយអាជ្ញាធររដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ និងដៃគូផ្សេងទៀត។ ជាពិសេសទៀតសមាជិកសហគមន៍មានការយល់ដឹងខ្ពស់ និងបានចូលរួមរាល់វគ្គបណ្តុះបណ្តាលបច្ចេកទេសរបស់ សហគមន៍ អង្គការដៃគូ និងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត ។ តាមរយៈការសាកសួរលោកប្រធានក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្មភ្នំដិនសែនសុខ បន្ទាប់ពីសមាជិកក្នុងសហគមន៍ និងប្រជាជននៅក្នុងឃុំបានយល់ដឹងពីបច្ចេកទេសធ្វើឱ្យពួកគាត់ប្រើប្រាស់ឧបករណ៍កសិកម្មបានយ៉ាងល្អ និងត្រឹមត្រូវ ហើយបានការកាត់បន្ថយចំណាយលើដំណើរការនៃការធ្វើកសិកម្ម ហើយជំនួសមកវិញទទួលបានទិន្នផលខ្ពស់ជាងមុន ។ រាល់សមិទ្ធផលទាំងអស់នេះបានបញ្ជាក់ឱ្យឃើញពីការរីកចម្រើន ក្រោមការដឹកនាំល្អរបស់លោកប្រធានក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្មភ្នំដិនសែនសុខ និងសមាជិកសហគមន៍ទាំងអស់ក្នុងការអភិវឌ្ឍវិស័យកសិកម្មនៅក្នុងសហគមន៍និងមូលដ្ឋានរបស់ពួកគាត់ ។

សរុបសេចក្ដីមក ការអភិវឌ្ឍវិស័យកសិកម្មរបស់សហគមន៍កសិកម្មភ្នំដិន សែនសុខ គឺបានដើរតួនាទីយ៉ាងសំខាន់ក្នុងគោលបំណងការពារ គ្រប់គ្រង ប្រើប្រាស់ លើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋ និងអភិវឌ្ឍវិស័យកសិកម្មប្រកបដោយប្រសិទ្ធភាព និងនិរន្តភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រក្នុងសហគមន៍មូលដ្ឋាន ដែលស្របតាមគោលនយោបាយផែនការអភិវឌ្ឍជនបទរបស់រាជរដ្ឋាភិបាលដើម្បីជួយអភិវឌ្ឍន៍ភូមិ ឃុំឱ្យមានការរីកចម្រើន ។

## ២. ការផ្ដល់អនុសាសន៍

ដើម្បីជាយុទ្ធសាស្ត្រនៅក្នុង ការអភិវឌ្ឍវិស័យកសិកម្មរបស់សហគមន៍កសិកម្មភ្នំដិនសែនសុខប្រកបដោយប្រសិទ្ធភាព និរន្តភាព និងចីរភាព យើងខ្ញុំសូមធ្វើការបញ្ចេញមតិ និងផ្ដល់យោបល់នៅក្នុងន័យចូលរួមកែលម្អនូវចំណុចខ្វះខាតទាំងឡាយ ដើម្បីជួយសម្រួល និងពង្រឹងការអភិវឌ្ឍវិស័យកសិកម្មនៅក្នុងសហគមន៍កសិកម្មភ្នំដិន សែនសុខឱ្យកាន់តែល្អប្រសើរឡើងមួយកម្រិតថែមទៀត។

❖ **សហគមន៍កសិកម្ម**

- ពង្រឹងសមត្ថភាពរបស់សមាជិកក្នុងសហគមន៍ មូលដ្ឋានទាំងមូល ក្នុងការគ្រប់គ្រង តាមដានត្រួតពិនិត្យ វាយតម្លៃ និងការចូលរួមដោះស្រាយបញ្ហាផ្សេងៗនៅក្នុងសហគមន៍
- ផ្សព្វផ្សាយបន្ថែមអំពីសកម្មភាពថ្មីៗរបស់សហគមន៍
- បណ្ដុះបណ្ដាលជំនាញថ្មីដល់សមាជិកទាំងអស់
- ពង្រឹងអនុវត្តផែនការឱ្យបានល្អប្រសើរ
- ជម្រុញឱ្យសមាជិកទាំងអស់ធ្វើសកម្មភាពព្រមគ្នាប្រកបដោយប្រសិទ្ធភាព ការចេះយោគយល់អធ្យាស្រ័យគ្នា និងលើកទឹកចិត្តគ្នា ដើម្បីធ្វើការអភិវឌ្ឍវិស័យកសិកម្ម
- ខិតខំទាក់ទាញក្រសួងពាក់ព័ន្ធ និងស្ថាប័នផ្សេងៗដើម្បីពង្រីកមុខរបរ
- ផ្ដល់លិខិតសរសើរ និងជួយផ្គត់ផ្គង់តម្រូវការបន្ថែម ដើម្បីលើកទឹកចត្តិដល់កសិករគម្រូ ។

❖ **ប្រជាពលរដ្ឋ**

- ចំណាយពេលវេលាមួយចំណែកក្នុងការចូលរួមវគ្គបណ្ដុះបណ្ដាល ដែលរៀបចំឡើងដោយសហគមន៍កសិកម្មឱ្យបានទៀតទាត់
- ត្រូវពង្រឹងសមត្ថភាព ស្មារតី និង បច្ចេកទេស នៅក្នុងដំណើរការធ្វើកសិកម្ម
- ចូលរួមអនុវត្តន៍តាមច្បាប់ ឬគោលការណ៍ដែលបានរៀបចំដោយសហគមន៍
- លើកទឹកចិត្ត និងផ្ដល់ទំនុកចិត្តដល់ការបណ្ដុះបណ្ដាល

- យកចិត្តទុកដាក់ក្នុងដំណើរការធ្វើកសិកម្ម ដើម្បីបង្កើនទិន្នផលតាមទីផ្សារ ។

❖ **អគ្គនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម និង អាជ្ញាធរមូលដ្ឋាន**

- គួរតែបង្កើនកិច្ចសហការគ្នាឱ្យបានច្រើនជាងមុនរវាងស្ថាប័នជំនាញពាក់ព័ន្ធ និង អាជ្ញាធរមូលដ្ឋានឱ្យបានច្រើនជាងមុន
- បន្តជួសជុលឡើងវិញ និងពង្រីកប្រព័ន្ធគមនាគមន៍ ប្រព័ន្ធធារាសាស្ត្របន្ថែមដល់តំបន់គោលដៅដែលមិនទាន់មានប្រភពប្រើប្រាស់គ្រប់គ្រាន់ ដូចជាអាងស្តុកទឹក ព្រែក ប្រឡាយបង្ហូរទឹកជាដើម
- ជម្រុញឱ្យមានការបង្កើតទីផ្សារតាមមូលដ្ឋានសម្រាប់លក់កសិផលរបស់កសិករ
- ជម្រុញនូវសមត្ថភាពកសិករបន្ថែមតាមរយៈ បច្ចេកវិទ្យា ដូចជាគ្រឿងយន្តកសិកម្ម គ្រាប់ពូជផ្សេងៗ
- ស្វែងរកទីផ្សារសម្រាប់លក់ផលិតផលកសិកម្ម
- ឧបត្ថម្ភធនដល់កសិករក្នុងការពង្រីកវិស័យកសិកម្ម ។

❖ **អង្គការក្រៅរដ្ឋាភិបាល**

- ការសាងសមត្ថភាពបន្ថែមលើការងាររដ្ឋបាលដល់សហគមន៍ និងការគ្រប់គ្រងហិរញ្ញវត្ថុបន្ថែមដល់សហគមន៍
- បន្តការផ្តល់ជំនួញគាំទ្រដល់សហគមន៍កសិកម្មនៅក្នុងប្រទេសកម្ពុជា និងជួយស្វែងអង្គការដៃគូអភិវឌ្ឍន៍ផ្សេងៗ ។

# ឯកសារយោង


- Economic Development 12th Edition , Michael P. Todaro and Stephen C. Smith 2009
- សៀវភៅ សេដ្ឋកិច្ចអភិវឌ្ឍន៍ ភាគទី២, រៀបរៀងដោយ សាស្ត្រាចារ្យ យៃម សំបូ (បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤)
- សៀវភៅ សេចក្តីផ្តើមនៃការអភិវឌ្ឍជនបទ, ចងក្រងដោយ អង្គការ ស៊ីដសេ CIDSE, ទំព័រទី២
- និស្សិតៈ ឡៃ បូរ៉ាពីន, សៀវភៅសារណាបញ្ចប់ការសិក្សា "ការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា",ទំព័រទី៦
- សារណាបញ្ចប់ការសិក្សា, កម្មវិធីអភិវឌ្ឍន៍របស់ឃុំឆ្លូង ខេត្តក្រចេះ, ឆ្នាំ២០០២ - ២០០៦
- សារណាបញ្ចប់កាសិក្សា ការលើកកម្ពស់ជីវភាពគ្រួសារតាមរយៈការដាំបន្លែ, និស្សិតៈ អិន សុគា និង ឡាញ់ ស្រីនាថ
- និស្សិតៈ ព្រំ បញ្ញា និង ហួ លីហួង, សារណាបញ្ចប់ការសិក្សា ( ការអភិវឌ្ឍជនបទ ឃុំព្រៃរំ ស្រុកល្វាឯម ខេត្តកណ្តាល )
- សៀវភៅ Michael P.Todaro and Stephen C.Smith, ២០០៩ ទំព័រ ១១២
- ការអភិវឌ្ឍវិស័យកសិកម្មសហគមន៍ត្រពាំងសង្កែ , និស្សិតៈ ឡុង សុខជា និង សុត វុន , ទំព័រទី ៨, របាយការណ៍កម្មសិក្សា
- វេបសាយ https://Regional-Economic-Development-Francois-Perroux/dp (ចូលមើលថ្ងៃទី ០៣ ឧសភា ឆ្នាំ ២០២០)
- ការអភិវឌ្ឍជនបទ ឃុំព្រែករំ ស្រុកល្វាឯម ខេត្តកណ្តាល,និស្សិតៈ ព្រំ បញ្ញា និង ហួ លីហួង, សារណាបញ្ចប់ការសិក្សា
- សារណាបញ្ចប់ការសិក្សា( ការអភិវឌ្ឍវិស័យកសិកម្មប្រទេសកម្ពុជា ), និស្សិតៈ ឡៃ បូរ៉ាពីន, ទំព័រទី ៩ និង ១០
- បណ្ឌិត ឈុន ពហុ, សៀវភៅ ការអភិវឌ្ឍជនបទ ( ភ្នំពេញ ៖ ស.ភ.វ.ស, ២០០៩ ) , ទំព័រ ២៣
- នួន វណ្ណា , ឆៃលាង បញ្ញា និងឯម វណ្ណារ៉ា, ( គំរោងអភិវឌ្ឍន៍សហគមន៍អ្នកក្រីក្រក្នុងរាជធានីភ្នំពេញ ) របាយការណ៍កម្មសិក្សាថ្នាក់បរិញ្ញាបត្រ, ២០០៦, ទំព័រទី ១៣
- វេបសាយ https://en.wikipedia.org/wiki/Rural-Community-Development , (ចូលមើលថ្ងៃទី ២០ ឧសភា ២០២០)

- ( សៀវភៅ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ) ,ឆ្នាំ ២០១៤- ២០១៨ ,រៀបចំដោយ នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ ក្រសួងអភិវឌ្ឍន៍ជនបទ ,ទំព័រទី ០៦
- សៀវភៅ គោលគំនិតសហគមន៍កសិកម្ម, ឆ្នាំ២០១៥, រៀបចំដោយ (គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅការធ្វើជំនួញ BPAC នៃនាយដ្ឋានសហគមន៍កសិកម្ម)
- គោលការណ៍ណែនាំស្តីពី ការសិក្សាស្រាវជ្រាវសម្រាប់បណ្តុះបណ្តាលសមាជិកសហគមន៍កសិកម្ម និងមន្ត្រីនៅកម្ពុជា , រៀបចំដោយៈ គម្រោង (BPAC), ឆ្នាំ២០១៥
- ច្បាប់ស្តីពី សហគមន៍កសិកម្ម, អនុម័តដោយរដ្ឋសភា ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៣
- វេបសាយ http://wmc.org.kh
- ស៊ុត សុជាមុនីរត្ន និងស៊ាង សុខ, ការអភិវឌ្ឍសហគមន៍របស់អង្គការស៊ីស៊ីឌីដើម្បីកាត់បន្ថយភាពក្រីក្រក្នុងខេត្តក្រចេះ , ស.ភ.វ.ស របាយការណ៍បញ្ចប់ការសិក្សា ២០១១, ទំព័រទី ៨,៩ ។
- ឡៅ ធន់សោភ័ណ្ឌ និងអន សុខអេង, ( ការអភិវឌ្ឍសហគមន៍នៅក្នុងភូមិព្រៃទទឹង ), របាយការណ៍បញ្ចប់ការសិក្សា ស.ភ.វ.ស
- សែម ឡុងឌី និងយឹង មឿន, ( ការអភិវឌ្ឍសហគមន៍តាមរយៈកសិកម្មចម្រុះ ), របាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ស.ភ.វ.ស ២០០៧, ទំព័រទី ១៦,១៧ ។
- http://fia.maff.gov.kh/newsdetail/skvYfIaFbf ( ចូលមើលថ្ងៃ ២៥ ឧសភា ឆ្នាំ ២០២០ )
- ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ៥ឆ្នាំលើកទី២, រៀបចំដោយក្រសួងអភិវឌ្ឍន៍ជនបទ
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤ - ២០១៨, រាជរដ្ឋាភិបាលកម្ពុជា, ឆ្នាំ២០១០
- សៀវភៅ ការគ្រប់គ្រងសហគមន៍កសិកម្មភ្នំដិន សែនសុខ, ២០១៤, ទំព័រទី ១១
- សៀវភៅ គោលការណ៍ណែនាំស្តីពី ការបែងចែកប្រាក់ចំណេញរបស់សហគមន៍កសិកម្មនៅប្រទេសកម្ពុជា, ឆ្នាំ ២០១៦ ។

## ឧបសម្ព័ន្ធ
## បញ្ជីសំណួរពាក់ព័ន្ធនឹងការស្រាវជ្រាវ
## សម្រាប់ធ្វើការសម្ភាសន៍នៅក្នុងសហគមន៍កសិកម្មភ្នំដិន សែនសុខ

១. ស្ថានភាពទូទៅរបស់សហគមន៍កសិកម្មភ្នំដិន សែនសុខ

- ប្រវត្តិ និងទីតាំងភូមិសាស្ត្ររបស់សហគមន៍
- រចនាសម្ព័ន្ធគ្រប់គ្រងរបស់សហគមន៍កសិកម្ម
- ទស្សនៈវិស័យ បេសកកម្ម សកម្មភាព និងគោលដៅរួម
- មូលនិធិពីស្ថាប័ននីមួយៗ
- សមិទ្ធិផលរបស់សហគមន៍
- ស្ថានភាពសហគមន៍កសិកម្មមុនពេល និងក្រោយពេលបង្កើតសហគមន៍ ។

២. តើប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ទទួលបានផលអ្វីខ្លះ ?

៣. តើប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ទទួលបានឱកាសការងារយ៉ាងដូចម្តេច ?

៤. តើពលរដ្ឋទទួលបានចំណេះដឹងទទួលបានចំណេះដឹងទូទៅ និងជំនាញបច្ចេកទេសអ្វីខ្លះពីសហគមន៍ ?

៥. តើប្រជាពលរដ្ឋទទួលបាននូវសេវានៃការបង្កើតមុខរបរថ្មីអ្វីខ្លះ?

៦. តើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាពាក់ព័ន្ធផ្សេងៗមានអ្វីខ្លះ ?

៧. តើប្រជាពលរដ្ឋមានសិទ្ធក្នុងការធ្វើសេចក្តីសម្រេចចិត្តអ្វីខ្លះ ?

៨. តើប្រជាពលរដ្ឋមានជីវភាពដូចម្តេច នៅពេលបង្កើតសហគមន៍ឡើង ?

៩. តើសហគមន៍មានគម្រោងអភិវឌ្ឍន៍អ្វីខ្លះបន្តទៀត ?

១០. តើសហគមន៍មានគោលនយោបាយអភិវឌ្ឍន៍ដូចម្តេចខ្លះ ?

១១. តើលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងនៅក្នុងសហគមន៍កសិកកម្ម ត្រូវបានរៀបចំឡើងដូចម្តេច ?

១២. តើសហគមន៍មានផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍អ្វីខ្លះ ?

១៣. តើសហគមន៍មានបញ្ហាប្រឈមអ្វីខ្លះ ដែលជួបប្រទះ ?

១៤. តើសហគមន៍ដោះស្រាយបញ្ហាទាំងនោះ ដោយរបៀបណាខ្លះ ?

១៥. តើប្រជាពលរដ្ឋពេញចិត្តចំពោះគោលនយោបាយ និងការអភិវឌ្ឍនរបស់សហគមន៍ដែរឬទេ ?

១៦. តើស្ថាប័នពាក់ព័ន្ធមានការវាយតម្លៃទៅលើសហគមន៍នេះយ៉ាងដូចម្តេចខ្លះ ?

១៧. តើសហគមន៍មានទិសដៅអភិវឌ្ឍន៍បន្តសម្រាប់ពេលអនាគតអ្វីខ្លះ ?

## ឧបសម្ព័ន្ធទី២



# ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំចូលជាសមាជិកសហគមន៍កសិកម្ម

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ : ........សី........សក្ខណា.................. ភេទ ស្រី..............................

ថ្ងៃ ខែ ឆ្នាំ កំណើត : ........06....03.....1990..........................................................

មុខរបរ : ..........ស្មៀនគ្រួ..........................................................................

អាសយដ្ឋាន : នៅភូមិ ..........[illegible]..................ឃុំ ..........ភ្នំតូច......................

ស្រុក ..........[illegible]..................ខេត្ត ..........តាកែវ..........................

### សូមគោរពជូន

### លោកប្រធានក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្ម

**កម្មវត្ថុ** : សំណើរសុំអនុញ្ញាតិឱ្យខ្ញុំបាទ/ នាងខ្ញុំ បានចូលជាសមាជិកសហគមន៍កសិកម្ម ...............

.....ភ្នំតូច [illegible]...................... ដោយក្តីអនុគ្រោះ ។

ខ្ញុំបាទ/ នាងខ្ញុំ សូមសន្យាថានឹង :

-បង់ប្រាក់សមាជិកភាពឱ្យសហគមន៍កសិកម្មចំនួន ....10.000.......................... រៀល

-បង់ថ្លៃជាវភាគហ៊ុនចំនួន ......5...... ហ៊ុន តំលៃក្នុងមួយហ៊ុន 10.000.......... រៀល

តំលៃសរុបនៃភាគហ៊ុនដែលត្រូវបង់ទាំងអស់គឺ ......60.000......... រៀល តាមការកំណត់ដែលមានចែងក្នុងលក្ខន្តិកៈរបស់សហគមន៍កសិកម្ម ។

-គោរពតាម លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង និងសេចក្តីសំរេចនានារបស់មហាសន្និបាត ។

-ស្ម័គ្រចិត្តចូលរួមចំណែកកសាងសហគមន៍ឱ្យមានការរីកចំរើន ។

តាកែវ ថ្ងៃទី ..03.. ខែ ..09.. ឆ្នាំ ២០១៤

ហត្ថលេខា ឬ ស្នាមមេដៃ

សី. សក្ខណា

## ឧបសម្ព័ន្ធទី៤

### សកម្មភាពសម្ភាសន៍ជាមួយលោក មេន ប៊ិន
### ប្រធានក្រុមប្រឹក្សាសហគមន៍កសិកម្មភ្នំដិន សែនសុខ





## ឧបសម្ព័ន្ធទី៥

# សកម្មភាពចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាល











# ឧបសម្ព័ន្ធទី៦

## វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីសហគមន៍កសិកម្ម




## វិញ្ញាបនបត្របញ្ជាក់ការសិក្សាប្រធានសហគមន៍កសិកម្ម

